ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 27-Apr-2016, 10:49
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៦នាទី**

**សវនាការលើកទី៣៩១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៉ាង

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ឆវ័ន្ត

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោក  គង់ សំអុន | ខ្មែរ |
| លោក ប៊ុន ឡឹងចូយ (2-TCW-838) | ខ្មែរ |
| លោក សៅ សារុន (2-TCW-1012) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោក ម៉ុន ឡឹងចូយ ឬ ចាន់ ម៉ុនលីត** (2-TCW-838)

សួរបន្តដោយលោក វ៉ុចទ័រ កូប៉េ ផ្ដើមពី........................................ ទំព័រ ២

សួរដោយលោកស្រី អង់តា ហ្គីសសេ ផ្ដើមពី........................................ ទំព័រ ១១

សួរបន្តដោយលោក គង់ សំអុន ផ្ដើមពី ........................................ ទំព័រ ៣០

**ការសួរសំណួរទៅសាក្សី÷ លោក សៅ សារុន** (2-TCW-1012)

សួរដោយលោកប្រធានអង្គជំនុំ ផ្ដើមពី ........................................ ទំព័រ ៣៨

សួរដោយលោក នីកូឡាស គូមជែន ផ្ដើមពី........................................ ទំព័រ ៤២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៦:១៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ប៊ុន ឡឹងចូយ បញ្ចប់ ហើយនិងផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1012 តាមរយៈប្រព័ន្ធសោតទស្សន៍ជាមួយនឹង -- ពាក់ព័ន្ធជាមួយនឹងអង្គហេតុចោទប្រកាន់មន្ទីរសន្តិសុខភ្នំក្រោល។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោក ប៊ុន ឡឹងចូយ។ លោក និងមេធាវីប្រឹក្សា លោកស្រី សុក សុជាតា មានវត្តមានរួចហើយ នៅក្នុងបន្ទប់សវនាការនេះ។ សាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មបន្ទាប់ទៀត មានរហស្សនាម 2-TCW-1012 តាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្តឧត្តរមានជ័យ។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីនឹងធ្វើសម្បថ មុននឹងគាត់ចូលមកផ្ដល់សក្ខីកម្ម។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្ចបកប្រែ និងខ្ចបកប្រែបន្ត។*

ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺចង្កេះជាប្រចាំ អង្គុយយូរមិនបាន និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០៩:១៥]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី លោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សហការីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរមួយចំនួនទៀតដែលត្រូវសួរលោកនៅព្រឹកនេះ។

ម្សិលមិញលោកបានផ្ដល់ភ័ស្ដុតាង ដែលបញ្ជាក់ថា លោកមិនមែនជាអនុលេខាស្រុកទេ ហើយលោកក៏មិនមានជាសមាជិកគណៈកម្មាធិការស្រុកដែរ ក៏ប៉ុន្ដែលោកជាអនុប្រធានមន្ទីរស្រុក។ តើលោកមានភារកិច្ចធ្វើអ្វីដែរ ក្នុងឋានៈលោកជាអនុប្រធានមន្ទីរ<ស្រុក? តើការងារប្រចាំថ្ងៃរបស់លោកធ្វើអ្វីខ្លះ>?

[០៩:១០:៥៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<លោកមេធាវីការពារក្ដីសូមរង់ចាំបន្ដិចសិន។>

**ប្រធានអង្គជំនុំ៖**

បាទយើងមានការ ធ្វើការជាប្រតិចារឹកកត់សម្គាល់អំពីបញ្ហាការបកប្រែភាសា នៅក្នុងឯកសារ E3/5177 ជាភាសាខ្មែរ គឺត្រង់ទំព័រ 00197860 គឺចម្លើយរបស់សាក្សី គាត់បានឆ្លើយច្បាស់ថា៖ “មុនខ្ញុំនៅស្រុកកោះញែក ខ្ញុំគឺជាអនុប្រធានមន្ទីរស្រុកកែវសីមា ពីព្រោះពូរបស់ខ្ញុំឈ្មោះ កាស៊ី គឺជាចៅហ្វាយស្រុក។ ខ្ញុំគឺជានីរសាររបស់គាត់ក្នុងចន្លោះឆ្នាំ១៩៧១ ដល់ ឆ្នាំ១៩៧៥។ ខ្ញុំគឺជាអនុប្រធានមន្ទីរពីឆ្នាំ៧៥ដល់ឆ្នាំ៧៧។” ដូច្នេះនៅក្នុងចម្លើយនេះច្បាស់លាស់ ប៉ុន្ដែវាមានការខុសក្នុងការបកប្រែភាសាៗអង់គ្លេសហ្នឹង គឺមានការសរសេរផ្សេងពីភាសាខ្មែរ។ សូមយល់ពីបញ្ហានេះ គឺភាសាអង់គ្លេស នៅត្រង់ទំព័រ 00274099។ អ៊ីចឹងគឺគាត់ឆ្លើយច្បាស់លាស់ហើយ គាត់ជាអនុប្រធានមន្ទីរស្រុក។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ក្នុងឋានៈលោកជាអនុប្រធានមន្ទីរស្រុក តើលោកបានបំពេញភារកិច្ចប្រចាំថ្ងៃ ពីមួយថ្ងៃទៅមួយថ្ងៃនោះ លោកធ្វើអ្វីដែរ?

[០៩:១៥:៥០]

**លោក ប៊ុន ឡឹងចួយ៖**

**ឆ៖** បាទ សូមឆ្លើយ ការងារនៅក្នុងមន្ទីរ ក្រៅពីការនាំបុគ្គលិកនៅក្នុងមន្ទីរទៅធ្វើស្រែ ធ្វើចម្ការហ្នឹង ប៉ុន្ដែមានការចែកការងារ។ ជួនកាលប្រធានមន្ទីរគាត់ធ្វើខាងលើកទំនប់ ជួនកាលខ្ញុំដឹកនាំធ្វើស្រែទៅ ជួនកាលខ្ញុំទៅខាងទំនប់ ជួនកាលគាត់មកធ្វើស្រែ។ អ៊ីចឹងពួកខ្ញុំពីរនាក់ផ្លាស់គ្នាទៅវិញទៅមក។

**ស៖** មន្ទីរស្រុកដែលលោកមានតួនាទីជាអនុប្រធានមន្ទីរស្រុកហ្នឹង ក្រៅពីមុខនាទីទាំងនេះ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

លោកមានតួនាទីផ្សេងទៀតទេ? ហើយបើមាន តើជាតួនាទីអ្វីខ្លះដែរ?

**ឆ៖** បាទ បើតាមខ្ញុំធ្លាប់ធ្វើ ដូចជាគ្មានការងារក្រៅពីហ្នឹងទេ គឺមានតាមតែការចាត់តាំងរបស់ថ្នាក់ៗលើប៉ុណ្ណឹង ដូចជាលេខាស្រុកហ្នឹងគាត់ចាត់តាំងយើងធ្វើអីមួយ យើងត្រូវតែធ្វើតាមហ្នឹងទៅ។ ហើយក្នុងដែលការងារធ្វើហ្នឹង មិនហួស គ្មានអីក្រៅពីការងារបង្កបង្កើនផលទេ។

**ស៖** តើខ្លួនលោកផ្ទាល់នេះ ធ្លាប់ដែលបានចូលរួមពាក់ព័ន្ធចាប់ខ្លួនអ្នកណាដែរទេ?

**ឆ៖** បាទ ត្រង់ចាប់ខ្លួន ខាងខ្ញុំអត់មានសិទ្ធិទេ។

**ស៖** តើលោកធ្លាប់ដែលបានឃើញការប្រាស្រ័យទាក់ទងណាមួយដាក់ឆ្លងតាមរយៈមន្ទីរស្រុកនេះដែរទេ ពាក់ព័ន្ធទៅនឹងការចាប់ខ្លួនអ្នកណាម្នាក់?

**ឆ៖** បាទ មានខ្លះដែរ ដូចជាជំនាន់ឆ្នាំ៧៤ ពីកាលខ្ញុំនៅជានីរសារគាត់ទេ កាលនោះខាងខេត្តក្រចេះបានឲ្យដំណឹងតាមចាប់ខ្មែរ-ស មានមួយលើកដែរ។

[០៩:១៥:៥៧]

**ស៖** ចុះក្រោយថ្ងៃ១៧ មេសា ៧៥ តើលោកធ្លាប់ដែលឃើញ ឬក៏ទទួលបាននូវការទាក់ទងគ្នាដើម្បីចាប់ខ្លួនអ្នកណាម្នាក់ ដោយឆ្លងកាត់មន្ទីររបស់លោកដែរទេ?

**ឆ៖** បាទ ក្រោយពេល៧៥ ដូចជារយាលបន្តិច ដូចអត់មានសភាពការណ៍អីទេ រហូតមកដល់ពេលដែលគេចាប់ពួកខ្ញុំហ្នឹងតែម្តង។

**ស៖** ក្នុងឋានៈលោកជាអនុប្រធានមន្ទីរស្រុក តើលោកធ្លាប់ឃើញការប្រាស្រ័យទាក់ទងគ្នាពាក់ព័ន្ធទៅនឹងចម្លើយសារភាពរបស់អ្នកទោសណាមួយដែរទេ?

**ឆ៖** បាទ ព្រោះការងារនេះ ខ្ញុំអត់ដឹងដែរ ព្រោះអត់ដែលបានសួរចម្លើយគេ ហើយអត់មែនសិទ្ធិខ្ញុំផង។

**ស៖** តើលោកផ្ទាល់នេះ ឬក៏មន្ទីរស្រុកធ្លាប់បានចូលរួមពាក់ព័ន្ធសម្លាប់អ្នកណាម្នាក់ចោលដែរទេ?

**ឆ៖** បាទ នៅស្រុកកន្លងមក ដូចមួយជំនាន់ខ្ញុំនៅហ្នឹងក៏អត់ដែលមានដែរ។

**ស៖** តើត្រឹមត្រូវដែរទេ ដែលថាខ្លួនលោកផ្ទាល់ ឬក៏មន្ទីរស្រុកនោះ មិនធ្លាប់ចូលរួមពាក់ព័ន្ធរៀបចំផែនការ ឬក៏សម្លាប់អ្នកណាទេ អ៊ីចឹងឬក៏យ៉ាងណា?

**ឆ៖** បាទ ជាការត្រឹមត្រូវ ព្រោះកន្លងមកនៅក្នុងពេលមុនខែ២ ៧៧ហ្នឹង សភាពការណ៍ធម្មតា

អត់មានសកម្មភាពកាប់សម្លាប់ទេ។ ក្រោយមក ចាប់ពីគេចាប់ផ្តើមចាប់ពួកខ្ញុំហ្នឹង បានជាគេចាប់បុគ្គលិកពួកខ្ញុំជាង៨0នាក់ហ្នឹង ហើយក៏គេកាប់សម្លាប់បន្តបន្ទាប់។ វាជារឿងក្រោយទេ។

[០៩:១៨:៥៨]

**ស៖** ក្នុងពេលលោកបំពេញតួនាទីជាអនុប្រធានមន្ទីរស្រុក តើលោកដែលបានឃើញការប្រាស្រ័យទាក់ទងគ្នារបស់កងពល៩២០ ទៅសេនាធិការ គឺថាទាក់ទងគ្នាទៅវិញទៅមក លោកធ្លាប់ដែលឃើញទេ?

**ឆ៖** បាទ មានមកទាក់ទងដែរ ប្រហែលជាម្តង ឬពីរដង ប៉ុន្តែដូចអត់មានសកម្មភាពអីផង។

**ស៖** <តើវាជាអ្វី ដែលលោកបានឃើញនោះ ឬក៏លោកចងចាំថាបានឃើញនោះ? អ្វីដែលលោកបានឃើញ>ម្តងពីរដង<នោះ> គឺការទាក់ទងរបស់ខាងផ្នែកយោធា<តើវាជាអ្វី>?

**ឆ៖** សូមជម្រាបលោកមេធាវីថា កាលដែលកងពល លោក តាស៊ិន, តាសយ នេះ គាត់មានកងពលមួយគេហៅថាកងពលតូចនៅប្រចាំស្រុកកែវសីមាហ្នឹង ឈ្មោះតាឃុន, តាសូ និងតាពៅ។ តាឃុន គាត់មកហ្នឹង មករួមជាមួយនឹង តាហម, តាឡាំង ហ្នឹង។ ហើយគាត់មក គាត់អត់មានធ្វើអ្វីទេ គឺការងារ ការងារតំបន់អ្នកដាក់ផែនការឱ្យទេ គាត់គ្រាន់តែប្រាស្រ័យមកជាមួយ។ ដល់ពេលក្រោយមកខ្ញុំឧស្សាហ៍ឃើញ តាពៅ ជាមេបញ្ជាការរងគាត់ទេ គាត់មកទាក់ទងពីរឿងស្បៀង ឬក៏រឿងទីតាំងសម្រាប់ឱ្យកងទ័ពគាត់នៅ តែប៉ុណ្ណឹង។ ហើយក្រៅពីហ្នឹងគាត់ប្រជុំនៅក្នុងគណៈស្រុកហ្នឹង ខ្ញុំអត់បានចូលរួមទេ ពីព្រោះខ្ញុំឋានៈតូចតាចអ៊ីចឹង វាមិនអាចចូលបាន អត់បានដឹងរឿងដែរបាទ សូមទោស។

**ស៖** កាលពីម្សិលមិញខ្ញុំបានអានសម្រង់មួយចំនួនឱ្យលោកស្តាប់ <> គឺសារទូរលេខទាក់ទងទៅនឹងការឈ្លានពានរបស់វៀតណាមចូលមកក្នុងដែនដីកម្ពុជាប្រជាធិបតេយ្យ។ តើលោក<ចាំថា>ធ្លាប់ដែលឃើញសារទូរលេខបែបនេះដែរទេ ក្នុងឋានៈលោកជាអនុប្រធានមន្ទីរនុ៎ង?

[០៩:២១:៤១]

**ឆ៖** បាទ និយាយរឿងសារទូរលេខ គឺចប់តែម្តង ដូចមិនដែលឮ អត់ដែលឮទេ។

**ស៖** តើលោកធ្លាប់ដែលឮសួរគេហៅថាក្រុម៧ ឬក៏ប្រាំពីរក្រុម<ទេ>? អ្វីក៏ដោយដែលអាចពាក់ព័ន្ធទៅនឹងលេខ៧ ដែលជា<សកម្មភាព>ខ្លាំង លោកធ្លាប់ដែលឮទេ?

**ឆ៖** អត់ទេ។

**ស៖** ម្សិលមិញលោកបានឆ្លើយជូនអង្គជំនុំជម្រះ អំពីការចោទប្រកាន់ពាក់ព័ន្ធទៅនឹងជោគ

វាសនារបស់ទាហាន លន់ នល់។ មុននឹងខ្ញុំចូលទៅសួរលម្អិតអំពីបញ្ហានេះ គឺថាបើសិនណាជាលោកមិនបានចូលរួមពាក់ព័ន្ធក្នុងការចាប់ខ្លួន សួរចម្លើយ ឬក៏មិនធ្លាប់បានអានចម្លើយសារភាព ឬក៏មិនធ្លាប់បានឃើញ<>សម្លាប់ណាមួយ <ឬក៏ការបញ្ហាទេ> ហេតុអីក៏លោកបានដឹងអំពីជោគវាសនារបស់ទាហាន លន់ នល់ ដែលមានបុណ្យស័ក្តិខ្ពស់ហ្នឹង? <តើ>លោកបានដឹង<អ្វីខ្លះនៅពេលនោះ ដែលលោកនិយាយថាដឹងថាមាន>គោលនយោបាយ<នោះ>?

**ឆ៖** បាទ ព្រោះរឿងនេះ ខ្ញុំក៏បានចូលរួមនៅក្នុងការងារនេះ តាំងពីជំនាន់មុនម្ល៉េះ។ ម្យ៉ាងទាហានទាំងអស់នេះ គាត់ធ្លាប់ទៅមកនៅផ្ទះខ្ញុំ ចូលផ្ទះខ្ញុំ ដេកស្នាក់នៅ ទោះទាហានតូចតាចតាំងពីស័ក្តិ៥ឡើង។ អ៊ីចឹងទេ ពួកគាត់ស្គាល់ខ្ញុំណាស់។ ពេលដែលមានសកម្មភាពដល់ពេលដែលបាក់បែកហើយ ប៉ុល ពត ត្រូវសម្លាប់ពួកគាត់នៅក្នុងឆ្នាំ៧៣នេះ គឺពួកខ្ញុំស្គាល់គាត់ច្បាស់ណាស់។ ហើយពេលដែលគេចាប់ធ្វើមីទិ្ទងនេះ គេធ្វើមីទិ្ទងពីស្រុកកោះញែក កាត់ស្រែសង្គម អូរបួនលើ ហើយគេបាញ់កាំភ្លើងព្រោងព្រាត ដាក់ខ្ទមសេតពីលើឡាន បាញ់ពីលើឡានហ្នឹង គំរាមកំហែងប្រជាជនហ្នឹង ហើយចាប់មនុស្សជាង៣០នាក់ យកទៅសម្លាប់។ អ៊ីចឹងទេ ខ្ញុំក៏ត្រូវដឹងមិនមែនអត់ដឹងទេ ប្រជាជនក្មេងតូចមួយក៏គេដឹងដែរ មិនមែនចំពោះខ្ញុំម្នាក់ទេ។ សូមអស់។

[០៩:២៥:០៦]

**ស៖** ខ្ញុំយល់ហើយនូវអ្វីដែលលោកកំពុងនិយាយ ក៏ប៉ុន្តែវាមានសង្គ្រាមបន្តរហូតមកដល់ឆ្នាំ១៩៧៥។ យុទ្ធជនភាគីទាំងសងខាងកំពុងតែបាញ់សម្លាប់គ្នា។ សំណួរខ្ញុំសួរថា ក្រោយ<ថ្ងៃ១៧ ខែមេសា> ឆ្នាំ១៩៧៥ ហាក់បីដូចជាលោកមិនបានដឹងអំពីការចាប់ខ្លួន ការសួរចម្លើយ ការ<សម្លាប់ជាដើមទេ>។ តើចម្លើយរបស់លោកនេះពាក់ព័ន្ធតែរឿងរ៉ាវកើតឡើងនៅមុនឆ្នាំ១៩៧៥ ឬក៏វាពាក់ព័ន្ធទៅនឹងក្រោយឆ្នាំ១៩៧៥ ទាក់ទងទៅនឹងទាហាននៃរបប លន់ នល់ ដែរឬយ៉ាងណា?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

នេះគ្រាន់តែជាការកត់សម្គាល់ទេលោកប្រធាន។ មេធាវីការពារក្តីកំពុងតែកំណត់<ភ័ស្តុតាងម្តងទៀតហើយ>។ សាក្សីបានឆ្លើយហើយថា ខេត្តនេះបានរំដោះតាំងពីឆ្នាំ១៩៧០ <ដូច្នេះសង្គ្រាមបានចប់

ទៅហើយ>។ សាក្សីមិនបាននិយាយអំពីប្រជាជន ឬក៏យុទ្ធជនដែលស្លាប់នៅក្នុងសមរភូមិទេ។ ដូច្នេះ <មេធាវីការពារក្តីមិនគួរសួរចំណុច>ត្រង់ចំណុចនេះ<ទៅសាក្សីទេ>។

**លោក វិុចទ័រ កូប៉េ៖**

ខ្ញុំមិនដឹងថា តើសហព្រះរាជអាជ្ញារងអន្តរជាតិកំពុងនិយាយពីបញ្ហាអ្វីទេ ពីព្រោះសង្គ្រាមនៅតែកំពុងតែប្រយុទ្ធតទល់គ្នា ហើយនៅខេត្តរតនគិរី មណ្ឌលគិរី មានការទម្លាក់គ្រាប់បែក<ពីសំណាក់សហរដ្ឋអាមេរិក>យ៉ាងច្រើន ទោះបីជារំដោះហើយ។ <វាអាចរំដោះហើយមែន ប៉ុន្តែវាមិនមានន័យថា មិនមានការច្បាំងគ្នាបន្តទៀតទេ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មេធាវីម៉េចក៏លោកផ្តល់សក្ខីកម្មដោយខ្លួនឯង ម៉េចក៏មិនទៅសួរសំណួរតែម្តងទៅ? <តើអ្វីដែលលោកនិយាយ ក៏ជាប់ទាក់ទងនឹងឆ្នាំ១៩៧៧ដែរមែនទេ?>

[០៩:២៧:០០]

**សួរដោយលោក វិុចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកបាននិយាយអំពីជោគវាសនារបស់ទាហាន លន់ នល់ ដែលមានបណ្តាស័ក្តិ។ តើព័ត៌មានពាក់ព័ន្ធទៅនឹងទាហាន លន់ នល់ ដែលមានបណ្តាស័ក្តិនេះ លោកនិយាយសំដៅទៅលើមុនឆ្នាំ១៩៧៥ ឬក្រោយឆ្នាំ១៩៧៥? <សូមប្រាប់មើល៍ តើលោកដឹងរឿងនោះដោយរបៀបណា?>

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ មុន១៩៧៥។

**ស៖** ម្សិលមិញនៅប្រមាណជាម៉ោង១០:០៤នាទី លោកបាននិយាយអំពីជោគវាសនារបស់ទាហាន លន់ នល់។ ហើយនៅត្រង់ចំណុចមួយនោះ ក្នុងចម្លើយដដែល លោកក៏បានឆ្លងទៅនិយាយដល់ការបោសសម្អាត <និង>កម្មាភិបាល<>។ ខ្ញុំសូមអានទូវអ្វីដែលលោកបានឆ្លើយកាលពីម្សិលមិញ ដើម្បីឱ្យច្បាស់លាស់ទាំងអស់គ្នា។ នៅម៉ោង១០:០៤នាទី លោកបានឆ្លើយថា៖ "ការចាប់ខ្លួន និងការសម្លាប់កើតមានឡើងនៅក្នុងឆ្នាំ១៩៧៥ តែចំពោះទាហានណាមានបណ្តាស័ក្តិទេ។ ការបោសសម្អាតនេះគឺថា គេបោសសម្អាតទៅតាមខ្សែរយៈបញ្ជា។" នេះជាផ្នែកមួយនៃចម្លើយរបស់លោក។

ទាក់ទងទៅនឹង<>ជោគវាសនារបស់ទាហាន លន់ នល់ ដែលមានបណ្តាស័ក្តិ។ <>នៅក្នុងចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា E3/5636 អង់គ្លេស <00711207><>,

ខ្មែរ 00042471, បារាំង00727128។ នៅត្រង់ចម្លើយនេះលោកនិយាយពី តាស៊ិន, តាយ៉ា, តាសយ, ហ៊ូ នឹម, តាគាវ, តាសៅ ហើយលោកនិយាយថា "ប្រៀបធៀបទៅនឹងបច្ចុប្បន្ននេះ គឺទាហានដែលមានបណ្ដាស័ក្តិ ពីស័ក្តិ២ឡើងទៅ ត្រូវបានយកទៅសម្លាប់ចោល។ <ច្បាស់ណាស់> តាស៊ិន, តាសយ <ត្រូវ>បាន<គេ>យក<>ទៅសម្លាប់<នៅភ្នំពេញ>។ តាស៊ិន គឺជាមេបញ្ជាការកងពល៩២០"។

សំណួរខ្ញុំនេះ នឹងស្មុគស្មាញបន្តិចហើយ ក៏ប៉ុន្តែតើលោកនិយាយ<>សំដៅទៅលើទាហានដែលមានបណ្ដាស័ក្តិនៅក្នុងជួរកងទ័ពបដិវត្តន៍ដែរឬទេ? ពីព្រោះហាក់បីដូចជាចម្លើយនេះថា កងពល៩២០, កងពល៨១០ ក៏ត្រូវបានបោសសម្អាត ក៏ត្រូវបានចាប់ខ្លួនដែរ។ សូមលោកបញ្ជាក់ឲ្យច្បាស់ចំណុចនេះបន្តិចមើល៍។

[០៩:៣១:០១]

**ឆ៖** បាទ សូមជម្រាប កងពល៩២០ មេបញ្ជាការរបស់គាត់ដំបូងបំផុតនោះគឺ តាស៊ិន។ បន្ទាប់មកទៀតគឺ តាសយ ខ្ញុំស្គាល់តែមេគេពីរហ្នឹងទេ។ បានឃើញតែមួយដងគត់ ពេលដែលគាត់ឡើងមកជួប តាហម គណៈតំបន់។ ពេលនោះខ្ញុំបានធ្វើចុងភៅ ខ្ញុំកំពុងតែធ្វើចុងភៅបម្រើការសន្និបាតរបស់គេនុ៎ង នៅកន្លែងទំនប់ការដ្ឋាន ទំនប់អូរបួនលើ។ ពេលហ្នឹងគេរកពួកនីរសារហ្នឹងបានពីរបីនាក់ ហើយបូកជាមួយប្រជាជន បានទៅជួយធ្វើចុងភៅនុ៎ង។ ខ្ញុំអត់មានការងារធ្វើអី ក៏ទៅជួយធ្វើម្ហូបអីឲ្យគេទៅ។ ហើយបានឃើញ តាស៊ិន, តាសយ ដែលគាត់ឡើងពីភ្នំពេញទៅដំបូងគេបំផុត ទៅជួប តាហម ដើម្បីសហការគ្នា ការងាររបស់គាត់។ ដល់អ៊ីចឹងខ្ញុំបានស្គាល់គាត់តែម្ដងហ្នឹងទេ។ ក្រោយមកគឺឆ្នាំចិត មុនឆ្នាំ៧៧ហ្នឹង ប្រហែលជាដើមឆ្នាំយ៉ាង ឬក៏ឆ្នាំ៧៦ ខ្ញុំមិនចាំ គេក៏ឮថាគេចាប់ពួកគាត់ហ្នឹង បោសសម្អាតទាំងតាស៊ិន ទាំងតាសយ បូកនឹងតាឃុន, តាសូ, តាពៅ អីហ្នឹង ហើយនិងខ្ញុំមិនស្គាល់ឈ្មោះខាងៗកងពលទេ។ អ៊ីចឹងទេ ក្នុងកងពល៩២០ហ្នឹង បើតាមខ្ញុំប៉ាន់ស្មានទៅ មិនស្មានទេ ប្រហែលជាងាប់ច្រើនណាស់។ ប៉ុន្តែយើងអត់បានដឹងថា ចំនួនដែលគេចាប់សម្លាប់នុ៎ង មិនដឹងជាប៉ុន្មានទេ ប៉ុន្តែឃើញនៅអូរបួនលើហ្នឹង គេលើកទំនប់ហ្នឹង គេយកបានម្ដង២០នាក់អីអ៊ីចឹងទៅ ១០នាក់អីអ៊ីចឹង រាល់ថ្ងៃៗអ៊ីចឹងទៅគ្នាមកជួយលើកទំនប់ហ្នឹង។ ខ្ញុំថានេះជារឿងពិតដែលខ្ញុំបានដឹង។ ប៉ុន្តែក្នុងចំណោមដែលគេកាប់សម្លាប់គ្នាគេនោះ ខ្ញុំអត់បានដឹងទេ។ មិនដឹងជាតើគេសម្លាប់គ្នាអស់ប៉ុន្មាន យើងអត់ដឹង។

**ស៖** ខ្ញុំយល់ហើយលោកសាក្សី។ ក៏ប៉ុន្តែចម្លើយរបស់លោកឆ្លើយជូន<>មជ្ឈមណ្ឌលឯកសារកម្ពុជា គឺលោកហាក់បីដូចជាធ្វើការប្រៀបធៀបពាក់ព័ន្ធទៅនឹងបណ្ដាស័ក្តិ គឺបណ្ដាស័ក្តិហ្នឹងពាក់ព័ន្ធ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01239237



តាស៊ិន, តាសយ។ ហើយក្រោយមក ក៏លោកប្រៀបធៀបទៅនឹងបណ្តាស័ក្តិ ទាហានដែលមានបណ្តាស័ក្តិពីអនុសេនីយ៍ទោឡើងទៅ។ ហើយម្សិលមិញនេះ ក៏លោកនិយាយអំពីការបោសសម្អាតកម្មាភិបាលផងដែរ។ តើ<>នេះ<ជាអ្វីដែល>លោកកំពុងតែប្រៀបធៀបពាក្យ“បណ្តាស័ក្តិ”នេះ <ជាមួយសមាជិកក្នុងកងពល៩១០ និង>៩២០ <>នឹងបណ្តាស័ក្តិនៃទាហាន លន់ នល់ ឬក៏យ៉ាងណា?

[០៩:៣៣:៥៦]

**ឆ៖** បាទ ព្រោះខ្ញុំដឹងថា នៅមណ្ឌលគិរីនេះ ក្នុងពេលនោះគឺអស់ហើយ ទាហាន លន់ នល់អត់មានទៀតទេ។ មានម្នាក់ពីរនាក់ដែលគាត់ជាប្រជាជនទៅហើយ អត់មានពាក់ព័ន្ធអីទេ។ ក្នុងពេលនេះ គឺទាហានខ្មែរក្រហមតែម្តង ហើយកាប់សម្លាប់ កាប់សម្លាប់ទាហានខ្មែរក្រហមគ្នាឯងហ្នឹងឯង។ បើនិយាយរឿងទាហាន លន់ នល់ អី ដូចអត់មានទៅនុំងទៀតទេ ព្រោះចប់ទៅហើយ។ ព្រោះតាំងពី៧០មក រហូតដល់៧៥នេះ ឆ្ងាយណាស់ វាប្រាំប្រាំមួយឆ្នាំបាត់ហើយ។ អ៊ីចឹងគេបោសសម្អាតដូចចង់អស់ទៅហើយ។ អ៊ីចឹងបើលោកថា ចង់សួរថាពីបញ្ហារឿងទាហាន លន់ នល់ ខ្ញុំជឿថា ដូចអត់មានទេ។ បើមាន មានតែទាហានខ្មែរក្រហមហ្នឹងឯង។ សូមអស់។

**ស៖** សូមអរគុណលោកសាក្សី។ នេះគឺជាប្រធានបទចុងក្រោយរបស់ខ្ញុំហើយ ដែលទាក់ទងទៅនឹងព្រឹត្តិការណ៍មុនឆ្នាំ១៩៧៥។ ប្រធានបទនេះ គឺជាប្រធានបទនិយាយអំពីការទម្លាក់គ្រាប់បែក <នៅមណ្ឌលគិរី និងរតនគិរី>ពីសំណាក់សហរដ្ឋអាមេរិក។ ខ្ញុំសូមអានចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីសួរបញ្ជាក់បន្ថែម ឯកសារ E3/5636 ERN អង់គ្លេស <00711231>, ខ្មែរ <00042489> ដល់ 90, បារាំង <00727146>។ “តើ<កងទ័ពជាគោលដៅនៃ>ការទម្លាក់គ្រាប់បែក<ឬ?> ហើយសំណួរមិនទាន់បញ្ចប់ផងលោកឆ្លើយថា៖ <ពួក>គេ<ជា>គោលដៅក្នុងការទម្លាក់គ្រាប់បែកនេះ ហើយអ្នកភូមិក៏ទទួលរងការឈឺចាប់។ ជួនកាលការទម្លាក់នេះ គឺថា មានគោលបំណងទម្លាក់ដាក់ភូមិតែម្តង។ នៅក្នុងភូមិកាទីគឺថាគ្រាប់បែកបេ-៥២ ទម្លាក់ចំកណ្តាលភូមិតែម្តង <បណ្តាលឲ្យស្លាប់មនុស្សជាច្រើនគ្រួសារ>។ <>ភូមិទាំងមូលហ្នឹងក្លាយទៅជារណ្តៅយ៉ាងជ្រៅ <មានទំហំប៉ុនផ្ទះពីរ>។ ហើយនិយាយសរុបទៅគឺថា គ្រាប់រាប់លានគ្រាប់ <ត្រូវបាន>ទម្លាក់ <នៅតាមព្រំដែន។ យន្តហោះបេ-៥២ នីមួយៗមានផ្ទុកគ្រប់បែក២០០គ្រាប់។>ក្នុងមួយពេលៗ <មានយន្តហោះបេ-៥២ ពីរ>បីទៅបួន<គ្រឿងទម្លាក់គ្រាប់បែក>នេះ។” លោកចាំទេ ថាលោកបានឆ្លើយសំណួរនេះ ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា?

01239238



[០៩:៣៦:៥២]

**ឆះ** បាទ សូមរាយការណ៍។ ការទម្លាក់គ្រាប់របស់សហរដ្ឋអាមេរិកនេះ បើតាមខ្ញុំចាំ គឺវាទម្លាក់ចាប់ពីឆ្នាំ១៩៦៩ ដល់ឆ្នាំ៧៣។ អ៊ីចឹងទេក្នុងអំឡុងហ្នឹង គឺគ្រាប់បែកមានគ្រប់ប្រភេទ មានបេ-៥២ មានអាណាប៉ាល់ មានប្រេងសាំង រ៉ុកកែ្កត ហើយនិងដែលគ្រាប់បែកចង្កោម ដូចជាប៊ុមប៊ីជាដើម។ ដូច្នេះខ្ញុំសូមរាយការណ៍ថា ទីតាំងដែលទម្លាក់គ្រាប់បែកហ្នឹង គឺមាននៅស្រុកកោះញែក គឺនៅពាមជីមៀត ឃុំពាមជីមៀត កោះម្បើល តាមដងអូរ តាមទន្លេស្រែពក អូរលាវ អូរតាង អូរប្លាយ រហូតដល់អូរដែលឡើងមកស្រុកពេជ្រាដា តាមព្រំប្រទល់ដែរហ្នឹង គឺអូរប្លាយ អូរពុល អូរតាំ ភ្នំដំលៀ ចាក់មកដាក់ដាំ កង់រ៉ូឡង់ ធ្លាយមកកែវសីមានេះ។ ហើយពិសេសគឺគាត់បោសសម្អាតនៅក្នុងឆ្នាំ៧០នេះ មិនមែនបោសសម្អាតតាមព្រំដែនទេ គឺគាត់បោសសម្អាតនៅក្នុងទឹកដីមណ្ឌលគិរី និងទឹកដីរតនគិរី ក្រចេះ ស្ទឹងត្រែងហ្នឹង ទាំងអស់។ ហើយទម្លាក់វាយប៉ាយតែម្តង។ អ៊ីចឹងមានឆ្នាំ៧០ហ្នឹង ក៏មាន ក្នុងភូមិមួយគេហៅភូមិធាង បានរលាយអស់មួយភូមិតែម្តង។ ត្រូវទម្លាក់ហ្នឹង មិនមែនទម្លាក់ទាហានយៀកកុង ឬក៏ទាហានខ្មែរក្រហមទេ គឺទម្លាក់សំដៅតែលើផ្ទះប្រជាជនតែម្តង។ អ៊ីចឹងភូមិហ្នឹងត្រូវរលាយទៅ នៅសល់ប្រហែលជាប្រាំមួយគ្រួសារគត់ ដែលសេសសល់ពីស្លាប់ទៅ។ អ៊ីចឹងភូមិហ្នឹងក៏មិនបានត្រឡប់ទៅនៅវិញទេ ទាល់ពីនុំងមកទល់បច្ចុប្បន្ននេះ ក៏ចោលតែម្តង។ ហ្នឹងខ្ញុំបានចាំនូវការទម្លាក់គ្រាប់បែកនេះ។ ហើយការទម្លាក់គ្រាប់បែកនៅក្នុងពេលសង្គ្រាមវៀតណាមវាយជាមួយទាហានលន់ នល់ នៅលើភ្នំដោះក្រមុំនេះ ក៏មានស្លាប់ច្រើនដែរ ប៉ុន្តែវាមិនប៉ះពាល់ដល់ប្រជាជនច្រើនពេកទេ ស្លាប់តែទាហាន ហើយនិងដែលទាហានយៀកកុង ទាហានខ្មែរ ខ្លះៗដែរ។ ធម្មតាទម្លាក់ពីលើហ្នឹងមិនដឹងថាទាហានណាទាហានណីទេ បើបេ-៥២ វាដាក់ទៅហើយ មិនស្គាល់ដែលរបស់យើង របស់គេទេ ដាក់ត្រូវតែទាំងអស់ហ្នឹង។ បាទ សូមអស់ប៉ុណ្ណឹង។

[០៩:៣៩:៥៥]

**សះ** សំណួរចុងក្រោយរបស់ខ្ញុំនៅខាងក្រោមបទសម្ភាសន៍<ជាមួយ>មជ្ឈមណ្ឌលឯកសារកម្ពុជា គេសួរថា៖ "តើៗការទម្លាក់គ្រាប់បែកសម្លាប់ជនស៊ីវិល <ឬ>ទាហាន<>? លោកឆ្លើយថា៖ គឺមានតែជនស៊ីវិលដែលត្រូវបានស្លាប់ គឺមិនមានយោធា ឬកងទ័ពត្រូវបានស្លាប់ទេ។" តើនេះជាសម្តីដែលលោកឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជាគឺ ការទម្លាក់គ្រាប់បែកសហរដ្ឋអាមេរិកសម្លាប់តែជនស៊ីវិលទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ព្រោះថាខ្ញុំបានដឹង ព្រោះថាបើនិយាយរឿងទ័ពខ្មែរក្រហមជំនាន់ហ្នឹង ដូចអត់មានត្រូវគ្រាប់បែកអាមេរិកទេ ប៉ុន្តែបើវៀតណាមមាន។ វៀតណាមត្រូវងាប់ច្រើនណាស់ ប៉ុន្តែបើទាហានខ្មែរក្រហម ទាំងពួកខ្ញុំ ទាំងអីហ្នឹងអត់ដែលមានទេ។ បើប្រជាជនមានការគ្រោះថ្នាក់ច្រើន។ អានេះនិយាយត្រង់ ហើយពិតទៀត។

**ស៖** អ៊ីចឹងសំណួរចុងក្រោយបំផុតរបស់ខ្ញុំគឺថា ក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក ៗបានផ្ដល់ជាស្ថិតិថា មណ្ឌលគិរីមានប្រជាជនប៉ុន្មាន រតនគិរីមានប្រជាជនប៉ុន្មាន។ គេសួរសំណួរលោកពីម្សិលមិញ តើលោកអាចនឹងប្រាប់បានទេ ថាតើប្រជាជនស៊ីវិលប៉ុន្មាននៅខេត្តមណ្ឌលគិរី និងរតនគិរីដែលបានស្លាប់ដោយការទម្លាក់គ្រាប់បែកសហរដ្ឋអាមេរិកដែរឬទេ?

**ឆ៖** បាទ នេះជាស្ថិតិរបស់ខ្មែរក្រហម។ ជំនាន់នុ៎ងគេប្រាប់ថា នៅខេត្តរតនគិរីស្លាប់ជាង ៣.000 នាក់ មណ្ឌលគិរីអស់៦00នាក់ទេ។ ប៉ុន្តែខ្ញុំក៏មិនជាក់ច្បាស់ដែរ ព្រោះមិនមែនជាតួនាទីខ្ញុំទេ គ្រាន់តែៗឮ ដែលគេប្រកាស។ សូមទោស សូមអរគុណ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមអរគុណលោកសាក្សី។ ខ្ញុំអស់សំណួរដែលត្រូវសួរហើយ។

[០៩:៤២:០៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សី។ បាទ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកសាក្សី។ ជម្រាបសួរសហភាតា អស់លោកលោកស្រីចៅក្រមទាំងអស់ជាទីគោរព។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អ៊ីចឹងខ្ញុំសូមចោទសំណួរមួយចំនួនទៅកាន់លោក។ សំណួរបឋមរបស់ខ្ញុំទាក់ទងទៅនឹងតួនាទីរបស់លោកជានីរសារ <គឺ>តួនាទីរបស់លោកមុនឆ្នាំ១៩៧៥។ ខ្ញុំយល់ថា លោកជានីរសារនៅពេលណាមួយ តើលោកបានចាប់ផ្ដើមធ្វើជានីរសារមុនឆ្នាំ១៩៧៥ ឬក៏យ៉ាងណា?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ ខ្ញុំបើនិយាយឲ្យចំ ខ្ញុំធ្វើនីរសារគាត់ក្នុងឆ្នាំ៧៣ទេ មិនមែន៧១ទេ ៧៣មកដល់៧៥។ បន្ទាប់ពី៧៥មក គាត់បានតែងតាំងខ្ញុំជាអនុប្រធាន ខ្ញុំអត់បានដើរតាមគាត់ទៀតទេបាទ។ ខ្ញុំធ្វើការនៅមន្ទីរវិញ។ សុំអស់។

**ស៖** នៅក្នុងចម្លើយជាភាសាបារាំងនោះ ខ្ញុំឮថា លោកឆ្លើយថា៖ "ខ្ញុំជានីរសាររបស់គាត់ ពីឆ្នាំ ១៩៧៣ ដល់ឆ្នាំ១៩៧៥" លោកចង់និយាយអំពីអ្នកណាថា នីរសារគាត់នេះ របស់អ្នកណា?

[០៩:៤៣:៥៩]

**ឆ៖** បាទ ជានីរសាររបស់ កាស៊ី។

**ស៖** លោកបានកើតនៅមណ្ឌលគិរី អ៊ីចឹងជាការត្រឹមត្រូវដែរឬទេ ថាលោកនៅរហូតដល់សព្វថ្ងៃនេះ គឺលោករស់នៅមណ្ឌលគិរីរហូត?

**ឆ៖** បាទ ពិតមែន។

**ស៖** នៅពេលដែលលោកជ្រើសរើសធ្វើជានីរសារនេះ <តើចាំបាច់>ត្រូវតែស្គាល់ទីតាំងភូមិសាស្ត្រ <>ទឹកដី<ព្រៃឈើ>ឲ្យច្បាស់<លាស់ទេ នៅពេលដែលខ្មែរក្រហមប្រតិបត្តិការនៅក្នុងព្រៃនោះ>?

**ឆ៖** បាទ ចំណុចនេះខ្ញុំ ដោយសារថាគាត់ពេញចិត្ត ហើយគាត់បានទៅសុំពីថ្នាក់លើ យកខ្ញុំទៅធ្វើនីរសារនេះ មិនមែនជាការងាយទេ ព្រោះខ្ញុំមានអតីតដែលឪពុកខ្ញុំមិនសូវត្រូវគ្នាជាមួយខ្មែរក្រហមប៉ុន្មានទេ ដែលគេយកទៅសម្លាប់ដែរហ្នឹង។ ហើយគេមិនទុកចិត្តខ្ញុំ មិនអាចឲ្យខ្ញុំទៅនៅជាមួយគេដទៃ។ ដោយសារ កាស៊ី គាត់ជាឪពុកមាខ្ញុំ ដែលគាត់ទុកចិត្តខ្លួនឯង ហើយគាត់ទៅសុំគេមករស់នៅជាមួយគាត់។ តើសួរថាបញ្ហារឿងព្រៃម៉ាគីនេះ ម្យ៉ាងគឺខ្ញុំស្គាល់ច្បាស់មែន មួយខេត្តមណ្ឌលគិរីហ្នឹងកន្លែងណាក៏អត់ចន្លោះដែរ។

**ស៖** លោកសាក្សី ខ្ញុំសូមឲ្យលោកស្តាប់សំណួរខ្ញុំឲ្យបានច្បាស់ ហើយខ្ញុំនឹងសួរលោកឲ្យបានច្បាស់លាស់បំផុត។ អ៊ីចឹងតាមចម្លើយរបស់លោកអំម្បាញ់មិញនេះ គឺបានន័យថា ការស្គាល់ទឹកដី ឬក៏ទីតាំងភូមិសាស្ត្រច្បាស់លាស់ហ្នឹង គឺជាលក្ខណៈវិនិច្ឆ័យដើម្បីរើសនីរសារ អ៊ីចឹងមែនទេ?

[០៩:៤៦:១៩]

**ឆ៖** បាទ មិនត្រឹមត្រូវទេ ពីព្រោះគាត់រើសនេះ គឺតាមសាច់ញាតិទេ។

**សៈ** តើលោកស្គាល់តំបន់នៅមណ្ឌលគិរីដែរឬទេ? ខ្ញុំសូមរំឭកលោក នៅក្នុងកិច្ចសម្ភាសន៍របស់លោកនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារE3/5636 ERNជាភាសាបារាំងគឺ 00727140, ERN ជាភាសាអង់គ្លេសគឺ 00711225, ERN ជាភាសាខ្មែរគឺ 00042483។ លោកពន្យល់ថា លោកបានធ្វើដំណើរច្រើន លោកនិយាយដូចតទៅនេះ៖ “គឺកាលពីសម័យនោះ ខ្ញុំមាន<កម្លាំង> ហើយខ្ញុំក្លាហាន ខ្ញុំពូកែធ្វើដំណើរក្នុងព្រៃ ខ្ញុំស្គាល់ផ្លូវច្បាស់លាស់ដើម្បីទៅប្រទេសវៀតណាម។ នេះជាអ្វីដែលមនុស្សទូទៅគេនិយាយ ព្រោះថាខ្ញុំទៅ ទៅមកៗមករហូត អ៊ីចឹងខ្ញុំស្គាល់ផ្លូវដូចបាតដៃខ្ញុំអ៊ីចឹង។”

សំណួរខ្ញុំច្បាស់លាស់ទៀតនោះ ខ្ញុំចង់ដឹងថាតើជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថាលោកស្គាល់តំបន់នោះច្បាស់ណាស់ ហើយលោកអាចដើរកាត់ព្រៃ ក្នុងព្រៃយ៉ាងស្រួល? ហើយជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា លោកស្គាល់តំបន់នោះដូចបាតដៃលោកអ៊ីចឹង?

**ធ៖** បាទ ពិតមែនបាទ ស្គាល់ទាំងអស់ហ្នឹង។

**សៈ** ហើយលោកក៏ស្គាល់ច្បាស់ដែរ កោះញែក លោកក៏ស្គាល់កោះញែកច្បាស់ដែរ ត្រឹមត្រូវដែរឬទេ?

**ធ៖** បាទ ស្រុកកោះញែកជាស្រុករបស់ខ្ញុំ។

[០៩:៤៨:៤០]

**សៈ** សូមអរគុណ។ អ៊ីចឹងកាលពីម្សិលមិញ សហព្រះរាជអាជ្ញាបានចោទសំណួរទៅលោកពាក់ព័ន្ធទៅហ្នឹងព្រែកមួយ -- អូរមួយ។ ខ្ញុំអានឈ្មោះមិនខុសទេនោះ សូមអភ័យទោសដល់ខ្ញុំ គឺឯកសារ E3/6760 ចំណុច<ទី១> ERNគឺ <01213545> ERN ជាភាសាបារាំង, ERN ជាភាសាអង់គ្លេសគឺ 01194793, ERN ជាភាសាខ្មែរគឺ 00586074។ នេះគឺជាឯកសារដែលសហព្រះរាជអាជ្ញាបានបង្ហាញជូនលោកកាលពីម្សិលមិញ នៅពេលដែលលោកនិយាយថា លោកមិនស្គាល់អូរដែលមានឈ្មោះថា “អូរល្ពៅ”។ ចំពោះអ្នកបកប្រែបើសិនមិនមានឯកសារទេ គឺសរសេរជាភាសាបារាំងគឺ អូ-អិល-ប៉េ-អូ-វ៉េ អ៊ីចឹងអូរល្ពៅ លោក។ លោកស្គាល់កោះញែកនេះច្បាស់លាស់នេះ លោកបានឆ្លើយថា លោកមិនស្គាល់អូរហ្នឹងទេ។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើអូរនេះនៅស្រុកផ្សេង ឬក៏ខេត្តផ្សេង ឬក៏យ៉ាងណា?

**ធ៖** បាទ ខ្ញុំឆ្ងល់ ព្រោះអូរល្ពៅនៅខេត្តមណ្ឌលគិរីដូចអត់មានមួយសោះ។ មិនមែនតែកោះញែកមួយទេ ទាំងអស់ទូទាំងប៉ុន្មាន ប្រាំស្រុកនេះ ខ្ញុំស្គាល់ច្បាស់ណាស់ ប៉ុន្តែអត់មានឈ្មោះនេះតែម្តង។

**សៈ** ទាក់ទងនឹងខេត្តមណ្ឌលគិរីដដែល ហើយយើងដឹងថាវាជាខេត្តមួយដែលមានជនជាតិភាគ

តិចច្រើន។ អ៊ីចឹងសំណួរខ្ញុំចង់ដឹងថា ក្រៅពីភាសាខ្មែរលោកមាននិយាយភាសាផ្សេងទៀតដែរឬទេ?

**ឆ៖** បាទ ខ្ញុំចេះបានពីរបីភាសាដែរ គឺភាសាព្នង, ភាសាឡាវ, ភាសាចារ៉ាយ ហើយនិងភាសាផ្សេងៗហ្នឹងតិចតួចៗ។

**ស៖** តើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកមានបាននិយាយភាសាទាំងប៉ុន្មាននេះដែលលោកបានរៀបរាប់អម្បាញ់មិញហ្នឹងដែរឬទេ?

**ឆ៖** បាទ ជំនាន់ខ្មែរក្រហម គេអត់បិទសិទ្ធិអារឿងនិយាយផង ចង់និយាយអីនិយាយតាមតែជនជាតិនេះគេមាន។

[០៩:៥២:០០]

**ស៖** តើលោកមានចាំដែរឬទេ ក្នុងចំណោមកម្មាភិបាលនៃកម្ពុជាប្រជាធិបតេយ្យមានកម្មា-ភិបាលដែលមានដើមកំណើតជាជនជាតិភាគតិចដែរឬទេ? ហើយ<> បើសិនជាលោកចាំវិញ <តើ> លោកអាចបញ្ជាក់ជូនបានដែរឬទេថា<ពួកគេឈ្មោះអីខ្លះ? តើពួកគេជា>ជនជាតិភាគតិច<>អីខ្លះ? <តើលោកចាំទេ>?

**ឆ៖** បាទ មណ្ឌលគិរី បើគិតទៅទាំងអស់ គឺចម្រុះជនជាតិ ហើយកម្មាភិបាលភាគច្រើនគឺជនជាតិ។ ខ្មែរមានប្រហែលជាមួយ ពីរនាក់អីប៉ុណ្ណឹងទេ។ ជនជាតិនេះគឺនៅខាងមណ្ឌលគិរីមានឡាវ មានជនជាតិទំពួន ជនជាតិព្នង ហើយមានខ្លះជនជាតិចារ៉ាយ មួយពីរដែរ។

**ស៖** សំណួរខ្ញុំហ្នឹងអម្បាញ់មិញហ្នឹងខ្ញុំចង់ដឹងថា តើមានកម្មាភិបាលដែលមានដើមកំណើតជាជនជាតិភាគតិច<ទេ>? <បើមាន តើពួកគាត់ជាអ្នកណា>ខ្លះ?

**ឆ៖** បាទ ហម – ឈ្មោះ ឡាំង នេះ ឪពុកឡាវ ម្ដាយចារ៉ាយ កាត់ព្នង។ ខាំ ភួន នេះគាត់ឡាវកាត់ទំពួន។ ហើយ កាស៊ី នេះព្នងចំតែម្ដង អត់មានឡាវ មានអីទេ។ ហើយ ស្វាយ នេះចារ៉ាយចំតែម្ដង។ ឡេង នេះក៏ចារ៉ាយចំដែរ។ បើ ឡាន់ វិញគាត់ចារ៉ាយកាត់ព្នង។ ខ្ញុំសូមជម្រាប មិនអាចរៀបរាប់អស់។ សូមអស់ប៉ុណ្ណឹង។

**ស៖** តើលោកមាននៅចាំឈ្មោះ ប៊្លូលី ទេ? <តើ>លោកមានចាំថា គាត់ហ្នឹងមានដើមកំណើតជាជនជាតិអីដែរទេ?

**ឆ៖** ប៊្លូលី បើតាមខ្ញុំស្គាល់គាត់ ៗនៅពាមជីមៀត នៅឃុំពាមជីមៀត ភូមិពាមជីមៀត ឃុំពាមជីមៀត ស្រុកកោះញែក ខេត្តមណ្ឌលគិរី គាត់ជាជនជាតិឡាវ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:៥៤:៤៧]

**ស៖** ខ្ញុំចង់និយាយអំពីចំណុចមួយទៀតជាមួយលោក។ នៅពេលមួយលោកបាននិយាយពីឈ្មោះ តាសារុន។ តើលោកអាចនិយាយអំពីគាត់បានដែរឬទេ ថាតើគាត់មានមុខតំណែងអ្វីឲ្យច្បាស់លាស់? ហើយគាត់មានសិទ្ធិអំណាចអ្វីខ្លះនៅពេលនោះ?

**ឆ៖** បាទ តាសារុន គាត់ដំបូងគាត់ជាលេខាស្រុកពេជ្រាដាទេ ពីមុន ពី៧០មក ។ដល់៧៥, ៧៣, ៧៤នេះ គាត់បានឡើងជាសមាជិកគណៈកម្មការខេត្តមណ្ឌលគិរីហ្នឹង។ ហើយពេល តាឡាំង ជាមួយនឹង ខាំ ភួន វ៉ៃគ្នាស្លាប់ហ្នឹង គាត់ប្រហែលជាថ្នាក់លើបានតែតាំងគាត់ឡើងជំនួស តាឡាំង ហ្នឹង តែម្តង។ ពេលហ្នឹងត្រូវមានការកាប់សម្លាប់ច្រើនណាស់ ហើយគាត់ហ្នឹងឡើងក៏ឡើងក្នុងពេល ក្រោយ ប្រហែលមួយខែអី ឬពីរខែអីក៏មិនដឹងដែរ ពេលហ្នឹងវាកៀកនឹងថ្ងៃរំដោះទៅហើយ។ អ៊ីចឹងគាត់ឡើង ប្រហែលជាមិនបានមួយឆ្នាំផង ក៏បានរំដោះបាត់ទៅហើយ។ ឋានៈគាត់ខ្ញុំដឹងប៉ុណ្ណឹងបាទ។

**ស៖** ខ្ញុំសូមការបញ្ជាក់មួយ ជាភាសាបារាំង និងជាភាសាអង់គ្លេស លោកនិយាយថា គាត់ចាប់ផ្តើមជាដំបូងនោះ គាត់ជាលេខាស្រុក។ អ៊ីចឹងខ្ញុំចង់សួរលោកថា ជាលេខាស្រុកណាដែរទៅ?

**ឆ៖** បាទ គាត់ជាលេខស្រុកពេជ្រាដា។

**ស៖** តើគាត់មកជំនួស ឡាំង ឡើងកាន់ជំនួស ឡាំង នៅពេលណាដែរ លោកចាំកាលបរិច្ឆេទទេ កាលនុ៎ង ?

**ឆ៖** បាទ ប្រហែលជាចូលឆ្នាំ ចុងឆ្នាំ៧៧ ចូល៧៨ហ្នឹង។

[០៩:៥៧:១៣]

**ស៖** តើជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា នៅពេលនោះលោកកំពុងតែធ្វើការនៅរយ៉? តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ខ្ញុំនៅរយ៉។

**ស៖** តើលោកមានទំនាក់ទំនងផ្ទាល់ជាមួយ តាសារុន ហ្នឹងដែរឬទេ?

**ឆ៖** បាទ តាមខ្ញុំចំណាំ ខ្ញុំបានសុំច្បាប់ទៅដេកពេទ្យកាលខ្ញុំឈឺ ហើយ តាកាឡុយ ប្រធានមន្ទីរ គាត់ហ្នឹង បានទៅដឹកខ្ញុំហ្នឹង ហើយគាត់មានលិខិតមួយ គាត់សរសេរ ឲ្យខ្ញុំសរសេរផ្ទាល់ ប៉ុន្តែគាត់បាន បំពេញហើយ គាត់ឲ្យសរសេរឈ្មោះ។ ហើយឃើញគាត់បោះត្រាហ្នឹង ឈ្មោះគាត់ បានខ្ញុំចាំថា ប្រហែលជាគាត់ឡើងធំទៅហើយ ព្រោះខ្ញុំនៅហ្នឹង ក៏ខ្ញុំមិនដឹងថាគាត់ឡើងធំប៉ុនណាទេ ព្រោះនៅក្នុង

ការដ្ឋានហ្នឹង មិនអាចលេចចេញទៅណាទៅណឺបាន ព្រោះមានតែការងារនៅក្នុងស្រែរហូត។ ហើយដល់ពេល តាកាឡយ ទៅយកខ្ញុំមកហ្នឹង ដោយសារការសំណើពីប្រធានមន្ទីររយ៉ហ្នឹង ថាឲ្យខ្ញុំសុំច្បាប់ទៅដេកពេទ្យ។ ប៉ុន្តែខ្ញុំមើលអត្ថន័យនៅក្នុងសំបុត្រហ្នឹង មិនមែននេះទេ គេដាក់ថាឲ្យខ្ញុំមានសេរីភាពឡើងវិញ។ អ៊ីចឹងបានន័យថា ដូចជាខ្ញុំហ្នឹងវារួចពីទោស។ គេសរសេរនៅក្នុងហ្នឹង ខ្ញុំចំណាំប៉ុណ្ណឹង ប៉ុន្តែគេដាក់ឈ្មោះហ្នឹង គេឲ្យខ្ញុំសរសេរខ្លួនឯង ព្រោះគេវាយតែកូឡោនៗទេ ដែលអង្គុលីលេខហ្នឹង។ ហើយដល់ពេលចុះដែលកូឡោនហ្នឹង គេឲ្យខ្ញុំសរសេរដៃខ្លួនឯង។ អ៊ីចឹងខ្ញុំដឹងថា តាសារុន គាត់មានសិទ្ធិជាលេខាខេត្តបាត់ទៅហើយ ហើយត្រាហ្នឹងត្រារបស់គាត់ ហើយឈ្មោះៗរបស់គាត់ បោះនៅលើក្រដាសហ្នឹង។ តាកាឡយ កាន់ទៅឲ្យខ្ញុំ ហើយឲ្យខ្ញុំចុះហើយ ខ្ញុំទៅដេកពេទ្យតំបន់។ ខ្ញុំដឹងតែប៉ុណ្ណឹង។

[០៩:៥៩:៤១]

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺឯកសារ E3/8749 ERN ជាភាសាបារាំងគឺ 00727661, ERN ជាភាសាអង់គ្លេសគឺ 00715750, ERN ជាភាសាខ្មែរគឺ 00711942។ លោកនិយាយពី តាសារុន ដូចតទៅនេះ៖ "ក្រោយពីពេល តាសារុន ឡើងជំនួស តាឡាំង មកគឺមានការចាប់ខ្លួនច្រើនជាងកាល តាឡាំង នៅកាន់អំណាច ពីព្រោះថាពួកគេសងសឹកគ្នាទៅវិញទៅមក ដោយចាប់កម្មាភិបាល<ដែលជិតស្និទ្ធនឹង>អតីតលេខាតំបន់ចាស់។ <>ក្នុងឋានៈជាលេខតំបន់ តាសារុន អាចសម្រេចចាប់ចងមនុស្សបាន។" សូមបញ្ចប់ការដកស្រង់។ សំណួរខ្ញុំចង់ដឹងដូចតទៅនេះ ខ្ញុំចង់ដឹងថា តើលោកមានប្រភពមកពីណា ដើម្បីបញ្ជាក់ថា តាសារុន នេះគាត់មានសិទ្ធិចាប់ចងមនុស្ស? ហើយលោកចង់និយាយយ៉ាងម៉េចដែរ នៅពេលដែលលោកប្រើពាក្យថា "ពួកគេសងសឹកគ្នាទៅវិញទៅមក" យ៉ាងដូច្នេះនោះ?

**ឆ៖** បាទ ត្រង់នេះខ្ញុំសូមបញ្ជាក់ទៀត។ ក្រោយពី តាខាំ ភួន រ៉ៃ តាឡាំង ស្លាប់ទៅ ហើយ ជួន – តាជួន ជាប្អូនថ្លៃរបស់ តាឡាំង ហ្នឹងឡើងប្រកាស ដើរប្រកាសសាធារណៈពេញមួយតំបន់ហ្នឹងតែម្តងពិសេសនៅតាមការដ្ឋាន និងសហករណ៍។ ហើយថា ក្រោយមកថា គាត់នឹងឡើងជំនួសបងថ្លៃគាត់ តែមិនបានប៉ុន្មានថ្ងៃ ចាប់ផ្តើមគេចាប់គាត់វិញ។ ពេលហ្នឹងខ្ញុំសុំជម្រាបថា ពេល ខាំ ភួន ជាមួយ ហាម រ៉ៃ គ្នានេះ ខ្សែតាហាម ហ្នឹងគឺមាន តាលក, តាអនស៊ី សុទ្ធតែថ្នាក់ស្រុកទេ ព្រោះគាត់ដល់ពេលហ្នឹងឡើងព្រឹបៗ មកអង្គុយជំនួសនេះតែម្តង។ ប៉ុន្តែមិនដឹងថាខាងលើហ្នឹង គេចាត់ឲ្យពួកគាត់ធ្វើអ៊ីចឹងដែរឬ ខ្ញុំអត់ដឹងទេ។ ប៉ុន្តែបើតាមដឹងហ្នឹង ពួកគាត់ឡើងអង្គុយអាកន្លែងថ្នាក់ពួកអ្នកបាត់ៗទៅហ្នឹងហើយ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:០២:២៤]

ដល់ពេលហ្នឹង មានការច្រឡូលច្របល់ ចាប់ផ្ដើមចាប់មនុស្ស។ ចាប់ហ្នឹងគឺចាប់តែខ្សែ ខាំ ភួន ពូជសាសន៍របស់ ខាំ ភួន ហ្នឹង អត់មានសល់ទេ។ កម្មាភិបាលខ្សែ ខាំ ភួន ហ្នឹងវាច្រើន តាជួន, តាចាន់ ថន, តាថា, វ៉ាន់ ខាំ, តាវ៉ា, ឬលី, ឬឡៃហ្នឹង ខ្សែរបស់តាខាំ ភួន ទាំងអស់។ អ៊ីចឹងមួយពូជហ្នឹង គេចាប់ មិនតិចទេ រាប់រយនាក់។ ប៉ុន្តែបើគិតទៅ មានខ្លះនៅសល់ខ្លះដែរ មានរស់ខ្លះ ប៉ុន្តែបើកាលចាប់នោះច្រើន ណាស់។ ប៉ុន្តែមើលទៅ បើបាត់ប្រហែលជាខ្ទង់ជាង៨០នាក់ ខ្សែខាំភួន ប៉ុន្តែនៅរស់ហ្នឹងប្រហែលជា តិចតួចទេ។ ដូចជា តាសាវ៉ាត ហ្នឹងក៏គេចាប់ដែរ តាកង អ៊ី ពួកប៉ាបាំងហ្នឹង អាកាំង ហ្នឹងក៏គេចាប់ដែរ ប៉ុន្តែបានរួចខ្លួន។ ឪពុកបង ទូយ មានក្នុងការស៊ើបក្ដីកាលមុននេះ ក៏បានមានឈ្មោះនៅក្នុងនេះដែរ ក៏គេ សម្លាប់ដែរ។ អ៊ីចឹងពួកគាត់ហ្នឹងសុទ្ធតែជាកម្មាភិបាលក្នុងចំណោមថ្នាក់ក្រោមៗហ្នឹង ជាប្រធានមន្ទីរ ជាស្ដី យោធា កងអនុសេនាតូច អនុសេនាធំ។ ហើយ វ៉ា ហ្នឹងជាអនុលេខាស្រុក។ អ៊ីចឹងទេគឺចាប់ វ៉ា ហើយចាប់ ឬឡៃ ៗគាត់ជាប្រធានពេទ្យ ៗតំបន។ ឬលី ក៏ពេទ្យតំបន់ដែរ ប៉ុន្តែគេឲ្យគាត់ ប្រហែលជា ក្រោយមក គេឲ្យគាត់ប្រចាំស្រុកកោះញែកហ្នឹង ជាប្រធានពេទ្យស្រុកកោះញែក ជាប្រពន្ធ តាស្វាយ។ អ៊ីចឹងខ្ញុំសូមជម្រាប់ថា ពេលនោះ--

**ស៖** *(គ្មានការបកប្រែ)*

**ឆ៖** ការសងសឹកគ្នានេះ មិនប្លែកទេ។ មិនចម្លែកទេ អ្នកណាក៏អាចសម្គាល់បានដែរ ព្រោះការ សងសឹកគ្នាគឺថា ខាំ ភួន គាត់វ៉ៃ តាហម ដោយសារកូនគាត់ តាហម សម្លាប់។ កូនគាត់គឺឈ្មោះ ខាំ។ មូលហេតុដែលដំបូងជាដំបូង កាស៊ី គេត្រូវចាប់។ ញ៉ុន នេះជាប្រធានមន្ទីររបស់ ខាំ ភួន។ ហើយ ញ៉ុន គាត់មើលទៅ មេរបស់គាត់ដែលយកគាត់បញ្ចូលបក្សនេះគឺ កាស៊ី មិនមែន ខាំ ភួន ទេ។ ពេល កាស៊ី គេ ចាប់ទៅ គាត់ត្រូវមានខ្លួនដែរ។ ធម្មតាខ្សែតែអ្នកណាចូលបក្សហើយ ពីណាអ្នកដឹកនាំចូលបក្សគឺអ្នក ហ្នឹងហើយ។ អ៊ីចឹងតែមេទៅហើយ គាត់មិនអាចនៅបាន គាត់រត់។ រត់នេះបើខ្ញុំនៅមន្ទីរហ្នឹងក៏ខ្ញុំគេ អាចយកខ្ញុំទៅដែរ មិនមែនតែ ញ៉ុន ម្នាក់ទៅទេ ព្រោះ ញ៉ុន ឲ្យនេះ ឈ្មោះ ប៊ុននឿន ទៅយកខ្ញុំនៅរយ៉។ ប៊ុននឿន អត់ទៅទេ ថាមិនបាច់ទេ កុំឲ្យវែងឆ្ងាយពេក យើងទៅតែយើងទៅ។ គេថា ញ៉ុន ថាយក ចូយ ទៅពីព្រោះ ចូយ ដឹងព្រៃ ដឹងផ្លូវ ដល់ ប៊ុននឿន ថាមិនបាច់ទេ។

[១០:០៥:៣៦]

**ស៖** លោកសាក្សីខ្ញុំសូមអភ័យទោស ខ្ញុំសូមកាត់សម្ដីលោក។ ខ្ញុំសោកស្ដាយដែលកាត់សម្ដី

លោកដូច្នេះ ដោយសារថាលោកឆ្លើយវែងពេក ហើយស្មុគស្មាញចំពោះខ្ញុំក្នុងការតាមលោកឲ្យទាន់។ អ៊ីចឹងខ្ញុំសូមឲ្យលោកឆ្លើយឲ្យបានខ្លីតាមដែលអាចធ្វើទៅបាន ហើយច្បាស់ៗ។ ហើយខ្ញុំដឹងថាលោកមានព័ត៌មានសំខាន់ៗច្រើនណាស់ អ៊ីចឹងខ្ញុំសូមព្យាយាមលម្អិតញែកតិចៗ។ លោកនិយាយថាមានការចាប់ខ្លួនដល់មនុស្សចំនួន៨០នាក់។ អ៊ីចឹងខ្ញុំសួរលោកថា នៅពេលដែលចាប់មនុស្ស៨០នាក់ហ្នឹង តើលោកធ្វើការនៅកន្លែងណា? លោកមានមុខតំណែងអ្វីដែរ? ហើយលោកពេលនោះលោកនៅរយ៉ ឬក៏លោក<នៅតែកាន់>មុខតំណែង<ពីមុនរបស់លោកនៅឡើយទេ>?

**ឆ៖** បាទ ខ្ញុំនៅរយ៉ដដែល។ ពេលហ្នឹងគេមកចាប់ដល់រយ៉ ព្រោះខ្សែខាំភួនហ្នឹង គឺតាចាន់ថន ចាប់គ្រួសារចាន់ថនហ្នឹង ៣០នាក់ដាក់លើឡានទៅ ជាង៣០នាក់ កូនគាត់គេចាប់បោះលើឡានបាក់ដៃបាក់ជើងអស់។ អ៊ីចឹងទេ អ្នកនៅអូរឫស្សីក្រោមនេះ គេចាប់ហូរហែទៅ។ បាទ អស់រលីងហើយ។

**ស៖** សូមអភ័យទោសសាក្សី ខ្ញុំកាត់ផ្តាច់លោកមួយសាទៀត។ ខ្ញុំសោកស្តាយណាស់ដោយសារពេលវេលាយើងខ្លី អ៊ីចឹងខ្ញុំសូមឲ្យលោកឆ្លើយសំណួរខ្ញុំឲ្យបានច្បាស់លាស់។ ខ្ញុំសួរលោកថាតើកាលនោះ លោកនៅធ្វើការនៅរយ៉<នៅឡើយទេឬ>? <>លោកឆ្លើយនឹងខ្ញុំហើយ អ៊ីចឹងមិនបាច់ឆ្លើយវែងឆ្ងាយទៀតទេ។ ខ្ញុំនឹងចោទសំណួរបន្តបន្ទាប់ទៀតទៅលោក <ប៉ុន្តែខ្ញុំចង់ទៅសន្សឹមៗ កុំលឿនពេកដូច្នេះហើយអ្វីៗនឹងច្បាស់សម្រាប់>អង្គជំនុំជម្រះហើយនិងភាគី។ កាលហ្នឹងលោកនៅ<ការដ្ឋាន>រយ៉ នៅពេលដែលគេបានចាប់ខ្លួនមនុស្សទាំង៨០នាក់នោះ។ អ៊ីចឹងតើលោកមានដឹងដែរឬទេ ថាតើអ្នកណាជាអ្នកផ្តើមចាប់មនុស្សទាំងអស់នោះ? ហើយបើលោកដឹង អ្នកណាជាអ្នកចេញសេចក្តីសម្រេចចាប់មនុស្សទាំងអស់នោះ? លោកឆ្លើយតែប៉ុណ្ណឹងបានហើយ លោកផ្តល់ឈ្មោះឲ្យខ្ញុំមក ប្រាប់ថាអ្នកណាអ្នកចេញសម្រេចឲ្យចាប់ទៅបានហើយ ហើយក្រោយមកខ្ញុំចោទសំណួរបន្តសួរលោកតទៅទៀត។

[១០:០៨:១០]

**ឆ៖** បាទ ការចាប់នេះគឺបន្ទាប់ពី ខាំ ភួន មក បន្ទាប់ពី ហាម វាអស់ៗមនុស្សហើយ។ អស់អ្នកធំ។ អ្នកមានសិទ្ធមានតែគាត់ទេ មាន តាសារុន ហើយនិងខាងទាហាន គឺមាន សុភា។ សុភា គេមិនទាន់ចាប់ទេ នៅពេលនោះ ឡុង, សុភា។ អ៊ីចឹងការចាប់នេះ យើងមិនដឹងថាសម្រេចមកពី តាសារុន ឬមកពីតាលក ប៉ុន្តែខ្ញុំគ្រាន់តែថា ដឹងពីខ្លះៗហ្នឹង គេជំនុំក្នុងគណៈកម្មាធិការរបស់គេហើយ មិនដែលម្នាក់បុគ្គលធ្វើបានទេ។ អ៊ីចឹងមុននឹងគេចាប់មនុស្ស មុននឹងគេធ្វើអ្វីមួយ អ៊ីចឹងក្នុងសមាជិកនៅសល់ទាំងប៉ុន្មានហ្នឹងគេប្រជុំ គេសម្រេចហើយ។ អ៊ីចឹងអ្នកណាធំជាងគេ យើងអាចសំដៅទៅលើថាគាត់ហ្នឹងក៏បានដែរ ឬ

មួយក៏ថាគណៈកម្មការគេហ្នឹងក៏បានដែរ។ បាទ សូមអស់។

**ប្រធានអង្គជំនុំ៖**

លោកសាក្សីយើងរំឭកម្ដងទៀតថា ទី១ គឺលោកសូមលោកឆ្លើយឲ្យបានច្បាស់លាស់ តបទៅនឹងសំណួរ ហើយដូចមេធាវីប្រាប់ហើយគឺឲ្យលោកឲ្យខ្លី។ ហើយទី២ ជៀសវាងលោកផ្ដល់សក្ខីកម្មបែបសន្និដ្ឋាន ឬក៏បែបស្មាន បានន័យថា សូមលោកផ្ដល់ជាក់លាក់នូវអ្វីដែលលោកដឹង បើលោកមិនដឹងទេចម្លើយតបមកវិញ ថាលោកមិនដឹងទេការងារនោះ។ នោះក៏ជាចម្លើយតបដែរ ជៀសវាងផ្ដល់សក្ខីកម្មដោយការស្មាន ឬក៏ការប្រហាក់ប្រហែល វាឥតប្រយោជន៍អ្វីជានាំឲ្យស្វែងទៅរកការពិតបានទេ។ បន្តទៀត!

[១០:១០:០៥]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកប្រធាន មុននឹងសម្រាក ខ្ញុំមានសំណួរមួយសូមការបំភ្លឺពីគាត់។ លោកសាក្សី លោកបាននិយាយអំពី តាសារុន ហើយនិង សុភា ហើយលោកក៏បានបញ្ជាក់ដែរថា កាលនោះលោកធ្វើការនៅការដ្ឋានរយ៉។ អ៊ីចឹងលោកអាចបញ្ជាក់បានដែរឬទេថា លោកមិនដឹងថាអ្នកណាជាអ្នកធ្វើសេចក្ដីសម្រេចនោះទេ គ្រាន់តែលោកសន្និដ្ឋានខ្លួនឯងតាមពាក្យចចាមអារ៉ាម តែប៉ុណ្ណឹងទេ? តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ ត្រឹមត្រូវ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ឥឡូវនេះបើលោកប្រធានចង់សម្រេចឲ្យពួកយើងសម្រាក អាចសម្រាកឥឡូវបានលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១១ នាទី ដល់ម៉ោង ១០:៣២ នាទី)*

[១០:៣២:៣២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សីឥឡូវនេះ ខ្ញុំសូមនិយាយអំពីមន្ទីរផ្សេងៗ ដែលលោកបានលើកឡើងក្នុងអំឡុងពេលលោកផ្តល់សក្ខីកម្មនេះ ហើយខ្ញុំចង់បានបញ្ជាក់<>ពាក់ព័ន្ធនឹងមន្ទីរក-១៦។ លោកថា មុនពេលដែលលោកទៅការដ្ឋានរយ៉ លោកត្រូវបានឃុំខ្លួនមួយរយៈពេលនៅក-១៦។ លោកអាចជម្រាបឲ្យបានច្បាស់បន្តិចបានទេថា តើមន្ទីរក-១៦ នេះជាមន្ទីរអ្វីដែរ? <> តើវាជាមន្ទីរអ្វីផ្សេង<ដែលក្រោយមកវាក្លាយទៅជាមន្ទីសន្តិសុខ> ឬវាមានតួនាទីត្រឹមតែជាមន្ទីរសន្តិសុខ<តាំងពីដើមមក>ទេ?

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ ក-១៦ មិនមែនជាមន្ទីរសន្តិសុខទេ គ្រាន់តែជាកន្លែងសេដ្ឋកិច្ច កន្លែងគេបង្កបង្កើនផល។ ហើយជាតួនាទីរបស់អនុប្រធានខេត្តនោះ គាត់តំណាងឲ្យ កាន់ខាងសេដ្ឋកិច្ចហ្នឹងគាត់គឺ តាខាំភួនហ្នឹងតែម្តង។

**ស៖** នៅក្នុងឯកសាររបស់លោកគឺ E3/5636, ERN ជាភាសាបារាំង 00727141, ERN ជាភាសាអង់គ្លេស00711226 និង ERN ជាភាសាខ្មែរ00042485។ លោកបាននិយាយអំពីមន្ទីរតាម៉ាន់។ <> តើ តាម៉ាន់ នេះជាអ្នកកាន់មន្ទីរបង្កបង្កើនផលមែនទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:៣៥:១៧]

**ឆ៖** អត់ទេ តាម៉ាន់ ឬក៏ តាមុំាង ដូចស្តាប់អត់បានបាទ?

**ស៖** សូមអភ័យទោសប្រសិនបើខ្ញុំអានឈ្មោះមិនច្បាស់។ គឺ តាម៉ាន់ –ម-៉-ា-ន-់– តាម៉ាន់គឺនៅឯកសារហ្នឹង លោកមើលទៅភាសាខ្មែរគឺ 00042485 ក្នុងហ្នឹងមានបញ្ជាក់ថា “មន្ទីររបស់តាម៉ាន់” ដូច្នេះខ្ញុំចង់ដឹងថា តាម៉ាន់ ហ្នឹងគាត់កាន់មន្ទីរហ្នឹង គឺមន្ទីរបង្កបង្កើនផលហ្នឹងមែនទេ?

**ឆ៖** បាទ ព្រោះ តាម៉ាន់ ដូចអត់មានឈ្មោះទេ បើ តាមុំាង មាន។

**ស៖** អ៊ីចឹង តាមុំាង ហ្នឹង ជាអ្នកណាចុះ?

**ឆ៖** បាទ តាមុំាង ជាទាហាន។ គាត់ជាទាហាន ហើយគាត់ជា ឋានៈគាត់ជាវរសេនាតូច ជាអនុវរសេនាតូច។

**ស៖** នៅក្នុងឯកសារដែលខ្ញុំបានដកស្រង់ហ្នឹងគឺ E3/5636 ហ្នឹង នៅERNដដែល លោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ “គេចាប់ផ្តើមចាប់ដំបូងនៅក-១៦ យកទៅដាក់សន្តិសុខតំបន់ ជាប់ <ក-១៦> កន្លែងមន្ទីរតាម៉ាន់ បានមួយយប់។ ព្រឹក<ថ្ងៃបន្ទាប់ គេ>យក<អ្នកទាំងនោះចេញ>ទៅ តែខ្ញុំមិនដឹងថាយកទៅណាទេ។” សូមបញ្ចប់ការដកស្រង់។--

**លោក ឌេល លីសាក់៖**

ប្រហែលជាបញ្ហាបកប្រែទេ នៅក្នុងភាសាអង់គ្លេស គឺមានអត្ថន័យដូចបែបនេះ៖ “ការចាប់ខ្លួនដំបូងនៅ ក-១៦ ហើយយកទៅដាក់មន្ទីរតំបន់នៅជិត ក-១១ មន្ទីរតាម៉ាន់<មួយយប់>។” អ៊ីចឹង<នៅក្នុងភាសាអង់គ្លេស ការចាប់ខ្លួន>គឺថា <មនុស្សនៅ ក-១៦ ប៉ុន្តែ>មន្ទីរតាម៉ាន់គឺនៅ ក-១១ ទេ។ ខ្ញុំមិនដឹងថា អត្ថបទដើមភាសាខ្មែរមានន័យដូចម្តេចទេ។

[១០:៣៨:១២]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អ៊ីចឹងដើម្បីឱ្យច្បាស់ គឺមានតែឱ្យលោកសាក្សីឆ្លើយបញ្ជាក់ត្រង់ចំណុចនេះ។ លោកអាចជម្រាបបានទេ តើមន្ទីរតាម៉ាន់ហ្នឹង នៅកន្លែងណា ក-១៦ ឬក៏ ក-១១?

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ តាមុំាង គាត់បន្ទាប់ពីមន្ទីរសន្តិសុខហ្នឹង គឺគាត់នៅជាប់គុកហ្នឹងតែម្តង និយាយឱ្យចំព្រោះក-១១ ហ្នឹង បូកជាមួយនឹង តាមុំាង ហ្នឹង សុភា ហ្នឹងនៅជាមួយគ្នាហ្នឹង គ្រាន់តែវាឆ្ងាយពីគ្នាវា

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ប្រហែលមួយរយពីររយម៉ែត្រហ្នឹង វាអត់មានឆ្ងាយប៉ុន្មានផងហ្នឹង។ អ៊ីចឹងគាត់នៅជាប់គុកហ្នឹងតែម្តង។ តាម៉ុង មិនមែន តាម៉ាន់ ទេ។ បើសរសេរឲ្យចំ ដាក់ "ម-៧ ឬក៏ ម-៧ំ-ង" តែម្តងទៅ ម៉ុង។

**ស៖** លោកនិយាយអំពីគុកអម្បាញ់មិញនេះ គុកហ្នឹងគុកអីដែរ? ហើយគុកហ្នឹង មានឈ្មោះអ្វីដែរ?

**ឆ៖** កាលជំនាន់ហ្នឹង គេហៅថា គុកភ្នំក្រោល។ គេអត់ដាក់ឈ្មោះអីផង ខ្ញុំអត់ចំណាំទេ។

**ស៖** ដូច្នេះលោកអាចជម្រាបបានទេ ថាខ្ញុំយល់ត្រឹមត្រូវទេថា នៅពេលដែលលោកនិយាយអំពីមន្ទីរតាម៉ាន់ ហ្នឹងគឺវានៅជាប់នឹងគុកហ្នឹងមែនទេ?

**ឆ៖** បាទ នៅជាប់នឹងគុកហ្នឹង។

[១០:៤០:១៥]

**ស៖** តើមន្ទីរហ្នឹងមានឈ្មោះអីពិសេសអីទេ?

**ឆ៖** បាទ ខ្ញុំអត់ៗចំណាំ អត់ស្គាល់ទេ ព្រោះជាកន្លែងទាហានគេ។

**ស៖** ដូច្នេះបើខ្ញុំយល់មិនច្រឡំទេ គុកភ្នំក្រោលនេះត្រូវបានគ្រប់គ្រងដោយពួកយោធា មែនទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** តាមរយៈចម្លើយមុនរបស់លោក ខ្ញុំយល់ថា តាម៉ាន់ ហ្នឹងមានឈ្មោះមួយទៀត ម៉ុង ដែលជាប្អូនរបស់ សារុន។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ អត់ត្រឹមត្រូវទេ។ តាម៉ុង ហ្នឹងហើយជាប្អូនរបស់ សារុន។ តាឡេង ៗគាត់អ្នកដទៃទេ។

**ស៖** ដើម្បីឲ្យច្បាស់ថាមិនមែនពីបញ្ហាបកប្រែនោះ គឺថានៅក្នុងសំណុំរឿង យើងបានដកស្រង់ហើយលោកក៏បានបញ្ជាក់ឆ្លើយច្បាស់ដែរ នៅក្នុងឯកសាររបស់លោកគឺ E3/5178, ERN ជាភាសាបារាំង <004034486>*(ស៊ីក)* និងបន្តទៅទំព័របន្ទាប់ទៀត, ERN ជាភាសាអង់គ្លេសគឺ 00274100, ERN ជាភាសាខ្មែរគឺ00197862។ លោកបាននិយាយអំពីមនុស្សជាច្រើន ក្នុងនេះលោកថា៖"តំបន់មណ្ឌលគិរី ឬតំបន់១០៥ បានបែកចែកជាផ្នែកនយោបាយ ឈ្មោះ ម៉ី អនុតំបន់ ជាអ្នកទទួលគ្រប់គ្រង។ ផ្នែកសន្តិសុខ និងផ្នែកយោធា គ្រប់គ្រងដោយ សុភា តាំងពីឆ្នាំ១៩៧០ ដល់ចុងឆ្នាំ១៩៧៨។ កន្លែងសន្តិសុខយោធានេះ ហៅថា ក-១១ ជាកន្លែងដែល សុភា ធ្វើការ។ ឈ្មោះ ម៉ុង ជាប្រធានកងវរសេនាតូចជាប្អូនបង្កើតរបស់ សារុន កាន់ក្តាប់ខាងគុក។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះខ្ញុំចង់ដឹងថា តើយើង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

និយាយឈ្មោះហ្នឹងដូចគ្នាមែនទេ ឈ្មោះ ម៉ុងហ្នឹងជាប្អូនរបស់ សារុន ហ្នឹង ដែលគាត់កាន់ខាងគុកហ្នឹង អ៊ីចឹងមន្ទីរគាត់ហ្នឹងគឺនៅជាប់នឹងគុកភ្នំក្រោលហ្នឹង មែនទេ?

[១០:៤៣:៥៦]

**ឆ៖** បាទ ជាប់។

**ស៖** ដោយសារលោកនិយាយថា គាត់កាន់ខាងគុក អ៊ីចឹងខ្ញុំចង់ដឹងថា តើមានអ្នកណាខ្លះទៀតដែលធ្វើការនៅគុកនោះ? ហើយបើលោកដឹង លោកដឹងតាមរបៀបណា?

**ឆ៖** ខ្ញុំអត់សូវច្បាស់ដែរទេ ព្រោះតាមដែលខ្ញុំធ្លាប់ដឹងហ្នឹង គ្រាន់តែថា គាត់នៅខាងទាហានទេ ប៉ុន្តែអ្នកកាន់គុកហ្នឹងគឺឈ្មោះ ផៃ ទេ ប៉ុន្តែមន្ទីរគាត់ហ្នឹង នៅជាប់គ្នាហ្នឹង។ តែខ្ញុំមិនដឹងថា គាត់ហ្នឹងមានតួនាទីនៅក្នុងគុកដែរឬអត់ទេ។ សូមជម្រាបអ៊ីចឹង។

**ស៖** នេះជាចម្លើយបន្តរបស់លោកតទៅទៀតនៅក្នុងឯកសារ E3/5178 នៅ ERN ដដែល។ លោកថា៖ "ផៃ ជាទាហានរបស់ ម៉ុង ហើយជាមេគុកភ្នំក្រោល"។ ដូច្នេះលោកនិយាយថា ម៉ុង ហ្នឹងជាប្អូនរបស់ សារុន ហ្នឹងកាន់ខាងគុក ហើយត្រួតពីលើមេគុកគឺឈ្មោះ ផៃ។ ក្នុងនេះលោកបញ្ជាក់ច្បាស់ថា ផៃ ជាកូនចៅរបស់ ម៉ុង។ អ៊ីចឹងខ្ញុំចង់ដឹងថាលោកបានព័ត៌មាននេះមកពីណា? ហើយតើ ផៃ នេះគាត់មានមុខងារអ្វីឲ្យប្រាកដនោះ?

**ឆ៖** បាទ បើតាមខ្ញុំដឹងហ្នឹង ផៃ គាត់គ្រាន់ជាប្រធានគុកទេ។ ឯចំណែកប្រមូលបានអ្នកទោសហ្នឹងគឺ តាម៉ុង ហ្នឹងហើយគាត់អ្នកដែលដែលគាត់ទៅតាមចាប់បានមក គាត់បញ្ជូនទៅគុកហ្នឹង គឺជូនឲ្យ ផៃ អ្នកគ្រប់គ្រងហ្នឹងតែម្តង។

**ស៖** សំណួរខ្ញុំគឺនៅតែដដែល។ តើលោកទទួលបានព័ត៌មាននេះមកពីណា?

[១០:៤៦:៣៥]

**ឆ៖** បាទ ជាការទម្លាប់ដែលឃើញកន្លងមកដែលខ្ញុំធ្លាប់ឃើញ វាមិនមែនជាអ្នកណាមកប្រាប់ឬក៏អ្នកណាទេ ជាការធ្លាប់ឃើញទេ។ ព្រោះ ម៉ុង គាត់ជាតួនាទីរបស់គាត់គឺដើរបោសសម្អាតអ៊ីចឹងឯងទៅត្រង់ណាក៏ឃើញមុខគាត់ដែរ។ ពេលទៅចាប់មនុស្ស ឃើញទាហានគាត់ទៅព្រោងព្រាតអ៊ីចឹងហើយ ប៉ុន្តែខ្លួនគាត់ជួនកាលមាន ជួនកាលអត់ទៅ។ កូនទាហានគាត់ពេញៗហ្នឹង។

**ស៖** ប្រសិនបើខ្ញុំយល់មិនច្រឡំទេ គឺថាលោកត្រូវបានឃុំនៅក-១៦មួយរយៈ ក្រោយមកគេបញ្ជូនលោកទៅរយ៉។ ដូច្នេះតើនៅពេលណាលោកឃើញ ម៉ុង ទទួលបន្ទុកខាងចាប់មនុស្ស? ហើយនៅ

ពេលណាដែលលោកឃើញ ផៃ ធ្វើជាមេគុកភ្នំក្រោលនោះ?

**ឆ៖** បាទ សូមទោស ត្រង់នេះខ្ញុំអត់បានឃើញទេ ប៉ុន្តែចំពោះអ្នកដែលដូចថារួចខ្លួនពីគុកហ្នឹង គាត់បាននិយាយប្រាប់ខ្ញុំដែរ។ អ៊ីចឹងខ្ញុំដឹងតាមរយៈគាត់ផងទេ។

**ស៖** ចំណុចនេះសំខាន់ណាស់។ នៅពេលដែលខ្ញុំសួររកប្រភពព័ត៌មានពីលោកនោះ ខ្ញុំចង់ដឹងថា តើលោកឃើញដោយខ្លួនឯងផ្ទាល់ភ្នែក ឬក៏មានអ្នកណាម្នាក់ប្រាប់លោក? ដូច្នេះខ្ញុំយល់ហើយ ឥឡូវនេះ ថាលោកមិនដឹងខ្លួនឯងទេ ថាភ្នំក្រោលនោះគេរៀបចំយ៉ាងម៉េច គឺអ្នកទោសទេដែលជាអ្នកប្រាប់លោក។ អ៊ីចឹងខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ តាមរយៈចម្លើយលោកអម្បាញ់មិញនោះ?

**ឆ៖** បាទ ត្រឹមត្រូវ។

[១០:៤៨:៥៣]

**ស៖** ដោយសារតែមានចំណុចមួយចំនួនដែលលោកស្តាប់ឮតាមពីពាក្យចចាមអារ៉ាម ឥឡូវនេះ ខ្ញុំចង់សួរពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកពាក់ព័ន្ធទៅនឹងមន្ទីរ<ឃុំឃាំង>ភ្នំក្រោល។ ខ្ញុំចង់ដឹងថា លោកដឹងទេថានៅពេលណាដែលគុកភ្នំក្រោលនេះត្រូវបានបង្កើតឡើង?

**ឆ៖** បាទ ខ្ញុំអត់ចំណាំដែរ ព្រោះស្រាប់តែចិត -- ព្រោះខ្ញុំនៅកែវសីមា ខ្ញុំអត់សូវដឹងរឿងគេធ្វើទេ។ ឃើញតែគេកាប់ឈើហ្នឹង ពេលដែលខ្ញុំទៅម្តងម្កាល ឃើញគេកាប់ឈើ នេះគេដុតជាចម្ការ។ ស្រាប់តែក្រោយមកឃើញគេធ្វើផ្ទះឃើញអីហ្នឹង ប៉ុន្តែមិនដឹងថាគុកផង។ ដល់ឆ្នាំដែលគេយកខ្ញុំមកដាក់ ក-១៦ហ្នឹង ខ្ញុំធ្លាប់ដើរកាត់តាមហ្នឹង ឬក៏ជិះឡានដែលគេនាំកាប់ឈើកាប់អីហ្នឹង ឃើញគេធ្វើគុកនៅហ្នឹង ប៉ុន្តែគុកហ្នឹងគេដាក់មនុស្សទៅហើយ។ ប៉ុន្តែមិនដឹងជាឆ្នាំប៉ុន្មានដែលគេដាក់ហ្នឹង ឬពី៧៥ ឬក៏៧៤ ប៉ុន្តែ ឃើញគេកាប់ហ្នឹងយូរដែរ ហើយគេនៅហ្នឹងក៏យូរដែរ។ អត់ដឹង សូមជម្រាប។

**ស៖** ទោះបីជាលោកមិនដឹងថា តើគុកនេះត្រូវបានសាងសង់ឡើងនៅឆ្នាំណាក៏ដោយ ក៏ប៉ុន្តែនៅ ពេលដែលលោកធ្វើជាអនុប្រធានមន្ទីរនោះ តើគុកនោះមានហើយឬនៅ? ឬក៏លោកធ្វើជាប្រធានមន្ទីរ ហើយ បានគុកហ្នឹងកើតមកតាមក្រោយទេ?

**ឆ៖** បាទ អង្កាល់ខ្ញុំធ្វើអនុប្រធានមន្ទីរនៅកែវសីមាហ្នឹង ខ្ញុំអត់ដឹង ព្រោះខ្ញុំនៅកែវសីមា អត់សូវ ដឹងកន្លែងគុកកន្លែងអីគេទេ។ ទើបនឹងដឹងពេលដែលគេចាប់មនុស្សច្រើន ពេលដែលខ្ញុំទៅនៅក្នុងក-១៦ ហ្នឹងទេ ខ្ញុំដឹង ចូលខែ២, ខែ៣ នេះហើយ។

**ស៖** ពេលលោកនិយាយថា ខែ២, ខែ៣ហ្នឹង លោកសំដៅឆ្នាំ១៩៧៧ មែនទេ?

**ឆ៖** បាទ។

[១០:៥១:៣៣]

**ស៖** តាមរយៈចម្លើយរបស់លោក ខ្ញុំយល់ថាលោកមិនដែលឈានជើងចូលទៅក្នុងមន្ទីរឃុំឃាំងភ្នំក្រោលហ្នឹងទេ តែលោកមើលឃើញពីចម្ងាយ មើលពីផ្លូវទៅ។ ដូច្នេះលោកអាចរៀបរាប់ដោយសង្ខេបអំពីទីតាំងហ្នឹងបានទេ? លោកមើលពីចម្ងាយទៅ មើលពីផ្លូវទៅ លោកឃើញអ្វីខ្លះដែរ?

**ឆ៖** បាទ មើលឃើញដំបូលផ្ទះ ប៉ុន្តែអត់ឃើញច្បាស់ទេ ព្រោះវានៅក្នុងទំនាបទៅល្បាក់ខាងទំនប់ទឹកណោះ ខាងទីធ្លាខាងមុខគេឈូសស្អាត យើងក្រឡេកមើលទៅឃើញ ប៉ុន្តែគេដាក់របងឫស្សីព័ទ្ធជុំវិញហ្នឹង មានតែប៉ុណ្ណឹង។

**ស៖** លោកថា គុកនេះនៅជិតទំនប់ លោកនិយាយអំពីទំនប់មួយណាដែរ?

**ឆ៖** កន្លែងហ្នឹងគេហៅថា ទំនប់សុទ ទំនប់កម្មករសុទ ហើយជាទំនប់ភ្នំក្រោលនោះតែម្តង។ សព្វថ្ងៃវាទៅជា នៅទំនប់ដដែលហ្នឹង។

**ស៖** លោកនិយាយថា ជាទំនប់ហ្នឹង ទំនប់ហ្នឹងជាទំនប់ធំដែលគេមានសង់ជាទ្វារទឹក ឬមានជញ្ជាំងមានអី ឬក៏គ្រាន់តែជាកូនទំនប់មួយតូចទេ?

**ឆ៖** បាទ ទំនប់ហ្នឹងវាលក្ខណៈមិនជាតូចពេកទេ អាចយើងធ្វើផ្លូវឡានរត់ខាងលើហ្នឹងហើយមានទ្វារទឹកត្រឹមត្រូវ។

**ស៖** លោកដឹងទេ ទំនប់នេះត្រូវបានសាងសង់ឡើងនៅឆ្នាំណាដែរ?

**ឆ៖** បាទ ទំនប់នេះសាងសង់ពី៧៤ មក៧៥, ៧៦ហើយ។

[១០:៥៤:៣៥]

**ស៖** លោកថាទំនប់នេះមិនជាតូចប៉ុន្មាន។ អ៊ីចឹងខ្ញុំចង់ដឹងថា តើទឹកហូរមកទំនប់ហ្នឹង ទឹកហ្នឹងមកពីខាងណាដែរ?

**ឆ៖** បាទ ទឹកទំនប់ហ្នឹង គឺហូរពីភ្នំទៅ ព្រោះវាក្នុងកន្លៀតភ្នំមួយដែលមានកូនអូរមកទល់ ៗនឹងភ្នំ ហើយយើងបិទពីក្រោមទៅ អ៊ីចឹងជុំវិញសងខាងហ្នឹងភ្នំតែម្តង គឺហៅភ្នំក្រោលហ្នឹងឯង។ អ៊ីចឹងអ្នកស្រុកនៅហ្នឹងគឺផឹកទឹកហ្នឹងឯង។

**ស៖** លោកថាទំនប់ហ្នឹងឈ្មោះ ទំនប់សុទ ឬទំនប់ភ្នំក្រោល។ អ៊ីចឹង សុទ ហ្នឹងជា គឺជាឈ្មោះអូរដែលនាំទឹកមកដល់ទំនប់ហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ សុទ ហ្នឹងជាឈ្មោះប្រធានកម្មករហ្នឹងទេ។

**ស៖** ចុះទឹកដែលហូរចេញពីកូនអូរ ដែលលោកថានៅពីភ្នំមកហ្នឹង លោកស្គាល់ឈ្មោះទេ កូនអូរហ្នឹងឈ្មោះអីដែរ?

**ឆ៖** បាទ អូរហ្នឹងតូចពេក ដូចជាអត់មានឈ្មោះផង បែបជនជាតិនៅស្រុកហ្នឹងបែបគេមានឈ្មោះគេ ប៉ុន្តែខ្ញុំអត់ស្គាល់ឈ្មោះទេ។

**ស៖** <ប៉ុន្តែ>លោកឯកភាពថាលោកជាអ្នកស្រុកកោះញែក <តើត្រឹមត្រូវទេ>?

**ឆ៖** បាទ ខ្ញុំជាស្រុកកោះញែក។

**ស៖** ហើយលោកស្គាល់ភូមិដែលជាទីតាំងមន្ទីរសន្តិសុខភ្នំក្រោល ដូច្នេះចន្លោះពីឆ្នាំ៧៥ ទៅដល់ឆ្នាំ៧៩ ពេលដែលលោកដើរកាត់តាមផ្លូវអីនោះ ឧទាហរណ៍នោះ លោកធ្លាប់ឮអ្នកភូមិ អ្នកស្រុកហ្នឹងហៅឈ្មោះអូរហ្នឹងទេ?

[១០:៥៧:៤៩]

**ឆ៖** បាទ គេហៅតែភ្នំ អូរភ្នំក្រោលៗ។ ហើយអូរហ្នឹងវាជាប្រឡាយតូចមួយ ដូចជាមិនមានកត់សម្គាល់អីផង។ ហើយគេបិទហ្នឹង បិទចំចង្កេះភ្នំតែម្តង។

**ស៖** លោកនិយាយអំពីដំបូលមន្ទីរភ្នំក្រោលហ្នឹង អ៊ីចឹងពីផ្លូវទៅហ្នឹងលោកមានមើលឃើញអគារ មើលឃើញអីទេ? គេសាងសង់យ៉ាងម៉េច? ហើយតើទ្រង់ទ្រាយ ឬក៏រចនាសម្ព័ន្ធភ្នំក្រោលនេះ គេរៀបចំសាងសង់យ៉ាងម៉េច មានធ្វើអំពីអីដែរ ពីឈើ ពីថ្ម?

**ឆ៖** បច្ចុប្បន្ននេះប្រជាជននៅពេញហ្នឹងពិបាកសន្និដ្ឋានដែរ ជួនកាលគេមាន ភាគច្រើនស្រុកហ្នឹងគេច្រើនធ្វើផ្ទះឈើ។

**ប្រធានអង្គជំនុំ៖**

និយាយពីអង្គាល់នុ៎ង កាលពេលនុ៎ង កាលៈទេសៈនោះ តើលោកបានដឹងបានឃើញដែរឬទេ ការសំណង់ហ្នឹង វាសង់យ៉ាងម៉េច? មិនមែននិយាយពីឥឡូវទេ និយាយពីរឿងកាលៈទេសៈនោះដែលលោកមាននៅហ្នឹង៧៧, ៧៨ នុ៎ង។

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ ជំនាន់នុ៎ង សូមជម្រាបដែរថា គ្មានផ្ទះធំដុំទេ គាត់ធ្វើផ្ទះស្បូវ ផ្ទះខ្ទមអីហ្នឹងតិចតួចហ្នឹង ហើយធ្វើតាមមន្ទីរ ដូចក-១១អ៊ីចឹង ក-១៧អ៊ីចឹង គេធ្វើផ្ទះតូចៗ ៥ម៉ែត្រគុណនឹង៤ម៉ែត្រអីអ៊ីចឹង

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទៅ ហើយគេធ្វើសាលាហ្នឹងក៏ធ្វើប្រក់ស្បូវទាំងអស់ហ្នឹង។ ដូចអត់ទាន់មានអីគួរឲ្យកត់សម្គាល់ទេ ដោយឡែកតែផ្ទះ តាហម ទេគាត់ធ្វើក្តារ ហើយខាងក្រោមហ្នឹងគាត់បានបូកស៊ីម៉ង់ត៍តិចតួច តែប៉ុណ្ណឹង ក្រៅពីហ្នឹងអត់មានអីគួរឲ្យអស្ចារ្យផង។

[១១:០០:១៣]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំស្តាប់ឮថា លោកនិយាយពីផ្ទះ តាហុង*(ស៊ីក)*។ <តើនោះជាអ្វីដែល>លោកហៅ <សំដៅទៅលើ>មន្ទីរសន្តិសុខភ្នំក្រោល<>មែនទេ?

**ឆ៖** បាទ សូមជម្រាបដែរ ព្រោះ តាហម គាត់នៅជិតហ្នឹងដែរ មានទៅឆ្ងាយប៉ុន្មាន។ អ៊ីចឹងដូចថាមួយជុំវិញហ្នឹង ប្រហែលជាបីបួនរយម៉ែត្រហ្នឹង គុកនៅក្បែងហ្នឹង ក-១១នៅក្បែរហ្នឹង ហើយក-១៧ នៅក្បែរហ្នឹងទៀត អ៊ីចឹងមួយជុំហ្នឹង ហើយឲ្យខ្ញុំរៀបរាប់យ៉ាងម៉េច? ខ្ញុំដូចជាអត់យល់ដែរ។ ព្រោះអ៊ីចឹងវាសភាពការណ៍នៅហ្នឹង គេដាក់កន្លែងជាទីរួមខេត្តរបស់គេ ហើយគេទើបតែបង្កើត មិនទាន់ ក-១៦ ហ្នឹងគេប្រុងនឹងលើកយកទៅដែរ ប៉ុន្តែមិនទាន់បានធ្វើទេ គេនៅដាក់កន្លែងអូរច្បារចាស់នោះ។ អ៊ីចឹងទេ នៅកន្លែងនេះ គេទើបនឹងរៀបចំធ្វើ។ អ៊ីចឹងផ្ទះហ្នឹងកំប៉ិកកំប៉ុក គេធ្វើនៅបណ្តោះអាសន្នអ៊ីចឹងទៅ។ បាទ សូមអស់។

**ស៖** លោកបាននិយាយអំពីផ្ទះតូចៗនៅជុំវិញ ក-១៦ និង ក-១១។ លោកថា ក-១១ និង ក-១៦ នេះ នៅជិតភ្នំក្រោល។ <លោកថា វាមានចម្ងាយពីគ្នាប្រហែល៣០០ម៉ែត្រ> អ៊ីចឹងមានន័យថា មន្ទីរក-១១, ក-១៦ ហើយនិងគុកភ្នំក្រោលហ្នឹងនៅក្នុងបរិវេណតែមួយមែនទេ? ព្រោះកាលពីម្សិលមិញហ្នឹង ខ្ញុំយល់ថា មន្ទីរសន្តិសុខភ្នំក្រោលនោះ មានរបងព័ទ្ធជុំវិញ។

[១១:០២:០៦]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអភ័យទោសដែលខ្ញុំកាត់។ អាចជាការកំហុសការបកប្រែ ប៉ុន្តែជាភាសាអង់គ្លេស<អ្វីដែលសាក្សី>និយាយ<គឺ> ក-១១ <និងក-១៧> មិនមែន<១៦> ក-១៧ ទេដែល<នៅ>ជិត<គុក>នោះ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<>។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំប្រហែលជាត្រូវបញ្ចាក់សំណួរខ្ញុំឡើងវិញ។

**ស៖** តើខ្ញុំយល់ត្រឹមត្រូវទេ តាមសក្ខីកម្មរបស់លោក ថានៅមិនឆ្ងាយពីមន្ទីរសន្តិសុខភ្នំក្រោល នោះមានមន្ទីរ ក-១១ និង ក-១៧ ឬក៏មានមន្ទីរ ក-១១ និង ក-១៦?

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ សូមជម្រាប។ មន្ទីរសន្តិសុខហ្នឹង ជិតបំផុតហ្នឹងគឺក-១១ ហ្នឹងហើយ។ ហើយក-១៧ ហ្នឹងទៅមុខបន្តិចទៀត ប្រហែលជា៥០០ម៉ែត្រទៀត។ ហើយនៅជុំហ្នឹង ខាងជើង ខាងត្បូងឆៀងត្បូង ហ្នឹង ខាងលិចឆៀងត្បូងហ្នឹងគឺកម្មករ កន្លែងគេផលិតគ្រឿងចក្រអីហ្នឹង គេមានម៉ាស៊ីនក្រឡឹង គេមានស្ពីគេទៅ គេអារឈើអារអីនៅហ្នឹង។ អ៊ីចឹងទេ ជុំវិញភ្នំក្រោលហ្នឹងគឺសុទ្ធតែទីតាំងរបស់គេ។ អ៊ីចឹងគុក ហ្នឹងគេដាក់ចំកណ្តាលតែម្តង។ ហើយជាប់អែបនឹងទំនប់ហ្នឹងតែម្តង ក្បែរទឹកទំនប់។ ឯចំណែក ក-១១ នេះ គាត់នៅត្រើយម្ខាង អូរច្បារខាងណោះ ប្រហែលជា២គីឡូទៅទៀត ទៅ២គីឡូកន្លះជាង។ អ៊ីចឹង ត្រូវឆ្លងទឹកទៀត មិនមែនជិតទេ។ សូមចប់។

**ស៖** ឥឡូវនេះខ្ញុំត្រឡប់មកសំណួរមុនរបស់ខ្ញុំវិញ។ កាលពីម្សិលមិញលោកនិយាយអំពីរបង ព័ទ្ធជុំវិញមន្ទីរសន្តិសុខភ្នំក្រោល។ ដូច្នេះខ្ញុំចង់ដឹងថា ក-១១ និង ក-១៧នេះ មានទីតាំងនៅក្នុងរបង ឬក្រៅរបងមន្ទីរសន្តិសុខភ្នំក្រោល?

**ឆ៖** បាទ នៅក្រៅទេ។

**ស៖** ខ្ញុំស្តាប់ឮថាក-១១ នេះស្ថិតនៅក្រោមបញ្ជារបស់ តាសុភា អ៊ីចឹងខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

[១១:០៥:០២]

**ស៖** អ៊ីចឹងខ្ញុំសួរដដែលទៀត ថាតើលោកបានប្រភពព័ត៌មាននេះមកពីណា?

**ឆ៖** ព័ត៌មាននេះមិនចាំបាច់ប្រភពទេ ព្រោះ ពូសុភា ក៏ជាសាច់ញាតិខ្ញុំដែរ ហើយមនុស្សភូមិ ផងរបងជាមួយ ធ្វើអីមួយក៏អាចដឹងបាន។ មិនបាច់ឆ្ងល់ទេ ព្រោះគាត់ដែលជាមួយម្តាយខ្ញុំគាត់ជិតស្និទ្ធ ណាស់ បងប្អូនរបស់គាត់។

**ស៖** នៅ ក-១៧ ហ្នឹង លោកដឹងថាអ្នកណាជាប្រធាន ក-១៧ នេះដែរឬទេ?

**ឆ៖** ក-១៧ គឺកន្លែងមន្ទីរតំបន់១០៥គឺ តាហម ហ្នឹងតែម្តង ប្រធានមន្ទីររបស់គាត់គឺឈ្មោះ ធិន បន្ទាប់មកទៀត ឈ្មោះ កាឡុយ។ ខ្ញុំស្គាល់តែប៉ុណ្ណឹងបាទ។

**ស៖** នេះលោកកំពុងតែនិយាយពីឆ្នាំណាដល់ឆ្នាំណាដែរនេះ ពាក់ព័ន្ធនឹងមន្ទីរ ក-១៧នេះ? <តើលោកដឹងថា មានអ្វី>ប្រែប្រួលដែរ<ទេនៅពេលក្រោយមក?>

**ឆ៖** បាទ ក-១៧នេះដំបូង គេដាក់នៅអូរឬស្សីក្រោម វាជិតនឹងក-១៦ទេ។ ដល់ពេលឆ្នាំ៧៥ក្រោយមក គេលើកទៅដាក់ភ្នំក្រោលហ្នឹង ហើយឯចំណែក ក-១៦នេះ គេមិនទាន់បានលើក។ អ៊ីចឹង ក-១៦ នៅកន្លែងចាស់ដដែល ក-១៧ គេលើកដាក់ទៅភ្នំក្រោល។ ហើយព្រមទាំង ក-១១ ហ្នឹង ហើយនិងមន្ទីរសន្តិសុខអីហ្នឹង គេធ្វើព្រមគ្នាក្នុងក្រោយ៧៥ មក។

**ស៖** ក៏ប៉ុន្តែសំណួរខ្ញុំខុសពីនេះ អម្បាញ់មិញនេះ។ ខ្ញុំចឹងដឹងថា តើនៅ ក-១៧ នេះ ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ហ្នឹង តើអ្នក<គ្រប់គ្រងទីនោះមានការផ្លាស់ប្តូរ>ដែរឬទេ? ឬក៏ថា ចាប់ពីពេលបង្កើត ក-១៧ ហ្នឹងមក រហូតដល់ពេលរបបកម្ពុជាប្រជាធិបតេយ្យនេះ ដួលរលំទៅហ្នឹង ប្រធាន ក-១៧ ហ្នឹងនៅតែជាមនុស្សដដែលទេ?

[១១:០៧:៥១]

**ឆ៖** បាទ ក-១៧ជាមន្ទីរ តាហម ហ្នឹង គឺដំបូងឡើយ តាំងពីណាពីណីហើយ តាធិន ហ្នឹងគាត់ជាប្រធានមន្ទីរនោះ។ ខ្ញុំបានស្គាល់គាត់ ហើយគាត់ក៏ជាបងថ្លៃខ្ញុំផង គាត់ទើបស្លាប់ឆ្នាំទៅដែរទេ។ ហើយកាឡុយ នេះក្រោយពីគាត់ខុសសីលធម៌ឆ្នាំ៧០ហើយនេះ ក្រោយពីគេសម្លាប់ កាស៊ី ហើយ ស្វាយហើយនេះ គាត់ក៏ខុសដែរ ក៏គេចាប់ទៅដាក់គុកហ្នឹងដែរ ហើយគេលែងគាត់វិញ ព្រោះគាត់អត់មានក្បត់ទេ គាត់គ្រាន់តែខុសសីលធម៌ ខូចជាមួយស្រីជាមួយអ៊ីចឹងទៅ គេចាប់គាត់ដាក់គុក ហើយជំនួសដោយកាឡុយ។ កាឡុយ នេះក្នុងឆ្នាំ៧៨ទេ។ អ៊ីចឹង កាឡុយ មិនទាន់បានប៉ុន្មានដែរ ឮថាយក កាឡុយ ទៅវៃចោលដែរ។ ខ្ញុំអត់ដឹងរឿងដែរ ព្រោះខ្ញុំដាច់អត់បាននៅហ្នឹងទេ ខ្ញុំដេកពេទ្យរហូត។

**ស៖** តាធិន ហ្នឹង ខ្ញុំឮអំមិញនេះ ដូចលោកនិយាយថា គាត់ជាបងថ្លៃរបស់លោក។ អ៊ីចឹងខ្ញុំចង់សួរលោកថា គាត់មានមុខតំណែងអ្វីជាក់លាក់ដែរ<នៅ ក-១៧> កាលសម័យនោះ?

**ឆ៖** បាទ ខ្ញុំដឹងគាត់តែត្រឹមតែប្រធានមន្ទីរ ខ្ញុំមិនដឹងគាត់មានការងារអីផង។

**ស៖** អ៊ីចឹង <តាភិន ទេ មិនមែន> តាធិន គេកែខ្ញុំអម្បាញ់មិញ។ ខ្ញុំមានសំណួរមួយសួរបន្ថែមទៀត លោកបានឆ្លើយថា លោកបានទៅដេកពេទ្យនៅពេលណាមួយ ហើយដោយអាស្រ័យហេតុហ្នឹង

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ហើយ បានលោកដឹងថា តាសារុន បានឡើងទៅជាលេខាស្រុក។ អានេះបើតាមខ្ញុំយល់។ អ៊ីចឹងតើលោកដឹងដែរឬទេថា តាសារុន មានតួនាទីអ្វីដែរ ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខភ្នំក្រោល?

[១១:១០:២៥]

**ប្រធានអង្គជំនុំ៖**

សំណួរដូចជាអាចច្រឡំមិនដឹង មិនមែនជាលេខាស្រុកទេ គាត់ឡើងជាលេខាតំបន់ណា។ ខុសគ្នាណា តំបន់ ហើយស្រុក ខុសគ្នាណា។ សួរច្របូកច្របល់អ៊ីចឹងទៅអាចស្ដាប់មិនបានទេ ព្រោះការសរុបអង្គហេតុហ្នឹងគឺអត់ស្ដាប់បានទេ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** សូមអភ័យទោសខ្ញុំច្រឡំ លោកប្រធាន។ លោកបាននិយាយថា តាសារុន ហ្នឹងបានឡើងជាលេខាតំបន់ នៅពេលដែលលោកទៅដេកពេទ្យ។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាតើ តាសារុន ហ្នឹងគាត់មានតួនាទីអ្វីដែរ ពាក់ព័ន្ធនឹងមន្ទីរភ្នំក្រោល? ប្រសិនជាលោកមិនដឹងទេ លោកគ្រាន់តែឆ្លើយថា មិនដឹងទៅបានហើយ។

**លោក ប៊ុន ឡឹងចូយ៖**

**ឆ៖** បាទ មិនដឹងទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ តែខ្ញុំសុំផ្ដល់វេទិកាទៅលោកមេធាវី គង់ សំអុន លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

[១១:១១:៤៨]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ។ សូមជ្រាបសួរលោកសាក្សី។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ដំបូងខ្ញុំចង់សួរលោកទាក់ទងទៅនឹងការវាយប្រហារគ្នា រវាងកងទ័ពកម្ពុជាប្រជាធិបតេយ្យ និងកងទ័ពវៀតណាម។ លោកបានឆ្លើយបញ្ជាក់ច្រើនគួរសមដែរហើយកន្លងមក។ តែខ្ញុំចង់សួរលោកឲ្យ

ច្បាស់ថា តើមុនឆ្នាំ១៩៧៥ បានន័យថា ក្រោយពេលជ័យជម្នះ -- សូមទោស មុនជ័យជម្នះ ១៧ មេសា ១៩៧៥ ហ្នឹង កងទ័ពរំដោះមានដែលប៉ះទង្គិចគ្នាជាមួយនឹងកងទ័ពវៀតណាមទេ ក្រុមណាក៏ដោយ?

**លោក ប៊ុន ឡឹងចួយ៖**

**ឆ៖** បាទ បើតាមខ្ញុំដឹង ប៉ះទង្គិចបីដងទេ គឺនៅកែវសីមាពីរដង នៅដាក់ដាំម្ដង។

**ស៖** បាទ ក្រែងលោលោកច្រឡំ។ អ្វីដែលខ្ញុំសួរនេះគឺមុនឆ្នាំ៧៥ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំឆ្លើយនេះ ឆ្លើយនៅក្រោយឆ្នាំ៧៥ទេ។

**ស៖** បាទ សូមអរគុណ។ សំណួររបស់ខ្ញុំសួរមុនឆ្នាំ៧៥ បានន័យថា អាចពី៧០ រហូតមកដល់ឆ្នាំ៧៥ហ្នឹង តើមានការប៉ះទង្គិចគ្នារវាងកងទ័ពរំដោះជាមួយនឹងកងទ័ពវៀតណាមដែរទេ? លោកអាចឆ្លើយបានទេ?

**ឆ៖** បាទ ពី៧០ មកដល់៧៥ បើតាមខ្ញុំដឹងអត់មានទេ។

[១១:១៣:៥០]

**ស៖** បាទ សូមអរគុណ។ លោកបញ្ជាក់មុននេះថា មានការប៉ះទង្គិចគ្នាបីដង ក្រោយ៧៥ហ្នឹង។ លោកបញ្ជាក់ថាដើមថា ក្នុងឆ្នាំ១៩៧៧។ ខ្ញុំចង់សួរបញ្ជាក់ទាក់ទងនឹងពេលវេលានេះ លោកដឹងច្បាស់ដោយផ្អែកលើអ្វីដែរ ដែលលោកចាំថាជាឆ្នាំ១៩៧៧នោះ?

**ឆ៖** បើតាមព័ត៌មាន ហើយនិងតាមការប្រកាសថា យើងបានវៃវៀតណាម ដោយសារវៀត-ណាមយើងដេញឲ្យចេញពីទឹកដី គេអត់ចេញ។ គេប្រកាសធ្វើ ការប្រកាសពេញមួយតំបន់ ដឹងតាមរយៈហ្នឹងបាទ។

**ស៖** លោកអាចបញ្ជាក់ច្បាស់បន្តិចបានទេថា ប្រកាសហ្នឹង ប្រកាសយ៉ាងម៉េច? តាមរយៈវិទ្យុ ឬក៏ការប្រជុំ ឬក៏មហាសន្និបាតអី?

**ឆ៖** បាទ គេប្រកាសតាមការប្រជុំនៅតាមអង្គភាពតូចតាចអីអ៊ីចឹង ព្រោះមេប្រធានហ្នឹងគេទទួលដំណឹងមក គេអាចរាយការណ៍ប្រាប់កូនចៅ ឬក៏បុគ្គលិកនៅក្នុងអង្គភាពហ្នឹង។

**ស៖** បាទ សូមអរគុណ។ លោកដឹងពីមូលហេតុទេ ថាមានហេតុផលអីដែលបណ្ដាលឲ្យមានការប៉ះទង្គិចគ្នាហ្នឹង?

**ឆ៖** បាទ ខ្ញុំដូចជាអត់យល់ទេ មិនអាចឆ្លើយបានទេ។

**ស៖** បាទ លោកអាចបញ្ជាក់បានទេ ថាកងទ័ពខាងវៀតណាមដែលប៉ះទង្គិចគ្នាហ្នឹងជាទ័ពអ្វី?

ជាកងទ័ពរបស់ខាងណា លោកអាចបញ្ជាក់បានទេ?

[១១:១៦:២១]

**ឆ៖** បាទ កងទ័ពហ្នឹង គឺកងទ័ពកុម្មុយនីស្ត អត់មែនកងទ័ពអាធីវទេ។

**ស៖** បាទ សូមអរគុណ។ លោកបញ្ជាក់ខាងដើមផងដែរថា ការប៉ះទង្គិចគ្នានេះ គឺនៅលើទឹកដីកម្ពុជា។ លោកអាចបញ្ជាក់បានទេ ថាលោកកំណត់បានថាជាទឹកដីកម្ពុជានេះ លោកដឹងដោយរបៀបណា ពីប្រភពណា ឬក៏អ្នកណាជាអ្នកប្រាប់លោកអំពីទីតាំងជាក់លាក់នេះ ថាការប៉ះទង្គិចគ្នានេះគឺនៅលើទឹកដីកម្ពុជា?

**ឆ៖** ខ្ញុំដឹងដោយសារទាហានម្នាក់ដែលគាត់ពិការ គាត់បានមកកាត់ជើងគាត់ដាច់ដោយសារជាន់មីន ពេលដែលទៅប្រយុទ្ធហ្នឹង គាត់បានដេកពេទ្យជាមួយខ្ញុំ គាត់ឧស្សាហ៍រៀបរាប់។ ហើយគាត់ប្រាប់ថា វៀតណាមហ្នឹងដោយសារយើងដេញប៉ុន្មានដងហើយអត់ទៅ អត់ព្រមដកឲ្យផុតពីទឹកដីយើងហ្នឹង ប្រហែលជា១គីឡូដីហ្នឹង អ៊ីចឹងគេវ៉ៃទៅ អាហ្នឹងលើកទី១។ ដល់លើកទី២ទៀត វ៉ៃនៅខាងកើតនេះ ខាងកងពលវ៉ៃ ដូចគ្នាដែរ មកជាប់អូរហ៊ុច។ ដល់អាទី៣នេះ មកវ៉ៃនេះគឺយើងទៅវ៉ៃនៅលើកំពូលភ្នំហ្នឹង គឺអាផ្លូវយើងហ្នឹងជាអ៊ីចឹង អាម្ខាងខាងនោះគេ ខាងណេះយើង អ៊ីចឹងគេមកនៅអាខាងយើងនេះ នៅអាកញ្ជ្រាញបន្តិចហ្នឹង ដែលជាដី៥០ម៉ែត្របួនជ្រុងត្រង់ហ្នឹង គេធ្វើបន្ទាយលើហ្នឹង យើងទៅវ៉ៃអាហ្នឹងទៀត។ អ៊ីចឹងពួកគាត់ហ្នឹងទៅវ៉ៃហ្នឹង បានជាជាន់មីនហ្នឹងដាច់ជើងទៅ ក៏កាត់ជើងដេកពេទ្យជាមួយខ្ញុំហ្នឹង ហើយគាត់រៀបរាប់ប្រាប់។ ខ្ញុំដឹងតាមរយៈគាត់ប្រាប់។

**ស៖** បាទ លោកអាចបញ្ជាក់បានទេថា ម្នាក់ដែលប្រាប់លោកហ្នឹងឈ្មោះអី? ហើយគាត់ចេញពីក្រុមកងទ័ពណា បានន័យថាក្នុងវរៈ ឬក៏ក្នុងកងពលណា លោកអាចចាំបានទេ?

[១១:១៨:៥៤]

**ឆ៖** បាទ គាត់ដំបូងគាត់ជាទាហានស្រុកកែវសីមាជាមួយខ្ញុំដែរ ក្រោយមកគាត់បានគេផ្ទេរមកឲ្យនៅតំបន់។ គាត់ជាទាហានតំបន់ទេ។

**ស៖** បាទ សូមអរគុណ។ អំមិញលោកមានប្រសាសន៍ថា ម្នាក់ហ្នឹងគាត់ត្រូវរបួសនៅសមរភូមិដោយសារជាន់មីន ៗរបស់អ្នកណា? ហើយសមរភូមិហ្នឹងសមរភូមិពេលណាដែរ លោកអាចបញ្ជាក់ឲ្យច្បាស់បានទេ?

**ឆ៖** បាទ មីននេះប្រហែលជាមីនដាក់ពីជំនាន់មុនៗ ទាំងមីនអាមេរិកាំង ទាំងមីនយៀកកុង

ទាំងមីនយើង វាមីនច្រើនណាស់ក្នុងតំបន់ហ្នឹង។ អ៊ីចឹងទេ មិនសន្និដ្ឋានថាមីនយួន ឬក៏មីនយើង ឬក៏មីនពីណាទេ ព្រោះដាក់វាច្រើនពេក ហើយយើងតែគេចបន្តិចត្រូវហើយ។ ហើយកន្លែងហ្នឹងគឺកន្លែងទាហាន ធីវ – ធីវ គី វានៅ វាបោះជំរំហ្នឹង ក៏វាបោះនៅកន្លែងហ្នឹងដែរ។ ដល់ពេលយៀកកុងមកទៀតក៏ដាក់នៅកន្លែងហ្នឹងទៀត។ អ៊ីចឹងទេដល់ក្រោយមកបានយើង ខាងយើងនេះខាងខ្មែរនេះ មិនចង់ឲ្យគាត់នៅកន្លែងហ្នឹង ព្រោះកន្លែងហ្នឹងជាកន្លែងចំព្រំប្រទល់។ ប៉ុន្តែគាត់មិនព្រមដកនៅហ្នឹង ហើយគាត់មកនៅឈរហ្នឹង គាត់ឈរនៅខាងផ្លូវខាងក្នុងនេះ អ៊ីចឹងទេ យើងទៅវាយកន្លែងហ្នឹង។ អ៊ីចឹងដូច សូមទោសដូចលោកមេធាវីគាត់សួរខ្ញុំម្សិលមិញថា គេមកវាយយើង ឬយើងវាយគេ ត្រង់នេះវាអ៊ីចឹងឯង។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងហ្វុលរ៉ូ លោកបានឆ្លើយតាំងពីម្សិលមិញដែរ ខ្ញុំចង់សួរលោកថា តើលោកដឹងពីគោលបំណង ឬក៏បេសកកម្មរបស់ហ្វុលរ៉ូហ្នឹងទេ? ដើម្បីអ្វីដែរ ហ្វុលរ៉ូហ្នឹង?

[១១:២១:០៧]

**ឆ៖** បាទ ហ្វុលរ៉ូ គាត់ជាជនជាតិភាគតិចរបស់វៀតណាមទេ។ តែគោលបំណងរបស់គាត់ ខ្ញុំអត់ដឹងទេ ពីព្រោះគាត់និយាយថា គាត់ទាមទារទឹកដីចម្ប៉ាររបស់គាត់តែប៉ុណ្ណោះ ដោយសារវៀតណាមឈ្លានពានយកទឹកដីគាត់។ មានតែប៉ុណ្ណឹង ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ លោកស្គាល់មេដឹកនាំហ្វុលរ៉ូហ្នឹងទេ ទោះជាមេដឹកនាំធំ ឬក៏មេដឹកនាំនៅក្នុងតំបន់ នៅក្នុងខេត្តដែលលោកបញ្ជាក់ថាមានមូលដ្ឋានពីរ គឺនៅរតនគិរី និងមណ្ឌលគិរី?

**ឆ៖** បាទ ពីមុនស្គាល់ម្នាក់ពីរនាក់ដែរ ប៉ុន្តែឥឡូវតាហ្នឹងគាត់ស្លាប់បាត់ហើយហ្នឹង គាត់ជាប្រធានវរៈប្រចាំការនៅឆ្នាំ៦៧, ៦៨ នៅខេត្តមណ្ឌលគិរី នៅភ្នំដោះក្រមុំហ្នឹង។ ឥឡូវគាត់ស្លាប់ហើយគាត់ជាជនជាតិភាគតិចដែរ។

**ស៖** បាទ សូមអរគុណ។ លោកចាំថា សកម្មភាពខាងហ្វុលរ៉ូគេធ្វើអ្វីខ្លះទេ នៅពេលហ្នឹង? ជាពិសេសគឺនៅទសវត្សរ៍៧០ អាចពី៧០ មកដល់៧៥ រហូតដល់៧៩ ហ្នឹង។

**ឆ៖** បាទ ខ្ញុំដូចជាមិនសូវច្បាស់ដែរ ព្រោះខាងគេហ្នឹងយើងដូចអត់មានប្រតិកម្ម ឬក៏មានហេតុការណ៍ដើម្បីប្រឆាំង ឬក៏ទប់ស្កាត់អី ដូចអត់មានអីសោះ។ អ៊ីចឹងទេខ្ញុំអត់យល់។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសួរអ៊ីចេះមួយទៀត តើលោកដឹងពីហ្វុលរ៉ូហ្នឹងនៅឆ្នាំណា? ពាក្យថា “ហ្វុលរ៉ូ” ឬក៏ “ក្រុមហ្វុលរ៉ូ” នៅឆ្នាំណាដែលលោកបានដឹងដំបូង?

**ឆ៖** បាទ ហ្វុលរ៉ូ បើតាមខ្ញុំដឹងដែលគេនិយាយប្រាប់តៗគ្នា ឬក៏ពួកគេហ្នឹងមកជួបយើងអ៊ីចឹង

ទៅ ខ្ញុំដឹងពីឆ្នាំ៧៦ --អំ ៦៦ ពីឆ្នាំ១៩៦៦មក។ ពីមុនមកអត់ដឹងថាស្គាល់ហ្វុលរ៉ូម៉េចទេ តែគ្រាន់តែដឹងថាហ្វុលរ៉ូហ្នឹង មិនដឹងជាទាហានខាងណា អត់ដឹង។

[១១:២៤:០៦]

**ស៖** បាទ សូមអរគុណ។ លោកមានដឹងពីសកម្មភាពខាងហ្វុលរ៉ូហ្នឹង មានទំនាក់ទំនងជាមួយកម្មាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យដែរទេក្នុងតំបន់ ជាពិសេស នៅក្នុងតំបន់មណ្ឌលគិរីរបស់លោកនោះ?

**ឆ៖** បាទ អត់ដឹងទេ ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសួរលោកទាក់ទងទៅនឹងតួនាទីរបស់លោកបន្ថែម ជាពិសេសគឺទាក់ទងទៅនឹងតួនាទីជាអនុប្រធានមន្ទីរស្រុក។ លោកបានបញ្ជាក់រួចហើយ លោកមានការងារពីរសំខាន់ គឺអាចដឹក មើលការដឹកប្រឡាយទំនប់ និងទី២ និងធ្វើស្រែ ដឹកនាំការធ្វើស្រែ។ ហើយដែលការងាររបស់លោក គឺផ្ទាស់គ្នាជាមួយនឹងប្រធានមន្ទីរ។ ខ្ញុំចង់សួរលោកថា តើមានប្រជាជនចំនួនប៉ុន្មាននាក់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោក ក្នុងឋានៈជាអនុប្រធាន ឬក៏ប្រធានមន្ទីរស្រុកនេះ?

**ឆ៖** បាទ បើខ្ញុំមិនភ្លេចទេ គឺខ្ញុំមានតួនាទីដឹកនាំតែអង្គភាពរបស់ខ្ញុំទេ ចំណែកខាងមូលដ្ឋានគឺភូមិឃុំគេ ប្រធានភូមិ ប្រធានឃុំ ប្រធានសហករណ៍គេអ្នកគ្រប់គ្រង តែសហការជាមួយខ្ញុំដែរ។ គ្រាន់តែថាយើងសហការគ្នាមេ ខាងមេឃុំហ្នឹងត្រូវមកជួបខ្ញុំ ៗជួបគាត់ទៅនិយាយពីរឿងលើកផែនការត្រូវធ្វើយ៉ាងម៉េចៗ រៀបជើងទំនប់របៀបម៉េច ឬក៏យើងធ្វើម៉េចអាហ្នឹងមានការសហការគ្នា។ តែប៉ុណ្ណឹង។

**ស៖** បាទ សំណួររបស់ខ្ញុំទាក់ទងទៅនឹងចំនួនប្រជាជនដែលលោកគ្រប់គ្រង ជាពិសេសលោកបានឆ្លើយអម្បាញ់មិញថា នៅក្នុងអង្គភាពរបស់លោក អ៊ីចឹងខ្ញុំចង់ដឹងថា តើអង្គភាពរបស់លោកហ្នឹងមានចំនួនប្រជាជនប៉ុន្មាននាក់ដែលលោកគ្រប់គ្រង?

[១១:២៦:៣៥]

**ឆ៖** បាទ នៅអង្គភាពខ្ញុំហ្នឹងតិចតួចដែរទេ ព្រោះគិតទៅប្រហែលជាជាង៣០នាក់ទេ អង្គភាពខ្ញុំ ចែកទៅខាងណោះ១៥នាក់ នៅខាងណេះ១៥នាក់។ ឬវាច្រើនក្មេង ហើយពួកគាត់ហ្នឹងមានប្រពន្ធកូនហ្នឹង វាច្រើនក្មេង គិតទៅបើសរុបទាំងក្មេងទាំងចាស់ ចូល៥០ប្លាយនាក់ដែរ។ ប៉ុន្តែបើដល់កម្លាំងពលកម្មមានតិចទេ ប៉ុន្តែនៅឃុំដែលខ្ញុំនៅហ្នឹងគឺគេហៅឃុំខ្ញុំមានប្រជាជនសរុបទាំងអស់២០០នាក់ហ្នឹង អត់មានច្រើនផង ប្រហែលជាសាមសែសិបគ្រួសារ។

**សៈ** បាទ សូមអរគុណ។ លោកបានឆ្លើយខាងដើមផងដែរទាក់ទងទៅនឹងលោក កាស៊ី។ លោកបានបញ្ជាក់ថា លោក កាស៊ី នេះមានទំនាក់ទំនងជាមួយវៀតកុង។ ខ្ញុំចង់ដឹងថា តើលោកដឹងដោយរបៀបណាពីទំនាក់ទំនងនេះ?

**ឆៈ** បាទ កន្លែងនេះ ខ្ញុំសូមនិយាយពីដើមមកវិញ មិនអាចនិយាយចុងបានទេ ព្រោះវាមានហេតុផលទាក់ទងជាមួយនឹង តាឡាំង, តាខាំភូន។ ដំបូងគាត់ទៅ ៗបានទំនាក់ទំនងជួបជាមួយនឹងគណៈភូមិភាគយួនឈ្មោះ តាទុង គឺ តាហម ហ្នឹងគាត់ប្រជុំតែខ្លួនគាត់ទេ។ ពួកខ្ញុំហ្នឹងនៅក្រៅទាំងអស់ ហើយខ្ញុំធ្វើចុងភៅ ហើយវៀតណាមពីរនាក់ជានីរសារ ជាយុទ្ធជនគេហ្នឹងមកសហការជាមួយខ្ញុំបានធ្វើសាច់ជ្រូកមួយ ធ្វើ*ប៊ីស្ទីក* ធ្វើអីឲ្យគាត់ហូប។ ពេលហ្នឹងការប្រជុំរបស់គេដឹងម៉េច ស្រាប់គេដាក់ផែនការ គេថា "ក្នុងថ្ងៃប៉ុណ្ណោះ ខែប៉ុននេះខ្ញុំនឹងមកទៀត"។ ដល់មកទៀត ពេលនុំងគាត់អត់មកទេ គាត់ឲ្យ តាខាំភូនមក។ ដល់ពេល តាខាំ ភូន មក តាខាំ ភូន និយាយទៅជួបគេហ្នឹង ពួកយើងជាយុទ្ធជនហ្នឹងនៅក្រៅទេ ហើយយើងអ្នកអង្គរក្សហ្នឹង យើងយាមនៅក្រៅអ៊ីចឹងទៅ គេចូលទៅប្រជុំក្នុងជាមួយយួនទៅ។ ដល់ពេលហ្នឹងគេប្រាប់ឲ្យខ្ញុំហ្នឹងមកយកឡានទៅពីខេត្តក្រចេះ ដឹកអីវ៉ាន់ហ្នឹង។ ក្នុងពេលដែលពួកខ្ញុំមកហ្នឹងគឺមានម៉ូតូពីរគ្រឿង ជិះម៉ូតូមក ៗដល់នេះប្រាប់ឲ្យឡានទៅ លើកឡានហ្នឹងដាក់លើម៉ូតូ ជិះទៅតាមផ្លូវស្នួលនេះ។ ហើយអង្កាល់ហ្នឹងក៏ជិះទៅដល់ ក៏យួនបានឲ្យជាកាំភ្លើង ឲ្យថ្នាំពេទ្យ ឲ្យជាក្រណាត់អីខ្លះ តាមដែលខ្ញុំដឹងមានស្បែកជើង មានកៅស៊ូ ក្រណាត់កៅស៊ូអី ជារបស់ទ័ពទេ។ ហើយបន្ទាប់មកទៀត ពួកគាត់អត់មកទេ អ៊ីចឹងគាត់ឲ្យ កាស៊ី នេះជួបដូចថាសហការបន្ត។ ការសហការបន្តនេះ ក៏អត់មានសិទ្ធិសម្រេចអីទេ គ្រាន់តែថាជួប បានតែព័ត៌មាន និងផ្ដល់ឲ្យខាងគាត់តែប៉ុណ្ណោះ។ អ៊ីចឹងខ្ញុំនៅស្រុកហ្នឹងដែលខ្ញុំធ្វើនីរសារជាមួយគាត់ហ្នឹង គឺខ្ញុំដឹងប៉ុណ្ណឹង។

[១១:៣០:០៣]

**សៈ** បាទ សូមអរគុណ។ លោកអាចបញ្ជាក់កាលបរិច្ឆេទបានទេ ថាក្នុងឆ្នាំណាខែណាដែរ នៅពេលដែលមានការជួបគ្នាបែបហ្នឹង?

**ឆៈ** បាទ តាមខ្ញុំមិនភ្លេចទេគឺក្នុងឆ្នាំ៧៥ តាំងពីដើមឆ្នាំ៧៥ មកដល់ថ្ងៃរំដោះ ១៧ មេសា ហ្នឹងតែម្ដង។ ក្នុងពេលរំដោះ ១៧ មេសា នេះខ្ញុំនៅស្រុកយួននៅឡើយ ព្រោះខ្ញុំទៅជ្រុលទៅនុំងទៅដើម្បីកៀងគរប្រជាជនមកវិញ ប្រជាជនដែលរត់ទៅវៀតណាមហ្នឹង ទាំងកាស៊ី ទាំងខ្ញុំ ទាំងអនុប្រធានគាត់ចិន្ដា ហើយមេបញ្ជាការទាហានស្រុកហ្នឹង ឈ្មោះ តាឡឺយ ហ្នឹងក៏ទៅជាមួយដែរ ព្រមទាង ខាំ ភូន។ ខាំ

ភូន គាត់ទៅជូនដល់ភូដូប គាត់ប្រញាប់មកវិញ ទុកឲ្យពួកខ្ញុំហ្នឹងទៅជួបប្រជាជន។ ពេលទៅជួបប្រជាជន ប្រជាជនឆ្លើយថា ពួកខ្ញុំអត់មានភ្លេចអីនៅកម្ពុជាទេ ពួកខ្ញុំមកនេះគ្រប់គ្រាន់ហើយ ពួកខ្ញុំមិនបាច់ត្រឡប់ទៅក្រោយទេ។ អ៊ីចឹងក៏អត់បានដែរ ប្រជាជនដែលខ្ញុំទៅយកហ្នឹង អត់បានម្នាក់សោះ មកវិញទទេ។ អ៊ីចឹងពេលហ្នឹង រំដោះ ១៧ មេសា ហ្នឹង ខ្ញុំនៅក្នុងស្រុកយួនទេ។ សូមអរគុណ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីទំនាក់ទំនងណាមួយដែលអាចឲ្យលោកចូលទៅក្នុងទឹកដីខាងវៀតណាមហ្នឹង ហើយទៅឃោសនា ឬក៏អូសទាញយកប្រជាជនត្រឡប់មកវិញហ្នឹង លោកអាចបញ្ជាក់បានទេ?

[១១:៣១:៤៨]

**ឆ៖** បាទ កន្លែងនេះ គឺខាងវៀតណាមទេ ភាគីវៀតណាម គេថា ប្រជាជនពួកលោកចូលមករស់នៅទឹកដីពួកខ្ញុំ បើពួកលោកត្រូវការប្រជាជនទៅវិញ សូមពួកលោកទៅយកគេមកវិញចុះ ពួកខ្ញុំអត់មានបញ្ហាទេ។ ប៉ុន្តែអត់មាន យើងមិនអាចធ្វើរបៀបបង្ខិតបង្ខំទេ បើគេស្ម័គ្រចិត្តមក ពួកខ្ញុំនឹងមានលទ្ធភាពអាចដឹកជញ្ជូនជូន។ ពួកខាងវៀតណាម គេថាអ៊ីចឹង។ ហើយពួកខ្ញុំទៅហ្នឹង ទៅដើម្បីសួរទឹកចិត្តគេហ្នឹងគេចង់មក ឬអត់? ដល់ពេលគេឆ្លើយថា គេអត់មានភ្លេចអីនៅកម្ពុជាទេ គេថាគេមកហ្នឹងគ្រប់គ្រាន់ហើយ។ អ៊ីចឹងគេអត់វិលមកទេ ក្នុងពេលនោះ។ អ៊ីចឹងមុនថ្ងៃ១៧ មេសា ប្រហែលថ្ងៃ១៣, ១៤ ខ្ញុំនៅប៊ូយ៉ាម៉ាប់ ហ្នឹងកំពុងតែជួបពួកប្រជាជនហ្នឹងឯង។

**ស៖** បាទ សូមអរគុណ។ លោកមានដឹងពីសកម្មភាពអីផ្សេងទៀតដែល តាកាស៊ី មានទំនាក់ទំនងជាមួយខាងវៀតណាម នៅពេលក្រោយទៀតទេ?

**ឆ៖** បាទ ខ្ញុំដូចជាមិនភ្លេចទេ គឺចាប់តាំងពីហ្នឹងមករហូតដល់ពេលគេចាប់ខ្លួនគាត់ អត់ដែលទៅជួបវៀតណាម ហើយក៏មិនដែលឡើងទៅហ្នឹងដែរ ចប់ត្រឹមហ្នឹងបណ្ដោយ។ ពេលមកវិញ គឺចប់តែម្ដង។ ចប់ហើយពេល មកវិញដឹងថាកម្ពុជាយើងបានរំដោះទាំងស្រុងហើយ ដល់ខែប៉ុន្មានទេ ខែ៦ កាលនោះ ១៧ មេសា ដល់ខែ៦ហ្នឹង ខាងនេះហៅចៅហ្វាយស្រុកហ្នឹងមកប្រជុំនៅភ្នំពេញទាំងអស់ ទូទាំងប្រទេស។ អ៊ីចឹងខ្ញុំអត់បានមកទេ ព្រោះខ្ញុំបានកាន់អនុប្រធានមន្ទីរហើយ ខ្ញុំឲ្យនីរសារគាត់រើសថ្មីហ្នឹងមកតាមគាត់។ អ៊ីចឹងខ្ញុំអត់បានដឹងរឿងទេ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

[១១:៣៤:០៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអរគុណលោក ប៊ុន ឡឹងចូយ សវនាការស្ដាប់សក្ខីកម្មរបស់លោក ក្នុងឋានៈជាសាក្សីបានដល់ទីបញ្ចប់ហើយ។ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្ដីនេះ។ នាពេលនេះ វត្តមានរបស់លោកនៅអ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្ដីសុខ សេចក្ដីចម្រើន។

អង្គជំនុំជម្រះក៏សូមអរគុណផងដែរ លោកស្រី សុក សុជាតា មេធាវីប្រឹក្សាសាក្សី។ នាពេលនេះលោកស្រីអាចសម្រាកបានហើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ប៊ុន ឡឹងចូយ វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ ហើយនៅរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សាក្សីដែលមានរហស្សនាម 2-TCW-1012 តាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្តឧត្ដរមានជ័យ។ ហើយនាពេលនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោង មួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៥ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៤២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃរសៀលនេះ អង្គជំនុំជម្រះនឹងផ្ដើមធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1012 តាមរយៈប្រព័ន្ធ

សោតទស្សន៍ពីខេត្តឧត្តរមានជ័យ។ ហើយមុននឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី អង្គជំនុំជម្រះ ខ្ញុំសូមជម្រាបជូនដំណឹងដល់ភាគីនៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះថា សវនាការនៅថ្ងៃនេះ នឹងអាចនៅសវនាការបន្តបន្ទាប់ក្នុងសប្តាហ៍នេះ លោកចៅក្រម យូរ ឧត្តរា ដែលជាចៅក្រមជាតិលោកអវត្តមាន ដោយមូលហេតុគាត់មានធុរៈចាំបាច់ផ្ទាល់ខ្លួន មិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការបាន។ ហើយបន្ទាប់ពីយើងខ្ញុំបានពិគ្រោះយោបល់ជាមួយនឹងបណ្តាចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងលោកចៅក្រម ធូ មណី ដែលជាចៅក្រមបម្រុងខាងភាគីជាតិជំនួសកន្លែងចៅក្រម យូរ ឧត្តរា ដែលបានអវត្តមាន រហូតដល់ពេលណាចៅក្រម យូរ ឧត្តរា មានវត្តមាន និងមានលទ្ធភាពអាចចូលរួមបំពេញការងារនៅក្នុងដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងវិញបាន។ ការសម្រេចនេះ ផ្អែកលើមូលដ្ឋាននៃបទប្បញ្ញត្តិវិធាន៧៩(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

សួស្តីលោក ញ៉ែម សំណាង។ លោកបានរៀបចំនូវប្រព័ន្ធសោតទស្សន៍--

[១៣:៣៤:២៦]

**លោក ញ៉ែម សំណាង៖**

សួស្តីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សោតទស្សន៍រួចរាល់ហើយឬនៅ?

**លោក ញ៉ែម សំណាង៖**

បាទ លោកប្រធាន ប្រព័ន្ធសោតទស្សន៍ បានរៀបចំរួច ហើយសាក្សី ហើយលោកមេធាវី មឿន សំម៉ាម -- មឿន សុវណ្ណ បានរៀបចំរួច លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណៗ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី។ តើលោកបានត្រៀមខ្លួនរួចហើយឬនៅលោកសាក្សី?

**លោក សៅ សារុន៖**

**ឆ៖** ត្រៀមរួចហើយ។

[១៣:៣៥:០៨]

**ស៖** បាទ អរគុណ។ ហើយជាដំបូងនេះ យើងសូមសួរអំពីព័ត៌មានបញ្ជាក់អំពីអត្តសញ្ញាណរបស់លោក ដោយសារសវនាការលើកមុនហ្នឹងយូរហើយ ឥឡូវហ្នឹងសូមបញ្ជាក់សាជាថ្មី។ តើលោកឈ្មោះអី លោកសាក្សី?

**ឆ៖** លោក សៅ សារុន។

**ស៖** អរគុណលោក សៅ សារុន។ ហើយតើលោកមានដែលមានប្រើឈ្មោះអីផ្សេងពីក្រៅសារុន នេះដែរឬទេ?

**ឆ៖** អត់។

**ស៖** លោកកើតនៅថ្ងៃ ខែ ឆ្នាំណា លោកចាំដែរទេ លោក សៅ សារុន?

**ឆ៖** អត់ចាំទេ លោក។

**ស៖** ឆ្នាំនេះ លោកអាយុប៉ុន្មានហើយ?

**ឆ៖** ខ្ញុំប្រហែលៗទេ ចា៩០ជាងហើយ ៩២។

**ស៖** លោកមានទីកន្លែងកំណើតនៅកន្លែងណា លោក សៅ សារុន?

**ឆ៖** នៅភូមិកោះម្បើល ឃុំពាមជីមៀត ស្រុកកោះញែក ខេត្តមណ្ឌលគិរី។

**ស៖** បាទ អរគុណលោក សៅ សារុន។ ហើយសូមលោកក្រោយពេលស្ដាប់សំណួរ លោកបង្អង់បន្តិច ដើម្បីឲ្យការបកប្រែភាសាហ្នឹងបានល្អពេញលេញណា ហើយសូមលោកឆ្លើយតប។ ចុះទីលំនៅសព្វថ្ងៃ តើលោករស់នៅទីកន្លែងណា?

**ឆ៖** នៅភូមិថ្នល់កែង ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

[១៣:៣៥:៥១]

**ស៖** បាទ អរគុណ។ ហើយលោកមានប្រកបមុខរបរអីដែរទេ សព្វថ្ងៃនេះ ឬក៏ជាមន្ត្រីចូលនិវត្តន៍ហើយ?

**ឆ៖** ចូលនិវត្តន៍ហើយ។

**ស៖** ឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតលោកឈ្មោះអី?

**ឆ៖** ឪពុកបង្កើត សៅ នូ។ ម្ដាយឈ្មោះ ប្រង។

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធទាំងស្លាប់ទាំងនៅរស់ ទាំងអស់១០នាក់។

**ស៖** ចុះប្រពន្ធៗរបស់លោកឈ្មោះអី?

**ឆ៖** ឈ្មោះយន់ – ផក់ យន់។

**ស៖** លោក សៅ សារុន តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោកខៀវ សំផន និងបុគ្គលទាំងឡាយដែលត្រូវបានទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដី០០២នេះទេ។ តើរបាយការណ៍នេះពិតជាត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ពិតត្រឹមត្រូវ អត់មានពាក់ព័ន្ធអីជាសាច់ញាតិបងប្អូនទេ។

[១៣:៣៨:២៨]

**ស៖** ហើយថាលោកបានធ្វើសម្បថចំពោះទេពារក្ស អារុក្ខអារក្សអ្នកតា និងបារមីស័ក្ដិសិទ្ធិនៅព្រះរាជាណាចក្រកម្ពុជារួចហើយ មុននឹងមកអង្គុយកន្លែងផ្ដល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍នាពេលនេះ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយ។

**ស៖** ជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចលោកក្នុងឋានៈជាលោកជាៗសាក្សីនៅក្នុងកិច្ចដំណើរការសវនាការដែលត្រូវផ្ដល់សក្ខីកម្មមកអង្គជំនុំជម្រះ លោក សៅ សារុន។ លោក សៅ សារុន អំពីសិទ្ធិលោក ក្នុងឋានៈលោកជាសាក្សី លោកមានសិទ្ធិក្នុងការបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការធ្វើការអត្ថាធិប្បាយដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

ហើយអំពីករណីយកិច្ច ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការចំពោះមុខអង្គជំនុំជម្រះ លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណា ឬការអត្ថាធិប្បាយរៀបរាប់ណា ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯងដូចយើងប្រាប់រួចហើយអំម្បាញ់មិញនេះ។ ហើយក្នុងឋានៈលោកជាសាក្សីត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬក៏មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេត

ដោយផ្ទាល់នូវព្រឹត្តិហេតុ ហេតុការណ៍ទាំងឡាយ ដែលពាក់ព័ន្ធនឹងសំណួរដែលចៅក្រមនៃអង្គជំនុំជម្រះ ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក សំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ តើលោកយល់អំពីសិទ្ធិ និងករណីយកិច្ចនេះដែរឬទេ?

[១៣:៤០:៥១]

**ឆ៖** អត់សូវយល់ អត់សូវចេះសំណួរ។

**ស៖** មិនមែនសំណួរទេ យើងប្រាប់អំពីសិទ្ធិ លោក សៅ សារុន។ លោកមានសិទ្ធិក្នុងការមិនឆ្លើយតបនូវសំណួរ ចំពោះសំណួរណាដែលសួរនាំឲ្យចម្លើយតបរបស់លោកដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ហើយចំណែកឯករណីយកិច្ចវិញគឺ ទី១ គឺត្រូវតែឆ្លើយតបរាល់សំណួរដែលសួរ។ ទី២ លើកលែងតែសំណួរណាដែលឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯងចម្លើយតបរបស់លោកដាក់ពិរុទ្ធភាពលើខ្លួនឯង ទើបលោកមិនបាច់ឆ្លើយតបទេ។ ហើយបញ្ហានេះដើម្បីច្បាស់លាស់អង្គជំនុំជម្រះតាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញបានចាត់តាំងមេធាវីទីប្រឹក្សាសាក្សីដែលអង្គុយក្បែរនោះហើយ ដើម្បីពិគ្រោះពិភាក្សាគ្នា ក្នុងករណីដែលមានសំណួរដាក់បន្ទុកលើលោក។ ឯករណីយ-កិច្ច គឺលោកត្រូវតែឆ្លើយតបហ្នឹងសំណួរទាំងអស់ដែលសួរដោយភាគី ឬចៅក្រមនៃអង្គជំនុំជម្រះ។ ហើយមួយទៀតគឺករណីយកិច្ចគឺថា លោកត្រូវតែនិយាយតែការណ៍ណាដែលពិតដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬក៏មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយ ដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។ តើលោកយល់ដែរទេ?

**ឆ៖** យល់ គឺបញ្ហាគឺខ្ញុំសូមគោរពលោក។ ខ្ញុំឆ្លើយបានតែការពិត និងភ្នែកឃើញ និងត្រចៀកខ្ញុំឮ បើក្រៅពីហ្នឹងខ្ញុំអត់ចេះឆ្លើយទេ ដូចខ្ញុំបានឆ្លើយនឹងលោកសហចៅក្រមស៊ើបអង្កេតកាលមុនហើយ។

[១៣:៤២:៣៩]

**ស៖** បាទ អរគុណណាស់។ ហើយលោក សៅ សារុន តើលោកដែលបានមកផ្ដល់សក្ខីកម្មនូវចំពោះ -- លោកដែលផ្ដល់សក្ខីកម្មនៅចំពោះអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ កន្លងមក?

**ឆ៖** បាទ បាន។ អាហ្នឹងហើយបានរាយការណ៍ជូនលោកសហចៅក្រមនៅផ្ទះយើងខ្ញុំ ម្ដង និងកន្លែងសវនាការ។

**ស៖** ហើយមុនពេលមកកាន់នៅទីនេះ តើលោកបានពិនិត្យ ឬក៏បានអានន្ធូវកំណត់ហេតុដែលស្ដាប់ ដែលលោកផ្ដល់សក្ខីកម្មកាលពីពេលមុន ដើម្បីរំឮកការចង់ចាំដែរឬទេ?

**ឆ៖** ឥឡូវនេះ វាចង់ភ្លេចការចងចាំអស់ហើយ បើៗយកតាមហ្នឹងចុះ តាមបានរាយការណ៍ជូនសវនាការតុលាការកំពូលហ្នឹងហើយ ឲ្យនិយាយសាឡើងវិញ ខ្ញុំភ្លេចការចងចាំអស់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយនាពេលនេះគឺ លោកបានទទួលមេធាវីប្រឹក្សាសាក្សីតាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញ តាមដំណើររបស់លោកហើយ គឺមេធាវី មឿន សុវណ្ណ។ ហើយសូមជម្រាបផងដែរ លោកមេធាវី មឿន សុវណ្ណ ក្នុងករណីមានសំណួរដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ឬខ្លួនសាក្សី ឬក៏មានការដែលស្នើសុំឲ្យសាក្សីធ្វើអត្ថាធិប្បាយ ដែលជាក្ដីអត្ថាធិប្បាយនោះ អាចប្រមើលមើលថា នឹងអាចដាក់បន្ទុកលើខ្លួនសាក្សីនោះ គឺលោកអាចពិភាក្សាបាន ពិភាក្សាគ្នាដោយជាសម្ងាត់ មិនមែនពិភាក្សាដាក់ក្បាលមីក្រូ ខ្សឹបដាក់ក្បាលមីក្រូទេ។ ហើយការឆ្លើយតប ឬក៏មិនឆ្លើយតបជារឿងរបស់សាក្សី មិនមែនមេធាវីឆ្លើយតបជំនួសសាក្សីទេ។ សូមរំឭកបញ្ជាក់សាជាថ្មីម្ដងទៀត ក្រែងលោភ័ន្តច្រឡំក្នុងការបំពេញមុខងារ។

បាទ ជាបន្តទៅនេះ ដោយអនុវត្តតាមបទបញ្ញត្តិនៃវិធាន៩០ ស្ទួននៃប្រធានផ្ទៃក្នុងអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី សៅ សារុន មុនភាគីដទៃទៀតនៃរឿងក្ដីហើយសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលកន្លះថ្ងៃក្នុងការតាំងសំណួរសាក្សីរូបនេះ។ សូមអញ្ជើញ!

[១៣:៤៥:២២]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ជម្រាបសួរលោក សៅ សារុន។ ខ្ញុំសូមជម្រាបប្រាប់លោកថា យើងមាន<កំណត់ហេតុ>ពីចម្លើយរបស់លោកនៅឆ្នាំ២០១២។ <យើង>មាន<ទាំងប្រតិចារឹក ទាំងវីដេអូ>ផង។ អ៊ីចឹងខ្ញុំស្នើសុំឲ្យលោកបញ្ជាក់អំពីអង្គហេតុមួយចំនួន ព្រឹត្តិការណ៍មួយចំនួន។ លោកយល់ដែរ?

**លោក សៅ សារុន៖**

**ឆ៖** បាទ។ ឆ្លើយ? អត់សូវយល់ខ្លឹមសារ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** នេះគ្រាន់តែជាការចាប់ផ្ដើមទេ លោក។ ខ្ញុំសួរតែម្ដង។ លោកបានឆ្លើយថា លោកកើតនៅមណ្ឌលគិរី តើលោកបន្តរស់នៅខេត្តមណ្ឌលគិរីរហូតដល់របបខ្មែរក្រហមដួលរលំ ពេលវៀតណាមចូលមក អ៊ីចឹងមែនទេ?

**ឆ៖** បាទ មែន។ រស់នៅ និងកើតនៅមណ្ឌលគិរីរហូតដល់វៀតណាមចូលមកឈ្លានពាន។

**ស៖** ដូច្នេះខ្ញុំយល់ឃើញថា លោកអាចនឹងផ្ដល់អង្គហេតុមួយចំនួននៅខេត្តមណ្ឌលគិរី។ តើ<ត្រឹមត្រូវទេដែលថា>ប្រជាជនភាគច្រើននៅខេត្តមណ្ឌលគិរី មិនមែនជាជាតិខ្មែរ <ឬពួកគេជាខ្មែរលើ ពួកគេនិយាយភាសាខុសៗគ្នា ហើយពួកគេជាកុលសម្ព័ន្ធ>ជនជាតិដើមភាគតិច អ៊ីចឹងមែនទេ លោក?

**ឆ៖** បាទ នៅខេត្តមណ្ឌលគិរីទាំងមូល គឺជនជាតិភាគតិច ភាគច្រើន គឺភាគច្រើន គឺជនជាតិភាគតិច ជនជាតិព្នង។

**ស៖** សូមអរគុណ។ តើ<ត្រឹមត្រូវដែរទេថា> ព្នងរស់នៅទាំងក្នុងទឹកដីខ្មែរផង <ទាំងក្នុងទឹកដីវៀតណាមផង> និង<ប្រហែលជា>រស់នៅក្នុងទឹកដីឡាវផង។ តើ<>លោក<អាចពន្យល់បានទេថា ព្នងរស់នៅទីណា>?

[១៣:៤៨:០៥]

**ឆ៖** បាទ គឺទឹក -- អាហ្នឹងជនជាតិព្នងនេះគឺនៅក្នុងខេត្តមណ្ឌលគិរីទាំងមូលតែម្ដង។

**ស៖** ចុះតើជនជាតិព្នងនេះ មានរស់នៅក្នុងប្រទេសវៀតណាមដែរទេ?

**ឆ៖** បាទ មាន។

**ស៖** លោក សារុន តើលោកមានបានចូលទៅក្នុងព្រៃ ដើម្បីចូលរួមតស៊ូប្រដាប់អាវុធដែរទេ នៅឆ្នាំ១៩៦៨ បាទ ឆ្នាំ១៩៦៨ តើលោកមានបានចូលតស៊ូប្រដាប់អាវុធក្នុងព្រៃដែរទេ?

**ឆ៖** បាទ បានចូលរួម។ ទៅក្នុងព្រៃ តស៊ូវាយចក្រពត្តិអាមេរិក។

**ស៖** តើលោកអាចពន្យល់ជូនតុលាការបានទេ នៅក្នុងឆ្នាំ១៩៦៨ ដែលតស៊ូប្រដាប់អាវុធប្រឆាំងទៅនឹងអាមេរិកាំងហ្នឹង តើលោកចូលរួមជាមួយក្រុមណាដែរ? ក្រុមនោះឈ្មោះអីដែរ?

**ឆ៖** ចូលរួមជាមួយ កាលហ្នឹងគឺឆ្នាំ៧០ហ្នឹង គឺបានចូលរួមជាមួយខ្មែរក្រហមនោះឯង វាយចក្រពត្តិអាមេរិកនោះ។

**ស៖** សូមអរគុណ។ តើត្រឹមត្រូវដែរទេថា លោកបានចូលរួមចលនាខ្មែរក្រហមនោះ គឺនៅក្នុងឆ្នាំ១៩៦៨ ត្រឹមត្រូវដែរឬអត់ទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** ចុះនៅក្នុងឆ្នាំ៦៨ហ្នឹង តើលោកវាយប្រយុទ្ធជាមួយខាងណា? ឬក៏ថាលោកក៏វាយប្រយុទ្ធជាមួយនឹងរបបសីហនុដែរ?

[១៣:៥០:៤៣]

**ឆ៖** បាទ គឺបានទទួលសេចក្តីអំពាវនាវរបស់សម្តេចឪ សីហនុ ហ្នឹងហើយ បានថាវៃចក្រពត្តិអាមេរិក គឺថា “សូមអញ្ជើញបងប្អូនគ្រប់ជនជាតិនៅខាងមណ្ឌលគិរីហ្នឹង គឺឲ្យក្រោកឡើងវៃចក្រពត្តិអាមេរិក វាឈ្លានពានទឹកដីយើង។” យើងបានចូលរួម។

**ស៖** ខ្ញុំសូមអានចម្លើយពីកិច្ចសម្ភាសន៍លើកទី១ របស់លោកជាមួយសហចៅក្រមស៊ើបអង្កេត E3/367, ERN ជាភាសាខ្មែរ 00251436, បារាំង 00486009, អង់គ្លេស 00278693។ លោកបានឆ្លើយទៅសហចៅក្រមស៊ើបអង្កេតក្នុងកិច្ចសម្ភាសន៍លើកទី១ថា៖ “នៅក្នុងឆ្នាំ<១៩៦៨> ប្រជាជនពីរភូមិ គឺមានភូមិកោះម្បើល និងភូមិពាមជីម្យៀត ចូលព្រៃតស៊ូ។ កាលនោះមេបញ្ជាការផ្ទាល់របស់ខ្ញុំឈ្មោះ ឡាំង។” តើត្រឹមត្រូវដែរទេ នូវអ្វីដែលខ្ញុំទើបតែអានពីចម្លើយរបស់លោកនេះ?

**ឆ៖** បាទ ហ្នឹងហើយ ឡាំង ហ្នឹងហើយគឺអ្នកស្រុកហ្នឹង ពួកពួងវៃចក្រពត្តិអាមេរិកនោះ ចូលព្រៃហ្នឹង។

**ស៖** លោក សារុន នៅក្នុងឆ្នាំ១៩៦៨ គឺជាពេលវេលាមួយមុនរដ្ឋប្រហារ លន់ នល់ មុនរដ្ឋប្រហារឆ្នាំ១៩៧០ គិតទៅវា២ឆ្នាំមុនរដ្ឋប្រហារ។ ត្រឹមត្រូវដែរទេលោក?

**ឆ៖** ម៉េច?

**លោក មឿន សុវណ្ណ៖**

សូមម្តងទៀត ស្តាប់អត់បាន។

**លោក សៅ សារុន៖**

**ឆ៖** ស្តាប់មិនបានសូមលើកសំណួរម្តងទៀត។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន សូម<>បង្ហាញរូបសាក្សីមក <ក្រោយពេលខ្ញុំសួរសំណួរ ដូច្នេះហើយយើងនឹងអាចមើលឃើញនូវអ្វីដែលកំពុងប្រព្រឹត្តទៅ ខណៈពេលកំពុងមានការបកប្រែ>។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី ខ្ញុំសួរសំណួរតាមរបៀបផ្សេងលោក។ ឡាំង តើ ឡាំង បានក្លាយជាសមាជិកមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** *(ពុំមិនច្បាស់)*។

**លោក មឿន សុវណ្ណ៖**

ឆ្លើយទៅ។

**លោក សៅ សារុន៖**

**ឆ៖** តាមដឹងហ្នឹងគឺគាត់ជាសមាជិករបស់មជ្ឈិមមែន។

**ស៖** តើក្រោយមកគាត់បានក្លាយជាលេខា<>តំបន់១០៥ <>មែនទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ចុះនៅពេលណាដែលលោកចូលរួមជាមួយបក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** តាំងពីឆ្នាំ១៩៦៨។

<>

[១៣:៥៥:២០]

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញាអន្តរជាតិមានឃើញរូបសាក្សីហើយនៅ?

**លោក នីកូឡាស គូមជែន៖**

ខ្ញុំមើល<>ឃើញគាត់<ហើយ> ប៉ុន្តែមើលទៅហាក់បីដូចជាឃើញរូបគាត់តែនៅពេលដែល<ឆ្លើយ>ចប់<>ហើយទេលោកប្រធាន <ប៉ុន្តែ>ខ្ញុំ<មិនឃើញគាត់ ពេលគាត់កំពុងស្តាប់>សំណួរ<និងពេលគាត់ចាប់ផ្តើមឆ្លើយទេ>។ <ដូច្នេះខ្ញុំស្នើសុំថា>ក្រោយ<>ពេលដែលខ្ញុំតាំងសំណួរជាភាសាអង់គ្លេសរួចហើយ <សូមឲ្យកាមេរ៉ាប្តូរទៅខាង>សាក្សី<វិញ>។

**ប្រធានអង្គជំនុំ៖**

បាទ ខាងសោតទស្សន៍សូមរៀបចំបញ្ហានេះ ដើម្បីឲ្យឆ្លើយតបទៅនឹងសំណូមពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក៏ដូចជាភាគីដទៃទៀតដែរ ដែលមានការពាក់ព័ន្ធនៅពេលដែលគាត់សួរ គឺសូមឲ្យបង្ហាញរូបសាក្សីបន្ទាប់ពីគាត់តាំងសំណួរចប់ ដើម្បីគាត់អាចស្តាប់ និងអាច ដូចជាសួរទល់មុខគ្នាអ៊ីចឹង

បញ្ហាទី១។ ទី២ យើងស្តាប់ទៅដូចជាមានបញ្ហាសំឡេង មានការជ្រៀតជ្រែកនៅក្នុងអំឡុងពេលផ្តល់សក្ខីកម្ម។ សាក្សី យើងប្រាប់ម្តងទៀត រួមទាំងមេធាវីប្រឹក្សាសាក្សី មិនអាចប្រឹក្សាគ្នាបានទេ ក្នុងអំឡុងពេលផ្តល់សក្ខីកម្មនេះ លើកលែងតែសំណួរណាដែលប្រមើលមើលឃើញថា វាអាចចម្លើយតប ឬសេចក្តីអត្ថាធិប្បាយរបស់សាក្សីតបទៅនឹងសំណួរ នាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ទើបអាចពិភាក្សាគ្នាបាន។ ស្តាប់ឲ្យបានណ៎ា មិនមែនចេះតែជ្រៀតជ្រែក ឬក៏សួរនាំគ្នាបានទេ។ នេះជាការរំខានដល់កិច្ចការដំណើរការសវនាការ។ បាទ អញ្ជើញបន្តទៀត សហព្រះរាជអាជ្ញាអន្តរជាតិ។

[១៣:៥៧:២៥]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី តើលោកជួប ប៉ុល ពត លើកដំបូងនៅពេលណា?

**លោក សៅ សារុន៖**

**ឆ៖** មិនដឹងពេលណាទេ ភ្លេចអស់ហើយ យូរហើយ។

**ស៖** ចុះលោកនៅនឹកឃើញទេថា លោកជួប ប៉ុល ពត នៅកន្លែងណា?

**ឆ៖** បាទ ជួបនៅភ្នំពេញនោះឯង។

**ស៖** តើ ប៉ុល ពត ឬ នួន ជា ឬ ខៀវ សំផន ធ្លាប់ដែលបានទៅធ្វើទស្សនកិច្ចនៅខេត្តមណ្ឌលគិរីដែរទេ នៅពេលដែលលោកនៅឯខេត្តមណ្ឌលគិរី?

**ឆ៖** បាទ អត់ទេ មិនដែលឃើញគាត់ទៅទេ។

**ស៖** ខ្ញុំសូមចូលទៅនិយាយអំពីកិច្ចប្រជុំមួយ ដែលលោកបានឆ្លើយជាមួយសហចៅក្រមស៊ើបអង្កេត។ លោកបានជម្រាបទៅសហចៅក្រមស៊ើបអង្កេតថា នៅឆ្នាំ៧២ លោកបានចូលរួមនៅក្នុងអង្គប្រជុំមួយនៅខេត្តកំពង់ធំ។ ហើយក្នុងអង្គប្រជុំនេះគឺ នួន ជា ជាអ្នកឡើងធ្វើសេចក្តីថ្លែង។ លោកនៅចាំទេ ថានៅពេលហ្នឹង នួន ជា គាត់ថ្លែងអំពីអ្វី?

**ឆ៖** បាទ គឺគាត់ថ្លែងមានតែបញ្ហាថា ប្រមូលកម្លាំង គ្រប់គ្រងកម្លាំង ដើម្បីវ៉ៃអាមេរិកតែប៉ុណ្ណឹង និងកសាងសេដ្ឋកិច្ច។

[១៣:៥៩:៣២]

**ស៖** ខ្ញុំសូមសួរលោកអំពីចម្លើយដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺចម្លើយដដែល E3/367 ខ្មែរ ERN ខ្មែរ00251437, បារាំង 00486010, អង់គ្លេស 00278694។ លោកបាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឆ្លើយថា៖ “នៅក្នុងអង្គប្រជុំដែល ប៉ុល ពត និង ខៀវ សំផន ក៏មានវត្តមានដែរ។ នួន ជា គឺជាអ្នកធ្វើបទបង្ហាញក្នុងវគ្គរៀនសូត្រនយោបាយ ក្នុងការវាយប្រយុទ្ធចក្រពត្តិអាមេរិក រំដោះជាតិ ហើយនិងការបង្ក្រាបនូវវណ្ណៈជិះជាន់។” ដូច្នេះ ខ្ញុំសូមឱ្យលោកពន្យល់ពាក្យដែលលោកប្រើនោះគឺថា នួន ជា និយាយអំពីវណ្ណៈជិះជាន់។ តើ <នរណាជា>“វណ្ណៈជិះជាន់”<>?

**ឆ៖** អាហ្នឹងនែ៎ អត់យល់ទេ។ វណ្ណៈជិះជាន់ហ្នឹង គេសំដៅលើសម្ដេចហ្នឹងឯង អ្នកជិះជាន់ មិនគេសំដៅលើអីទេ។ ខ្ញុំមិនសូវយល់ដែរ។

**ស៖** ខ្ញុំយល់ឃើញថា ខ្ញុំយល់តាមការបកប្រែនេះគឺ មិនច្បាស់ទេជាភាសាអង់គ្លេស អត់យល់។ សុំលោកនិយាយម្ដងទៀតមក “វណ្ណៈជិះជាន់” នេះ លោកសំដៅទៅលើអ្វី?

**ឆ៖** សំដៅលើគេថា អ្នកជិះជាន់សង្កត់សង្កិនប្រជាពលរដ្ឋហ្នឹង។ អាហ្នឹងគេសំដៅតែអ្នកហ្នឹងឯង វណ្ណៈជិះជាន់ អ្នកគ្រប់គ្រង។

**ស៖** ហើយ<>ប្រទេស<នោះ> គឺសំដៅ<>កម្ពុជា។ អ៊ីចឹងមែនទេលោក?

**ឆ៖** បាទ។

[១៤:០២:០៥]

**ស៖** លោកសាក្សី លោកបានឆ្លើយថា លោកមានតួនាទីច្រើនដែរ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងតួនាទីជាលេខាស្រុក ក្រោយមកលេខាតំបន់១០៥។ តើលោកអាចជម្រាបជូនតុលាការបានទេ ក្នុងអំឡុងពេលនោះ តើលោក<>ត្រូវដើរតាមគោលនយោបាយបក្ស ឬក៏គេអនុញ្ញាតឱ្យលោកដាក់គោលនយោបាយចេញដោយខ្លួនឯងបានដែរ?

**ឆ៖** បាទ គឺកាលហ្នឹងគឺ ខ្ញុំជាប្រធានស្រុកពេជ្រាដាតាំងពីឆ្នាំ១៩៧១ គេចាត់តាំងខ្ញុំធ្វើជាប្រធានស្រុកពេជ្រាដា។

**ស៖** លោកសាក្សី យើង<>ដឹង<រឿងនេះ>ហើយ ហើយលោកក៏បាននិយាយ<ថា ក្រោយ>ការបាត់ខ្លួន ឬការស្លាប់ ឡាំង។ បាទ ក្រោយពី ឡាំង បាត់ខ្លួន ឬក៏ស្លាប់ទៅ លោកក៏បានក្លាយទៅជាលេខា<តំបន់>។ អ៊ីចឹង<នៅក្នុងតួនាទីទាំងអស់នោះ ទាំង>ជាលេខាស្រុក <និងទាំងជាលេខាតំបន់> តើគេតម្រូវឱ្យលោកដើរតាមគោលនយោបាយដាក់ចេញដោយមជ្ឈិមបក្ស ឬក៏គេឱ្យលោកដាក់គោលនយោបាយចេញដោយខ្លួនឯងបានដែរ?

**ឆ៖** អត់បានទេ គឺគោលនយោបាយហ្នឹងគឺមកពីមជ្ឈិមបក្ស គេកំណត់។ យើងបុគ្គលម្នាក់ៗ

អត់មានសិទ្ធិទេ កំណត់គោលនយោបាយទេ។

**ស៖** តើនៅក្នុងពេលនោះ លោកអាចបដិសេធមិនធ្វើតាមគោលនយោបាយបក្សទេ <ដោយប្រាប់ទៅមជ្ឈិមថា ការធ្វើបែបនេះមិនត្រឹមត្រូវទេ ហើយលោកមិនចង់ធ្វើ តើលោកគិតថាគួរតែ>មានគោលនយោបាយផ្សេង<ទេ>?<>

[១៤:០៤:៤៦]

**ឆ៖** សូមឆ្លើយគឺ ពេលហ្នឹងល្អ មិនល្អក៏គេចេះតែស្ដាប់គេហើយ។ យើងពេញចិត្ត មិនពេញចិត្តក៏មិនបានដែរ មិនបានបដិសេធ។ បើបានបដិសេធ គឺទៅហើយ អត់មានរស់ទេ ចេះតែស្ដាប់គេទៅអ៊ីចឹងហើយ។

**ស៖** សូមអរគុណ។ ខ្ញុំនឹងសួរសំណួរទាក់ទងទៅនឹងគោលនយោបាយមួយចំនួនទាក់ទងទៅនឹងការរៀបការ។ តើគោលនយោបាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គេនិយាយដូចម្ដេចអំពីការរៀបការបុរស និងស្ត្រី?

**ឆ៖** អ៊ីចឹងគឺដឹងគោលនយោបាយយ៉ាងម៉េចទេ គេពេលហ្នឹង ឃើញតែថាចេះតែរៀបតែម្ដងមួយគូ ពីគូអីតែអ៊ីចឹង។ គេថាគេរៀបតាមសម័យគេ សម័យកុម្មុយនីស្តហ្នឹង ថារៀបអ៊ីចឹង យើងអ្នករៀបតាមសង្គមចាស់ហ្នឹងក៏វាលំបាក គេថា--

**ស៖** ប្រហែលអាចនឹងរំឭកការចងចាំរបស់លោកអំពីអ្វីដែល នួន ជា បាននិយាយអំពីគោលនយោបាយនេះ។ ខ្ញុំនឹងអានជូនលោកស្ដាប់អំពីឯកសារចេញពីសៀវភៅមួយដែលគាត់សរសេរជាមួយ ថេត សម្បត្តិ <E3/4202>, ខ្មែរ 00858253, បារាំង 00849377, អង់គ្លេស 00757496។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! លោកមេធាវីវ៉ិចទ័រ កូប៉េ មានបញ្ហាអីទៅ?

[១៤:០៦:៥១]

**លោក វ៉ិចទ័រ កូប៉េ៖**

ជាសេចក្ដីសង្កេត ដើម្បីកែតម្រូវ លោកប្រធានគឺថាសៀវភៅដែលសរសេរដោយ <ជីណា ចន> ហើយនិង ថេត សម្បត្តិ មិនមែន នួន ជា ជាអ្នកសរសេរទេ។ <គាត់គ្រាន់តែផ្ដល់បទសម្ភាសន៍ទៅឲ្យ ថេត សម្បត្តិ និង លឹម គីម ទេ។>

**លោក នីកូឡាស គូមជែន៖**

ខ្ញុំមិនជំទាស់ទេ ប៉ុន្តែលោក នួន ជា បានផ្តល់ការអនុញ្ញាតឲ្យសរសេរសៀវភៅនេះ ប៉ុន្តែខ្ញុំនឹងបន្តទៅទៀតលោកប្រធាន។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សីសៀវភៅដែល ថេត សម្បត្តិ ហើយនិង ជីណា ចន សរសេរ<ដូចខាងក្រោមនេះ>អំពីគោលនយោបាយរៀបចំគ្រួសាររៀបអាពាហ៍ពិពាហ៍ ទាក់ទងនឹងការបង្កើនគ្រួសារ។ "<ដោយសារតែពួកគេចង់បង្កើនចំនួនប្រជាពលរដ្ឋទ្វេដង> ខ្មែរក្រហមចង់បង្កើនចំនួននៃការរៀបការប៉ុន្តែដោយថាសង្គ្រាមសម្លាប់<ប្រុសៗ>ជាច្រើន មានស្ត្រីច្រើននៅក្នុងសង្គម។ ខ្មែរក្រហមចាត់វិធានការនៅក្នុងកណ្តាប់ដៃរបស់ខ្លួន" បន្ទាប់មកគេដកស្រង់សម្តី នួន ជា សូមដកស្រង់៖ "នួន ជា និយាយថាបុរសចង់បាននារីដែលស្អាតៗ ហេតុនេះហើយដែលយើងត្រូវបង្ខំឲ្យគេរៀបការ ហើយអង្គការជាអ្នកជ្រើសប្រពន្ធឲ្យគេ"។ គេនិយាយថា នួន ជា ប្រាប់គេ អ្នកនិពន្ធនិយាយថានារីក្មេងៗគឺត្រូវបង្ខំឲ្យរៀបការជាមួយបុរសដែលមានអាយុច្រើនជាងខ្លួនពីរដង <និងផ្ទុយមកវិញ>។ ហើយទាក់ទងទស្សនៈកូនកម្លោះ និងកូនក្រមុំ <មិនមានបញ្ហាអ្វី>ទេ។ <ការរៀបអាពាហ៍ពិពាហ៍ បានក្លាយជាគោលនយោបាយរបស់រដ្ឋាភិបាល និងវិទ្យាស្ថានដែលបម្រើឲ្យបុព្វហេតុបដិវត្តន៍>។" លោកសាក្សី តើ<>សេចក្តីថ្លែងការណ៍គោលនយោបាយ<រៀបអាពាហ៍ពិពាហ៍>នេះ<ត្រឹមត្រូវទេតាមបទពិសោធន៍របស់លោកនោះ>?

[១៤:០៨:៣៦]

**លោក វិុចទ័រ កូប៉េ៖**

<ខ្ញុំជំទាស់នឹងការតាំងសំណួរនេះលោកប្រធាន។>

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី វិុចទ័រ កូប៉េ!

**លោក វិុចទ័រ កូប៉េ៖**

តាមពិតសេចក្តីសង្កេតរបស់ខ្ញុំ គឺទាក់ទងទៅនឹង<ការកែតម្រូវ> ឥឡូវទៅជាការជំទាស់ហើយលោកប្រធាន។ <អត្ថបទ>នេះ<សរសេរដោយ> ជីណា ចន <ទាំងស្រុង។ ថេត សម្បត្តិ ជាអ្នកធ្វើ

បទសម្ភាសន៍ ប៉ុន្តែជីណា ចន> ជាអ្នក<>រៀបចំអត្ថបទបញ្ចូលគ្នា ហើយគាត់ផ្អែកលើប្រភព<ទី២>។ ខ្ញុំដឹងថាអត្ថបទនោះចេញមកពីណា ហើយខ្លឹមសារនោះវាខុសប្រធានបទ ខុសបរិបទ ប៉ុន្តែ<វាមិនមានបញ្ហាអីទេ។ ទោះជាយ៉ាងណា ក៏បង្ហាញសម្រង់នេះទាំងស្រុង ថាជាការ>ផ្ទុះបញ្ចាំងពីគោលនយោបាយ<នោះ គឺជាការខុសទាំងស្រុងហើយ។> វាផ្ទុះបញ្ចាំងពីអ្វីដែល ជីណា ចន គាត់ជឿ<>ថា<ជា>គោលនយោបាយ<រៀបអាពាហ៍ពិពាហ៍។ នេះជាការខុសគ្នាទាំងស្រុង>។

[១៤:០៩:៤១]

**លោក នីកូឡាស គូមជែន៖**

លោក លោកស្រីចៅក្រម សៀវភៅខ្លួនឯង ហើយ នួន ជា ក្នុងសក្ខីកម្មរបស់ខ្លួន គាត់ថាគាត់ផ្តល់ការអនុញ្ញាតជាមួយនឹង ថេត សម្បត្តិ ទៅលើបញ្ហានេះ។ ហើយ<ខ្ញុំជឿថា> នួន ជា បាន<ប្រាប់តុលាការថា តើភាពស្មោះត្រង់របស់សៀវភៅនោះនៅកន្លែងណា>។ ហើយ សម្បត្តិ <និងអ្នកផ្សេងៗទៀតបាន>បញ្ជាក់ថា គាត់បានពិភាក្សាជាមួយ នួន ជា <រាប់រយ>ម៉ោង។ ហើយ<អ្វីដែលខ្ញុំទើបតែបានអានគឺជាសម្រង់មួយ> គឺថា៖ “បុរសៗតែងតែចង់បាននារីស្អាត” ហើយ<បញ្ចប់ដោយ> នួន ជា និយាយថា៖ <“នេះហើយជា>មូលហេតុនេះដែលយើងបង្ខំឲ្យ<ពួកគេរៀបការ> ហើយអង្គការជាអ្នកជ្រើសរើស<ប្រពន្ធឲ្យពួកគេ>។” <ដូច្នេះខ្ញុំយល់ហើយថា ហេតុអ្វីបានជាមានការជំទាស់ ពីព្រោះ> នេះហើយជាការសារភាពចំពោះគោលនយោបាយបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍។ <ប៉ុន្តែជាការពិត>នេះ <ប្រភពទី២> ដែល<>សម្ភាស<ផ្ទាល់ជាមួយ> នួន ជា។

**លោក វ៉ិចទ័រ កូប៉េ៖**

នេះ គឺមិនត្រឹមត្រូវទេលោកប្រធាន។ គឺថាសៀវភៅនេះចេញពីក្នុងឆ្នាំ២០១០ ហើយខ្ញុំអាចចាំស្ទើរតែផ្ទាល់មាត់ហើយ <គាត់ត្រូវបានឃុំខ្លួនអស់រយៈពេលបីឆ្នាំរួចទៅហើយ។> គឺថាគាត់មិនដែលផ្តល់ការអនុញ្ញាត<ទៅលើ>អត្ថបទ<ចុងក្រោយ>នេះ<>ទេ <ហើយប្រសិនបើគាត់បានអានវានោះគាត់ច្បាស់ជាមិនផ្តល់ការអនុញ្ញាតទៅលើផ្នែកដែលមិនមែនជាការដកស្រង់សម្តីគាត់នោះ>ទេ។ គឺថាការដកស្រង់នេះ គឺថាខុសបរិបទទាំងស្រុង។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំ<មិនដឹង>ថាមេធាវីអាចបញ្ជាក់អ៊ីចឹងបាន<ទេ> ប៉ុន្តែ<នេះជាអ្វីដែលបានសរសេរនៅក្នុង>សៀវភៅ<>នេះ។ <មេធាវីការពារក្តីបានផ្អែកលើសៀវភៅនេះ។ ពួកគេបានស្នើសុំឲ្យទទួលយក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សៀវភៅនេះ។ យើងបានស្នើសុំឲ្យលោក ថេត សម្បត្តិ មកផ្តល់សក្ខីកម្ម ហើយខ្ញុំគិតថា មេធាវីការពារក្តីក៏សុំបែបនេះដែរ។> <ដូច្នេះខ្ញុំគិតថា ជាការសមហេតុផលណាស់ ដែលមេធាវីការពារក្តី ឬភាគីណាមួយ ដកស្រង់ឃ្លាណាមួយមកសួរ>សាក្សី។ <នេះជាការ>ដកស្រង់ពី<> នួន ជា <ដោយអ្នកនិពន្ធជីវប្រវត្តិរបស់គាត់>។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១៤:០១]

**ប្រធានអង្គជំនុំ៖**

បាទ ករណីនេះអង្គជំនុំជម្រះសម្រេចថា បដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារក្តី នួន ជា ចំពោះសំណួរនេះ។ ហើយសំណួរនេះ គឺសមស្របនឹងសួរ ហើយអង្គជំនុំជម្រះក៏ត្រូវការស្តាប់ចម្លើយតបរបស់សាក្សី តបទៅហ្នឹងសំណួររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលសួរសាក្សីចុងក្រោយដែរ។ ហើយទំនងជាសាក្សីភ្លេចហើយ អាយុចាស់ អាយុច្រើនហើយ បើតាមឆ្នាំ អាយុ៨៤ឆ្នាំនេះហើយ គាត់ឆ្លើយថាគាត់៩២ បើតាមមើលផ្ទៀងផ្ទាត់ជាមួយឆ្នាំកំណើតគឺ១៩៣២ គឺកៅសិបនេះហើយ។ អ៊ីចឹងគឺទំនងជាលំបាកក្នុងការចង់ចាំ។ សូមលោកតាំងរៀបរាប់ រៀបចំសំណួររបស់លោកសាជាថ្មីឡើងវិញ។

**លោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សីសៀវភៅដកស្រង់សម្តីរបស់ នួន ជា ថា៖ "បុរសចង់បាននារីស្អាតធ្វើជាប្រពន្ធ ដូច្នេះហើយ<ទើបយើងបង្ខំឲ្យពួកគេរៀបការ ហើយ>អង្គការត្រូវជ្រើសរើសនារីធ្វើជាប្រពន្ធរបស់អ្នកទាំងនោះ។" ហើយពីអ្វីដែលលោកបានដឹងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើចំណុចនេះជាគោលនយោបាយរបស់គេដែរឬទេ?

យើងរង់ចាំចម្លើយពីលោក ។សាក្សី។ ខ្ញុំនឹងសួរលោកម្តងទៀត។ សំណួរខ្ញុំសួរថា នៅពេល នួន ជា និយាយបែបនេះត្រឹមត្រូវដែរឬទេ? <គាត់និយាយពីគោលនយោបាយរៀបអាពាហ៍ពិពាហ៍។> "<>បុរស<។តែងតែ>ចង់បាននារីស្អាត ហេតុដូច្នេះហើយបានជាយើងបង្ខំឲ្យគេរៀបការ ហើយ<> អង្គការជាអ្នកជ្រើសរើសប្រពន្ធឲ្យពួកគេ។" តើខ្លឹមសារហ្នឹងត្រឹមត្រូវ ឬដូចម្តេច?

[១៤:១៦:១៤]

**លោក មឿន សុវណ្ណ៖**

ឆ្លើយ។

**ប្រធានអង្គជំនុំ៖**

សាក្សីស្ដាប់មិនបានសួរមកវិញ ដើម្បីឱ្យសួរចម្លើយម្ដងទៀត លោកមិនគប្បីពិភាក្សាអីទេ ព្រោះមិនមែនសំណួរដាក់បន្ទុកលើលោកទេ។ មេធាវីពន្យល់គាត់ផង ហើយមុននឹងផ្ដើមស្ដាប់ ធ្វើសវនាការត្រូវពន្យល់ពីបញ្ហានេះផង ឱ្យគាត់ពិភាក្សាគ្នាតែសំណួរណាដែល ឬក៏ធ្វើការអះអាងអំណះអំណាងណាមួយ ដែលនាំឱ្យលទ្ធផលនៃចម្លើយតប ឬក៏អះអាងតបហ្នឹងវាមានជាលទ្ធភាពអាចចម្លើយដាក់បន្ទុកលើខ្លួនឯង ទើបពិភាក្សាគ្នា។ ស្ដាប់មិនបានសាក្សីសួរមកម្ចាស់សំណួរឱ្យសួរសាជាថ្មីម្ដងទៀត ឬក៏ប្រាប់មកយើង ដើម្បីយើងប្រាប់អ្នកដែលសួរហ្នឹង ឱ្យសួរលោកសាជាថ្មីម្ដងទៀត។

ហើយសហព្រះរាជអាជ្ញាអន្តរជាតិ គួរយល់ពីបញ្ហានេះហើយ គាត់ចាស់ហើយគាត់មិនចងចាំទេ គប្បីកាត់សំណួរយ៉ាងម៉េចខ្លីៗ ដើម្បីងាយយល់ អាចដំណើរការហ្នឹងបានចប់ចុងចប់ដើម។ យើងប្រាប់ហើយអំមិញ ១៩៣២ ទំនងជាអាយុច្រើនហើយកៅសិបជាង ៨៤ទៅហើយ។ អ៎! ៨៤ អាយុច្រើនអ៊ីចឹងប្រហែលជាយើងមើលរូបរាងកាយរបស់គាត់អាចមានបញ្ហាចងចាំ ទំនងជាអាចកើតមានចំពោះគាត់ ដូចគាត់បាននិយាយអ៊ីចឹង។

តាំងសំណួររបស់លោកសាជាថ្មីម្ដងទៀត ទំនងសាក្សីស្ដាប់មិនបានទេ។

[១៤:១៧:៥៩]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី ខ្ញុំអានសេចក្ដីដកស្រង់ពី នួន ជា និយាយថា៖ "អង្គការបង្ខំឱ្យ<ពួកគេ>រៀបការ ហើយអង្គការជាអ្នកជ្រើសរើសប្រពន្ធឱ្យពួកគេ"។ តើនេះ<ជាអ្វីដែលបានកើតឡើង>មែនឬទេ?

**លោក សៅ សារុន៖**

**ឆ៖** អានេះ ខ្ញុំបាទសូមឆ្លើយចុះ អត់សូវយល់ដែរ ឃើញតែគេថា រៀបម្ដងមួយគូ, ពីរគូ, បីគូអីទៅ។ ហ្នឹងមិនដឹងគេធ្វើដោយយ៉ាងម៉េច អាហ្នឹងអត់សូវយល់។

**ស៖** តើលោកទទួលព័ត៌មានដែរទេ <តាមរយៈ>វគ្គសិក្សា ឬក៏ឯកសារ ឬក៏ក្នុងកិច្ចប្រជុំនានាដែលថាអង្គការចង់បង្កើនចំនួនប្រជាជន<>?

**ឆ៖** បាទ អាហ្នឹងឮ។ ត្រូវឱ្យយើងបង្កើនចំនួនប្រជាជនហ្នឹងឱ្យវាកាន់តែច្រើនតែឡើង--<> ពីព្រោះយើង ប្រទេសយើងប្រជាជនតិច ធ្វើយ៉ាងម៉េចទាល់រៀបចំគូស្រករឱ្យយុវជន យុវនារីឱ្យបាន

ត្រឹមត្រូវ។ អាហ្នឹងឮអាហ្នឹង។

**ស៖** ខ្ញុំនឹងចូលទៅប្រធានបទមួយផ្សេងទៀត នៅថ្ងៃទី០៥ មិថុនា ឆ្នាំ២០១២ លោកបញ្ជាក់ថា តំបន់១០៥ គេហៅថាជាតំបន់ឯករាជ្យ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** តើត្រឹមត្រូវដែរឬទេ តំបន់នោះរាយការណ៍ដោយផ្ទាល់ទៅមជ្ឈិម គឺមិនរាយការណ៍ទៅភូមិភាគទេ ត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[១៤:១៩:៥០]

**ស៖** លោកសាក្សីមានឯកសារមួយ E3/12 ចុះថ្ងៃ៣០ <មីនា> ឆ្នាំ១៩៧៦ ជាសេចក្តីសម្រេចរបស់គណៈមជ្ឈិមពាក់ព័ន្ធនឹងបញ្ហាមួយចំនួន។ ចំណុចទី១ និយាយថា "សិទ្ធិកម្ទេចនៅក្នុង និងក្រៅជួរបក្ស"។ ឯកសារនេះនិយាយថា៖ "១) គឺថា ក្របខ័ណ្ឌអំពីគោលជំហរដាច់ខាតរបស់បដិវត្តន៍។ ២) គឺថាពង្រឹង<ប្រជាធិបតេយ្យ>សង្គមនិយម គឺពង្រឹងអំណាចរដ្ឋរបស់យើង។ នៅក្នុងក្របខ័ណ្ឌមូលដ្ឋានត្រូវ<>សម្រេច<ដោយ>គណៈកម្មការអចិន្ត្រៃយ៍ភូមិភាគ។ ជុំវិញ<មន្ទីរ>មជ្ឈិម គឺត្រូវសម្រេចដោយគណៈមជ្ឈិម។ ហើយតំបន់ឯករាជ្យត្រូវសម្រេចដោយគណៈអចិន្ត្រៃយ៍។"

ខ្ញុំសង្ខេបបន្តិចឲ្យងាយស្រួល សេចក្តីសម្រេចរបស់គណៈមជ្ឈិមបក្សនៅថ្ងៃទី៣០ មីនា ឆ្នាំ ១៩៧៦ គឺនិយាយអំពីសិទ្ធិនៃការកម្ទេចនៅក្នុង ហើយនិងនៅក្រៅជួរបក្ស។ នេះខ្ញុំនិយាយអំពីតំបន់ឯករាជ្យ គឺត្រូវសម្រេចដោយគណៈអចិន្ត្រៃយ៍។ តើត្រឹមត្រូវដែរឬទេ អំពីអ្វីដែលលោកធ្លាប់ធ្វើជាលេខាស្រុក និងលេខាតំបន់ពាក់ព័ន្ធទៅនឹងការកម្ទេចមនុស្សនៅក្នុង ហើយនិងក្រៅជួរបក្សនោះ គឺតំបន់១០៥ ជាតំបន់ឯករាជ្យ ត្រូវតែគោរពតាមសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍? តើការពិតវាកើតឡើងអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ គឺបញ្ហាហ្នឹងគឺតំបន់១០៥ហ្នឹង កាលពីមុនហ្នឹងខ្ញុំអត់សូវយល់ដែរ ពីព្រោះខ្ញុំការងារនៅស្រុកហ្នឹង គេសម្រេចយ៉ាងម៉េចៗ ខាងគណៈមជ្ឈិមគឺខ្ញុំអត់សូវយល់។

[១៤:២២:០៧]

**ស៖** លោកសាក្សី ខ្ញុំដកស្រង់ចំណុចមួយចំនួនដែលលោកបានឆ្លើយក្នុងសក្ខីកម្មនៅឆ្នាំ២០១២ នៅថ្ងៃទី០៧ មិថុនា។ នៅម៉ោង០៩:២៧ព្រឹក គេសួរសំណួរលោកអំពី ជួន ដែលគេហៅទៅអប់រំនៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ភ្នំពេញ ប៉ុន្តែតាមពិតគេបញ្ជូនគាត់ទៅស-២១ នៅខែវិច្ឆិកា ឆ្នាំ១៩៧៧។ ហើយគេសួរលោក<ថានរណាជាអ្នកបញ្ជាឲ្យ>ចាប់ខ្លួន<នេះ។> ហើយលោកឆ្លើយថា៖ “ខ្ញុំមិនយល់មិនស្គាល់ស្ថានភាពនោះទេ មនុស្សបាត់ខ្លួន ហើយម្នាក់ៗក៏មានការភ័យខ្លាច។” តើនោះជាស្ថានភាពអីចឹងមែនទេ នៅពេលដែលលោកទទួលបន្ទុកនៅតំបន់ <ដែលមានមនុស្សបាត់ខ្លួន> ហើយម្នាក់ៗក៏ភ័យខ្លាច? តើអីចឹងមែនទេកាលនោះ?

**ឆ៖** បាទ អង្កាល់ហ្នឹងគឺអីចឹងមែន។ ម្នាក់ៗគឺចេះតែភ័យហើយ ឲ្យតែថាហៅទៅភ្នំពេញ គឺភ័យហើយ ពីព្រោះហៅទៅបាត់ ហៅទៅបាត់ មិនដឹងបាត់ពីរឿងអី។ ឃើញតែបាត់តែមនុស្សទៅ។ ពិសេស គឺប្អូនខ្ញុំ ប្អូនថ្លៃអី បាត់ គេហៅទៅធ្វើការៗ មិនដឹងធ្វើការអីបាត់រហូតទៅ អត់ឃើញមក។

**ស៖** តើលោកនិយាយ<សំដៅ>ទៅ សុភា ឬក៏លោកនិយាយ<សំដៅ>ទៅរកអ្នកណា<>?

**ឆ៖** ប្អូនថ្លៃខ្ញុំ សុភា ហ្នឹង គេទៅហៅទៅ។ ទៅជាមួយហើយ ដល់មកទៅគេថា ខាងយោធាធ្វើការសិនទៅ បាត់រហូតមកដល់សព្វថ្ងៃនេះ។

**ស៖** ដើម្បីឲ្យខ្ញុំច្បាស់ ថាតើប្អូនថ្លៃប្រុសរបស់លោកហ្នឹងឈ្មោះអ្វី?

**ឆ៖** បាទ សុភា ហ្នឹង។

[១៤:២៤:១៩]

**ស៖** លោកសាក្សី លោកនិយាយនៅក្នុងសក្ខីកម្មនៅថ្ងៃទី០៦ មិថុនា នៅម៉ោង១៤:៣៣នៅពេលដែលនិយាយពីការបាត់ខ្លួនរបស់ ម៉ាឡា និយាយពី ជួន ហ្នឹង។ តើអ្នកណាជាអ្នកបញ្ជាឲ្យមានការបញ្ជូនអ្នកទាំងអស់នោះទៅ ហើយក៏ក្រោយមកបាត់ខ្លួនហ្នឹង ក្រោមបញ្ជារបស់អ្នកណា?

**ឆ៖** គឺបញ្ជាមកពីលោក ប៉ុល ពត ហ្នឹង ថាហៅទៅធ្វើការ ទៅក៏បាត់ទៅ។

**ស៖** ឥឡូវនេះ តើ<ការ>បញ្ជា<ធ្វើឡើងតាមរយៈ>ការហៅទូរស័ព្ទ ឬក៏ដោយនីរសារ ឬក៏សារទូរលេខ? សូមលោកពន្យល់តុលាការ ថាតើបញ្ជាថាឲ្យបញ្ជូនមនុស្សទៅរៀនសូត្រហ្នឹង គេបញ្ជូនបញ្ជាមកដូចម្ដេចតាមរបៀបណា?

**ឆ៖** ច្រើនតែគេបញ្ជាមកតាមទូរលេខ។ អត់មាន ថាឲ្យហៅទៅរៀន ឈ្មោះនេះ ឈ្មោះនេះ គេចុចឈ្មោះមកពីភ្នំពេញតែម្ដង។ ហៅទៅរៀនទៅ បើយើងមិនទៅ ក៏គេទៅហៅទៅរៀន ទៅរៀនទៅបាត់មិនឃើញមក--

**ស៖** ពីដើមលោកបានផ្ដល់សក្ខីកម្មថា នួន ជា បញ្ជូន<សារ>ទូរ<លេខ> ហើយហៅកម្មាភិ-

បាលទៅចូលរួមវគ្គសិក្សា។ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** ឥឡូវមនុស្សទាំងអស់នោះ ដែល នួន ជា បានហៅទៅឲ្យរៀនសូត្រនោះ តើមានអ្នកណាបាត់ខ្លួន មានអ្នកណានៅសល់ដែរឬទេ?

**ឆ៖** បាត់ខ្លួនតែប្អូនថ្លៃខ្ញុំទេ ក្រៅពីហ្នឹងនៅសល់ទាំងអស់។

[១៤:២៦:២៩]

**ស៖** លោកសាក្សី យើងមានសេចក្តីសង្ខេបអំពីកំណត់ហេតុរបស់<មនុស្សរាប់រយ>នាក់<ពីតំបន់១០៥> គឺថា ដែលគេបញ្ជូនទៅ ស-២១<>។ អ៊ីចឹងយើងចង់ដឹងថា តើគេបញ្ជូនអ្នកទាំងអស់នោះ<ទៅ>ស-២១ <ដោយរបៀបណា>? <តើនរណាជាអ្នកបញ្ជាឲ្យបញ្ជូនអ្នកទាំងនោះទៅ?>

**ឆ៖** ខ្ញុំអត់យល់ដែរ តាឡាំង ហ្នឹងគេបញ្ជូនរបៀបណាៗ ខ្ញុំនៅឯស្រុកពេជ្រាដា អត់យល់ទេ មិនដឹងគេបញ្ជូនរបៀបណាទេ មិនដឹងការងារអី អត់យល់។

**ស៖** ខ្ញុំចង់បំភ្លឺបញ្ហាមួយពីខាងដើម លោកបានធ្វើសក្ខីកម្មថា បន្ទាប់ពីការស្លាប់របស់ ឡាំង ហើយ ជួន បានទាក់ទងលោក ហើយលោកមកភ្នំពេញប្រហែល<ប៉ុន្មាន>ថ្ងៃ<បន្ទាប់ពី>ហ្នឹង ហើយនៅក្រុងភ្នំពេញ ប៉ុល ពត បានចាត់តាំងលោកឲ្យកាន់តំបន់។ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ តាឡាំង ស្លាប់ហ្នឹង ជួន ទៅហៅខ្ញុំនៅឯស្រុកនោះ ហៅថា មិនចូលផ្ទះខ្ញុំទៀត រាងខ្លាចៗទៀតណ៎ា។ គាត់មកខ្សឹបថា អ៊ូ! អាណិត តាឡាំង ស្លាប់ហើយ។ ខ្ញុំថាស្លាប់មូលហេតុអី? ខាំ ភួននោះឯង ថាទៅធ្វើការនេះ ទៅសម្រាកនោះ មិនទាន់បានធ្វើការទេ សម្រាកនៅផ្ទះសំណាក់នៅភ្នំពេញហ្នឹង តាភួន ដេកគ្រែមួយ តាឡាំង ដេកគ្រែមួយ ទាំង តាជួន នៅកៀកហ្នឹង។ ឃើញដែកតាមរទេះ រទេះឡាន ប៉ុណ្ណឹង។ ថា តាឡាំង ហ្នឹងថាមានកាំភ្លើងខ្លីនៅជាប់នឹងក្លៀកនេះ។--

**ស៖** អរគុណ។

**ឆ៖** អឺៗ ងាប់ហើយ បានយកកាំភ្លើងខ្លីហ្នឹងបាញ់ *(ឮមិនច្បាស់)* ស្លាប់ក្រោមទ្វារបន្ទប់។--

[១៤:២៨:៣០]

**ស៖** អរគុណលោកសាក្សី យើងមានភ័ស្តុតាងពីរឿងហ្នឹងហើយ។ អរគុណលោកបានពន្យល់៤ឆ្នាំមកហើយ គឺពីឆ្នាំ២០១២ យើងមិនទៅលម្អិតពីបញ្ហាហ្នឹងទៀតទេ ប៉ុន្តែខ្ញុំចង់បញ្ជាក់ចំណុចច្បាស់មួយពីលោកគឺ ជួន ដែលមកភ្នំពេញជាមួយលោក ហើយ ជួន ហ្នឹងបានទៅស-២១ នៅខែវិច្ឆិកា ឆ្នាំ

១៩៧៧។ ហើយនៅចុងឆ្នាំ១៩៧៧ហ្នឹង ប៉ុល ពត បានចាត់តាំងលោកទៅធ្វើជាគណៈតំបន់១០៥ <ជំនួស ឡាំង>។ តើអ៊ីចឹងត្រឹមត្រូវឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។ ពេល តាឡាំង ស្លាប់ហ្នឹងគាត់ចាត់ ប៉ុល ពត ចាត់តាំងហ្នឹង ខ្ញុំអត់ទទួលទេ។ ដល់តែមានសន្និបាតឆ្នាំ១៩៧៨នោះ បានគេតែងតាំងជា បោះជាប្រជាមតិហ្នឹង ភាគច្រើននេះ បោះជាប្រជាមតិនោះ យកខ្ញុំធ្វើជាប្រធាន<>ប្រកែកគេអត់បាន ក៏ធ្វើទៅ បាន២ខែ។

**ស៖** សូមអរគុណ ហើយយើងនឹងត្រឡប់មកសួរបញ្ហានេះបន្តិចទៀត។ នៅពេលដែលលោកជំនួស ឡាំង ធ្វើការនៅ<មន្ទីរ>តំបន់<> នៅចុងឆ្នាំ១៩៧៧នោះ <ហើយនិង>នៅពេលដែលលោកធ្វើជាលេខាស្រុក តើលោកធ្លាប់បានឃើញការជំនុំជម្រះ ឬក៏ដំណើរការកាត់ទោសអ្នកដែលបាត់ខ្លួនដែលលោកថាបាត់ទៅមិនដែលឃើញត្រឡប់មកវិញ គេមានជំនុំជម្រះកាត់ទោសអ្នកទាំងហ្នឹងទេ មុននឹងគេបាត់ខ្លួន?

**ឆ៖** អត់ឃើញឮថាកាត់ទោសកាត់អីទេ។ គេគ្រាន់បាត់ៗទៅ ហៅទៅបាត់ ហៅតែទៅរៀនទៅក៏បាត់ទៅ មិនឃើញថាកាត់ទោស ថាឲ្យវាមានទោសអ៊ីចេះ មានទោសអ៊ីចុះ កាត់ទោសឲ្យវាច្បាស់លាស់ អត់ៗឃើញ អត់ឮទេ។ ឃើញតែហៅទៅ ៗប្រជុំ ទៅរៀនសូត្រ បាត់ តែប៉ុណ្ណឹង បាត់។ មិនដឹងគេហៅ បាត់រឿងអី ដឹងថារឿងអី យើងអត់ដឹងរឿង ចេះតែបាត់មនុស្សនោះ មិនដឹងវារឿងអី។

[១៤:៣១:០៥]

**ស៖** តាមអ្វីដែលលោកដឹង ថាតើមានតុលាការ ឬក៏មានដំណើរការកាត់ក្តីអ្នកណាម្នាក់ទេ បើអ្នកណាម្នាក់ប្រព្រឹត្តកំហុស ឬទោសអ្វីមួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** អត់ដឹងទេ ដឹងថាកំហុសអីក៏អត់ដឹង ទោសអីក៏អត់ដឹង ឃើញតែថាហៅទៅគឺបាត់ តែប៉ុណ្ណឹង។ មិនដឹងទោស មិនដឹងពៃរ៍អី មិនដឹងរឿងអី បានគេបាត់មនុស្សនោះ យើងអត់ដឹង។

**ស៖** នៅពេលដែលមនុស្សបាត់ខ្លួន តើក្រុមគ្រួសារ ដូចជាប្រពន្ធកូនគេបាត់ខ្លួនដែរឬទេ?

**ឆ៖** អត់ទេ។

**ស៖** លោកសាក្សី ខ្ញុំអានជូនលោកស្តាប់។ ចម្លើយមួយរបស់កូនប្រុសរបស់លោក ឡាំង, ខាំ ផាន់ E3/57 អង់គ្លេស 002905*(ស៊ីក)*។ ខ្ញុំសង្ខេប<បែបនេះ។ ក្នុងអំឡុងពេលលោកផ្តល់សក្ខីកម្ម> មេធាវី នួន ជា បានអានឲ្យលោកស្តាប់នៅម៉ោង១៤:៣៥ នៅថ្ងៃចុងក្រោយនៃសវនាការស្តាប់សក្ខីកម្មរបស់លោក<គឺថ្ងៃទី១២ ខែមិថុនា>។ ឯកសារ E3/57 នេះឯងដែលកូនប្រុសរបស់ ឡាំង និយាយថា៖

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

"<នៅ>អំឡុងពេល<សម័យ> តាសារុន កាន់អំណាច <ការចាប់>ខ្លួនទាំងគ្រួសារ<ត្រូវបានគេធ្វើឡើង ប៉ុន្តែខ្ញុំមិនដឹងថា តើគ្រួសារទាំងនោះត្រូវបានគេយកទៅសម្លាប់នៅ>ទីណាទេ"។ ហើយ<មានសាក្សីផ្សេងទៀត>ដែលមកធ្វើសក្ខីកម្មហ្នឹង<រួមទាំងអ្នកមក>ពេលព្រឹកនេះ ហើយនិងម្សិលមិញ គេនិយាយអំពីប្រពន្ធ និងកូនៗរបស់បុរសក៏ត្រូវបានគេចាប់ខ្លួនដែរ បើសិនជាគេចាប់ប្ដីហើយហ្នឹង។ <តើប្រពន្ធ និងកូនៗត្រូវបានគេចាប់ខ្លួនដែរមែនទេ>?

[១៤:៣៣:២១]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំជំទាស់នឹង<ការជ្រើសរើសប្រើប្រាស់ភស្តុតាង>បែបនេះ។ <>តាវ៉ាល់ <ត្រូវបានចាប់ខ្លួនប៉ុន្តែប្រពន្ធគាត់មិនត្រូវបានចាប់ខ្លួនទេ។ ប្ដីរបស់> ប្រាក់ យុត <ត្រូវបានចាប់ខ្លួន ប៉ុន្តែ ប្រាក់ យុត មិនត្រូវបានចាប់ខ្លួនទេ>។ <យើងពេញចិត្តថា មានអ្វីមួយត្រូវធ្វើជាមួយនឹងតួនាទីជាប្រពន្ធរបស់កម្មាភិបាល។ ប្រពន្ធមិនត្រូវបានចាប់ខ្លួនយ៉ាងងាយស្រួល ដោយសារតែពួកគេជាប្រពន្ធនោះទេ។ ដូច្នេះ មានភស្តុតាងផ្សេងទៀតដែលគាំទ្រដល់ការជំទាស់នេះ>។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំនិយាយអំពីតំបន់១០៥ ដែលសាក្សីរូបនេះ<ទទួលខុសត្រូវ>។ យើងមានភ័ស្តុតាងនៅក្នុងចំណុចនេះ <គឺ>ប្រពន្ធ<>ត្រូវបានចាប់ខ្លួន ហើយកូន<ៗក៏>ត្រូវបានចាប់ខ្លួនដែរ<។> ឧទាហរណ៍ ចាន់ តួយ ហើយ នេត សាវ៉ាត <ទាំងពីរនាក់> បានធ្វើសក្ខីកម្មថា<មានការចាប់>កូន<ៗយកទៅជាមួយពួកគេដែរ>។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** តើត្រឹមត្រូវដែរឬទេ ថាកូនៗត្រូវបានចាប់ខ្លួននៅពេលដែលគេចាប់ខ្លួនកម្មាភិបាលណាមួយនោះ? សូមលោកសាក្សីឆ្លើយ។

**លោក សៅ សារុន៖**

**ឆ៖** បើនៅ១០៥ ដូចអត់មានប្រភេទហ្នឹងទេ ថាចាប់ប្ដីហើយ យកប្រពន្ធទៅទៀត អត់មានទេ។ តាមខ្ញុំឃើញណ៎ា តាំងពីសម័យ តាឡាំង នៅធ្វើជាប្រធានតំបន់ ដូចអត់ឃើញធ្វើអ៊ីចឹង។ មិនមែនខ្ញុំនិយាយអ៊ីចឹងកាន់ដៃកាន់ជើងទេ អត់ទេ ព្រោះវាអត់ឃើញ ភ្នែកវាអត់ឃើញ ត្រចៀកយើងអត់ឮ មិនឃើញថាចាប់ទាំងគ្រួៗទៅ អត់ឃើញ។ បើខេត្តគេផ្សេងៗ ខ្ញុំអត់ដឹងទេ ខ្ញុំនិយាយតែខេត្តមណ្ឌលគិរី។

[១៤:៣៥:២០]

**ស៖** លោកសាក្សី ខ្ញុំសូមអានចម្លើយចេញពីសាក្សីម្នាក់ទៀត ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាគឺ <E3/8651> ខ្មែរ 00042269 <ជាភាសាអង់គ្លេស 01156504>។ មុននឹងខ្ញុំអានចំណុចនេះ <ខ្ញុំសួរលោកថា> តើលោកបានត្រឡប់ទៅមណ្ឌលគិរីវិញ ជាចុងក្រោយនោះនៅពេលណា?

**ឆ៖** អានម្តងទៀតទៅ។

**ស៖** តើលោកទៅមណ្ឌលគិរីវិញនោះ ជាចុងក្រោយនៅពេលណា?

**ឆ៖** ទៅៗ រួចធ្វើការតែមួយថ្ងៃពីរហ្នឹង ក៏មកមណ្ឌលគិរីវិញ។

**ស៖** ខ្ញុំសូមព្យាយាមសួរសំណួរម្តងទៀត។ ខ្ញុំសួរលោកអំពីលោក ខ្ញុំសួរលោកថា នៅពេលណាដែលលោកទៅមណ្ឌលគិរីជាចុងក្រោយ? តើខែមុន ឆ្នាំមុន ឬក៏ឆ្នាំ១៩៧៩ ពេលណាជាពេលចុងក្រោយដែលលោកត្រឡប់ទៅមណ្ឌលគិរីវិញ?

**ប្រធានអង្គជំនុំ៖**

លោក សៅ សារុន ដែលសំណួរសួរអ៊ីចេះថា តាំងពីលោកចាកចេញពីមណ្ឌលគិរីមករហូតដល់សព្វថ្ងៃនេះ តើពេលណាដែលចុងក្រោយបំផុតដែលលោកបានទៅមណ្ឌលគិរីនោះ? តើលោកដែលទៅមណ្ឌលគិរីទេចុងក្រោយ ប៉ុន្មានឆ្នាំថ្មីៗនេះ ឬក៏ពេលចុងក្រោយលោកចាំទេ ថាទៅពេលណា?

**លោក សៅ សារុន៖**

**ស៖** អ៎! ដល់មកទឹកដីថៃហើយហ្នឹងអ្វី? ទៅមណ្ឌលគិរីឆ្នាំណាទេ ភ្លេចអស់ហើយ យូរហើយតាំងពីឆ្នាំណាទេ ភ្លេចភ្លាំងអស់ហើយ វាយូរហើយទៅ ពីរដង បីដងដែរ ទៅមណ្ឌលគិរី។

[១៤:៣៨:១៥]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមអរគុណ។ ប្រហែលជា<ត្រូវមានការពន្យល់ពីមូលហេតុដែល>លោកមិនចាំ<នេះ>។ ពីចម្លើយ<នេះ> សាក្សីនេះ<>និយាយអំពីលោកថា "<សៅ សារុន> គាត់អត់ហ៊ានទៅមណ្ឌលគិរីវិញទេ ដោយសារថាបាតដៃគាត់ប្រឡាក់ឈាម មនុស្សច្រើនណាស់"។ តើលោកអាចពន្យល់ជូនតុលាការបានទេ <ហេតុអ្វីមនុស្សនៅ>មណ្ឌលគិរី<គិតថា មានមនុស្សជាច្រើនស្លាប់ នៅពេលដែលលោកគ្រប់គ្រង>លេខាតំបន់<នោះ>?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

កុំអាលឆ្លើយតបលោក សៅ សារុន!

អញ្ជើញមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំចង់បានឯកសារយោងនូវសំណួរអំម្បាញ់មិញនេះ គាត់យកព័ត៌មានហ្នឹងមកពីណា ដើម្បីឲ្យយើងដឹងផង ថាតើអ្នកនិយាយហ្នឹងគាត់ឈ្មោះអី ដែលនិយាយសម្ដីបែបហ្នឹង ដើម្បីឲ្យយើងអាចឆ្លើយតបបាន។

[១៤:៣៩:១៨]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ខ្ញុំនឹងរកឈ្មោះ មិនមាននៅក្នុងកំណត់ត្រារបស់ខ្ញុំទេ។ <សូមបញ្ជាក់ថា>មិនមាន<ការ> បកជាភាសាបារាំងនៅឡើយ<ទេ> កំណត់ហេតុដែលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា E3/8651 ហ្នឹង។ សាក្សីហ្នឹងឈ្មោះ <សល់ វ៉ា> –អេស-អេ-អិល– ឈ្មោះ សល់ វ៉ា។ <តើលោកមានការពន្យល់យ៉ាងណាដែរ ដែលប្រជាជននៅ>ខេត្តមណ្ឌលគិរី<គិតថា មានមនុស្សជាច្រើនបានស្លាប់នៅក្នុងអំឡុង>ពេលដែលលោកធ្វើជាលេខាតំបន់<នោះ?>

**លោក សៅ សារុន៖**

**ឆ៖** ខ្ញុំសូមឆ្លើយ។ បញ្ហាហ្នឹង គឺអត់ការពិតទេ។ អ្នករាយការណ៍ហ្នឹង គឺរាយការណ៍ពន្លើសទេ។ ខ្ញុំទៅមណ្ឌលគិរីប៉ុន្មានដងហើយ ទៅដល់ណា។ ទៅលើកទី១នោះ ខ្ញុំនៅ៣ខែ នៅភូមិមណ្ឌលគិរី នៅដេកនៅទីរួមខេត្តហ្នឹង មួយអាទិត្យ។ បងប្អូនអ្នំ ចៅហ្វាយខេត្តមណ្ឌលគិរី និងខាងទាហាន មេទាហាននេះ ជប់លៀងខ្ញុំមួយថ្ងៃ។ ហើយមានបងៗប្អូន ជិះយន្តហោះពីភ្នំពេញ ជប់លៀងជាមួយគ្នា រាំទាំងពីព្រឹករាល់ល្ងាច។ ខ្ញុំទៅរហូតហ្នឹង មណ្ឌលគិរី មានពីណា ខ្ញុំអត់មានប្រឡាក់ឈាម មិនដែលសម្លាប់ប្រជាជនមណ្ឌលគិរីម្នាក់ទេ។ អ្នករាយការណ៍ហ្នឹង រាយការណ៍ចង់មានមុខ មានមាត់ទេ ចង់សម្លាប់តែគ្នាឯងទេ។ អ៊ីចឹងអ្ហេ! សម័យបីឆ្នាំ សម័យប៉ុលពត បានសម្លាប់គ្នាឯង មូលបង្កាច់--

**ស៖** *(គ្មានការបកប្រែ)*

**ឆ៖** ហើយរឿងបុគ្គលស្វនត្ត មូលបង្កាច់ ដើម្បីសម្លាប់តែជាតិគ្នាឯង ខ្មែរគ្នាឯង។ អត់ល្អទេ រាយការណ៍របៀបហ្នឹង។ អ្នករាយការណ៍ហ្នឹង មិនត្រឹមត្រូវទេ។ រាយការណ៍នេះ រាយការណ៍សម្លាប់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជនជាតិខ្មែរគ្នាឯងទេ។--

**ស៖** *(គ្មានការបកប្រែ)*

[១៤:៤១:៤៦]

**ប្រធានអង្គជំនុំ៖**

បាទៗ បានប៉ុណ្ណឹង។ បន្តទៀត។

**លោក សៅ សារុន៖**

**ឆ៖** បាទ ប៉ុណ្ណឹងហើយ គឺខ្ញុំអត់ប៉ុណ្ណឹង។ អាហ្នឹងខ្ញុំបញ្ជាក់ ដើម្បីឱ្យលោកតុលាការ ឱ្យពិនិត្យវិនិច្ឆ័យឱ្យច្បាស់ អ្នករាយការណ៍។--

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** *(គ្មានការបកប្រែ)*

**ឆ៖** រាយការណ៍ពន្លើស មួលបង្កាច់ សម្លាប់តែជាតិឯង ប្រជាជនឯង។ អត់ត្រឹមត្រូវទេ។ អាហ្នឹងឱ្យវិនិច្ឆ័យចុះ។ ខ្ញុំម៉េច! ទៅមណ្ឌលគិរីជារៀងរហូតនោះ ដេកនៅខេត្តនុំង មួយអាទិត្យ ទៅដេកនៅភូមិកំណើតខ្ញុំ៣ខែនៅហ្នឹង។

**ប្រធានអង្គជំនុំ៖**

បាទៗ បានហើយសាក្សី។ អរគុណច្រើន ហើយចាំស្តាប់សំណួរផ្សេងទៀត សំណួរបន្តទៀតណ៎ា។

**លោក សៅ សារុន៖**

បាទ។

[១៤:៤២:៤៤]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី ខ្ញុំសប្បាយណាស់ ដែលលោកមានការចងចាំភ្លាមៗអម្បាញ់មិញនេះ។ លោកថា គេ<>ចង់សម្លាប់តែប្រជាជនឯង តើ<អ្នកណាជាអ្នកចង់សម្លាប់>ប្រជាជនឯងហ្នឹង<>?<>

**លោក សៅ សារុន៖**

**ឆ៖** ខ្ញុំថា ចង់និយាយអ៊ីចេះ។ អ្នករករឿងហ្នឹងអ្នកស ចង់សម្លាប់តែជាតិឯង ប្រជាជនឯងនេះ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចង់មានមុខ មានមាត់ មានបុណ្យ មានស័ក្តិនេះ។ វាអាចទៅរាយការណ៍អ៊ីចឹង វាអត់សមហេតុ មើល! ដូចខ្ញុំថា គេរាយការណ៍ថា ខ្ញុំមិនប៉ានទៅមណ្ឌលគិរី ខ្ញុំប្រឡាក់ឈាម។ ខ្ញុំមិនដែលសម្លាប់ប្រជាជនមួយរូបផង។ ខ្ញុំទៅដេកនៅមណ្ឌលគិរី នៅភូមិកំណើតខ្ញុំបីខែ ដេកនៅទីរួមខេត្តហ្នឹង មួយអាទិត្យនៅហ្នឹង។ មានពីណាប្រឆាំងខ្ញុំ មានពីណាស្អប់ខ្ញុំ នៅស្រុកអូររាំងហ្នឹង ខ្ញុំទៅ គេពេលការ កូនចៅ ខ្ញុំទៅចូលរួមការជាមួយគេ ដល់ខ្ញុំទៅវិញទៅ គេក៏លើកភ្លៅក្របី អឺ!ភ្លៅ -- គេកាត់ក្របី លើកភ្លៅសាច់ក្របីហ្នឹងដាក់--

**ស៖** *(គ្មានការបកប្រែ)*

**ឆ៖** --ឡានខ្ញុំហ្នឹងមួយភ្លៅទៀត។ ធឹកតាំងពីប្រាំរហូតដល់ម៉ោងប្រាំបួន អ៊ូ! ប្រជាជនគេមិនដែលឃើញមុខនោះ មកអបអរសាទរ--

[១៤:៤៤:១៧]

**ប្រធានអង្គជំនុំ៖**

បាទ បានហើយៗ លោក សៅ សារុន។

**លោក សៅ សារុន៖**

--ឆ្អៀតទាំងលើកមួយភ្លៅសាច់ក្របី មួយភ្លៅឲ្យទៀត ដាក់ឡាន។

**ប្រធានអង្គជំនុំ៖**

បានហើយៗ ប៉ុណ្ណឹងសិនណ៎ា!

**លោក សៅ សារុន៖**

ខ្ញុំណ៎ះ! រាយការណ៍ថាខ្ញុំមិនប៉ានទៅមណ្ឌលគិរី ខ្ញុំមានរឿងអីមិនប៉ានទៅភូមិកំណើត ស្រុកកំណើតខ្ញុំនៅហ្នឹង។

**ប្រធានអង្គជំនុំ៖**

បានហើយៗ លោក សៅ សារុន!

**លោក សៅ សារុន៖**

ចៅហ្វាយខេត្តហ្នឹងឈ្មោះ *(ឮមិនច្បាស់)*។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការត្រឹម

នេះ។ ហើយសវនាការសម្រាកពីពេលនេះតទៅ រហូតដល់ម៉ោងបី ម៉ោងបីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

លោក សៅ សារុន ហើយនិងលោក សំណាង ហើយលោកមេធាវីប្រឹក្សាសាក្សី គឺយើងសម្រាកពីម៉ោងនេះទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ដូច្នេះសូមលោក អស់លោកទាំងអស់ អញ្ជើញមកដល់កន្លែងផ្តល់សក្ខីកម្មឱ្យបានមុនម៉ោងបីណា៎ះ!

សម្រាកចុះ!

**លោក ញ៉ែម សំណាង៖**

បាទ លោកប្រធាន។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៥ នាទី ដល់ម៉ោង ១៥:០៤ នាទី)*

[១៥:០៤:១០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សួស្តីលោក សៅ សារុន តើលោកបានត្រៀមខ្លួនរួចហើយឬនៅ?

**លោក សៅ សារុន៖**

បាទ ត្រៀមខ្លួនហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក សៅ សារុន។ ជាបន្តទៅនេះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោក សៅ សារុន ក្រោយ ឡាំង ស្តាប់ទៅលោកទទួលតួនាទីជំនួសគាត់។ តើលោកមានបានទទួលការរិះគន់ណាមួយ<ពីមជ្ឈិម> ពី ប៉ុល ពត <ឬ> នួន ជា <ទាក់ទងទៅនឹងការបំពេញការងាររបស់លោកទេ> ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៥:០៥:១៧]

**លោក សៅ សារុន៖**

**ឆ៖** បាទ គឺខ្ញុំសូមឆ្លើយ។ គឺក្រោយពី តាឡាំង ស្លាប់ទៅ គេតែងតាំងខ្ញុំនេះមកទទួលខុសត្រូវនៅតំបន់។ បញ្ហាមកមានតែថាណែនាំឲ្យគ្រប់គ្រងប្រជាជនឲ្យល្អ ដោះស្រាយសេដ្ឋកិច្ចជីវភាពជូនប្រជាពលរដ្ឋ មិនឲ្យអត់ មិនឲ្យឃ្លាន។ គេណែនាំតែប៉ុណ្ណឹង មិនឃើញនិយាយពីរឿងអី និយាយតែពីរឿងកសាងភូមិឋានឲ្យរីកចម្រើន កុំឲ្យមានប្រជាពលរដ្ឋអត់បាយ អត់ទឹកតទៅទៀត ពីព្រោះប្រទេសយើងឯករាជ្យ សន្តិភាពហើយ មិនគួរឲ្យប្រជាជនអត់បាយ អត់ទឹកទេ។ គាត់មានតែណែនាំតែប៉ុណ្ណឹង។ បាទសូមអស់។

**ស៖** សូមអរគុណលោកសាក្សី។ លោកមិនទាន់ឆ្លើយសំណួរខ្ញុំនៅឡើយទេ។ ឥឡូវសូមលោកយកចិត្តទុកដាក់ស្តាប់បន្តិច ពីព្រោះថាលោកចង់ឲ្យចប់នៅថ្ងៃស្អែក ហើយយើងខ្ញុំក៏ចង់ដូច្នេះដែរ។ សំណួរខ្ញុំគឺ តើ ប៉ុល ពត, នួន ជា ធ្លាប់ទិតៀនលោកអំពីការងារដែលលោកបំពេញដែរឬទេ ក្រោយពីលោកទទួលតួនាទីនេះពី ឡាំង មក?

**ឆ៖** បាទ គឺខ្ញុំ ឥឡូវចង់ឲ្យលោកអានម្តងទៀត កុំអានវែងពេក អានខ្លីៗ ខ្ញុំវា ១បាត់ការចងចាំ។

**ស៖** លោក សារុន តើ ប៉ុល ពត ធ្លាប់ទិតៀនលោកទេ?

**ឆ៖** ទេ, បាទខ្ញុំមិនដែលឃើញទិតៀនអីទេ មានតែការណែនាំតែប៉ុណ្ណឹង។ ថាទិតៀនអ៊ីចេះអ៊ីចុះ មិនឃើញទេ ពីព្រោះខ្ញុំក៏ធ្វើការរយៈខ្លីដែរ តែពីរខែហ្នឹង។

[១៥:០៧:៣៨]

**ស៖** សូមអរគុណលោក ក៏ប៉ុន្តែ ឯកសារបញ្ជាក់ថា លោកបានទទួលតួនាទីនេះ គឺមួយឆ្នាំក្រោយពី ជួន នៅរស់រានមានជីវិតនៅឡើយនោះ។ លោក សារុន?

**ឆ៖** បាទ ខ្ញុំទទួល*(ឮមិនច្បាស់)*--

**ស៖** សូមទោសៗ ខ្ញុំនឹងសួរបន្តទៅទៀត។ ឥឡូវនេះ ខ្ញុំចូលនិយាយពីឆ្នាំ១៩៧៥ នៅពេលដែល ប៉ុល ពត ឲ្យលោកទទួលតំណែងនេះបន្ត។ ហើយសក្ខីកម្មមុនៗថា <លោកបានប្រាប់> ប៉ុល ពត ថា លោកមិនមានលក្ខណៈសម្បត្តិត្រឹមត្រូវទេ <ហើយលោកបានស្នើសុំ> កុំចាត់តាំងលោកអី។ តើមានហេតុផលណាដែលនាំឲ្យលោក<មិនចង់ទទួលតំណែងនោះ>?

**ឆ៖** បាទ អាហ្នឹងក្រោយ តាឡាំង ស្លាប់ ខ្ញុំបានតវ៉ាជាមួយគាត់មែន ពីព្រោះខ្ញុំវាអត់មាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សមត្ថភាព វប្បធម៌ អក្សរសាស្ត្រក៏ខ្ញុំក៏ទាប ត្រឹមតែចេះសរសេរ ចេះអាន ខ្ញុំមិនចង់មកទទួលការងារតំបន់ទេ។ ខ្ញុំថា ខ្ញុំអត់ចេះ ឲ្យលោករកគេអ្នកផ្សេងធ្វើទៅ ខ្ញុំអត់ធ្វើទេ។ ខ្ញុំអត់ធ្វើមែន ទាល់តែមានការសន្និបាត៧៨ហ្នឹង បានខ្ញុំ គេបោះប្រជាមតិភាគច្រើនថាឲ្យខ្ញុំធ្វើ ខ្ញុំធ្វើបានពីរខែ ល្មមយួនចូលរំដោះប្រទេស។

**ស៖** ដូច្នេះរឿងដែល ប៉ុល ពត ឲ្យលោកទទួលតួនាទីនុ៎ងនៅក្នុងឆ្នាំ១៩៧៧ ក្រោយពី ឡាំង ស្លាប់ទៅ ហើយ<តួនាទីរបស់>លោក<ត្រូវបានបញ្ជាក់>នៅខែកញ្ញា ៧៨។ តើលោកយល់ថា គណៈមជ្ឈិម<>សប្បាយចិត្តណាស់ <ចំពោះអ្វីដែល>លោក<បាន>បំពេញការងារហ្នឹង<រហូតដល់ពេលនោះ គឺខែកញ្ញានោះ>?

**ឆ៖** អ៊ីចឹងគឺខ្ញុំបានជដែកមែន។ ខ្ញុំថាខ្ញុំមិនចង់ធ្វើ ពីព្រោះវាអត់ចេះ អត់ដឹង អត់មានសមត្ថភាព គេដឹង -- គេពេញចិត្ត ឬមិនពេញចិត្តទេណា ចេះតែតវ៉ាទៅ រឿងខ្ញុំធ្វើ។ ទាល់តែមានការតែងតាំងសន្និបាតខែ៩ ឆ្នាំ១៩៧៨ បានខ្ញុំទទួលធ្វើ ធ្វើបាន២ខែ ខែ៩ សន្និបាតនៅភ្នំពេញ ខែ១០ ខ្ញុំមកទទួលខុសត្រូវ នៅបាន២ខែ, ខែ១០, ខែ១១, ខែ១២, ខែ០១ ល្មមយួនចូលរំដោះ។

[១៥:១០:៥១]

**ស៖** លោកសាក្សីនិយាយអំពីកិច្ចប្រជុំលើកទី១ ជាមួយ ប៉ុល ពត ក្រោយពី ឡាំង ស្លាប់ទៅ នៅពេលដែលលោកទៅជួប ប៉ុល ពត ជាមួយ ជួន លោកបាន<>ប្រាប់ ប៉ុល ពត ថាលោកមិនមានលក្ខណៈសម្បត្តិត្រឹមត្រូវទេ។ ប៉ុន្តែ ប៉ុល ពត ថា តាសាន មេបញ្ជាការកងពល៩២០ នឹងជួយកិច្ចការលោក។ តើ ប៉ុល ពត មានប្រាប់លោកថា មេបញ្ជាការកងពល៩២០ ជួយធ្វើការងារអ្វីខ្លះដល់លោកក្នុងតួនាទីជាប្រធានតំបន់នេះដែរទេ?

**ឆ៖** បាទ មានអ៊ីចឹងមែន។ ខ្ញុំ លោក ប៉ុល ពត ក៏ឲ្យអាខាង៩២០ជួយ ខ្ញុំថា ជួយក៏ជួយ ខ្ញុំវាអត់ចេះ គេក៏ឲ្យជួយមែន។ ខ្ញុំចេះតែចចេស ចចេសជាមួយគាត់រហូតហ្នឹង ទាល់តែមានការតែងតាំងហ្នឹងបានខ្ញុំទទួលធ្វើ។

**ស៖** លោកសាក្សី តើកងទ័ពកងពល៩២០ ជួយធ្វើការលោកអ្វីខ្លះដែរ?

**ឆ៖** ធ្វើខាងការអប់រំ បើកសាលារៀន កម្មាភិបាលនៅក្នុងតំបន់ទាំងមូល។

**ស៖** សំណួរខ្ញុំសួរថាយ៉ាងដូច្នេះ តើ តាសាន មេបញ្ជាការកងពល៩២០ ជួយកិច្ចការលោកអ្វីខ្លះ? លោកថា<គាត់>ជួយបង្រៀននៅតាមសាលា<ឬ>?

**ឆ៖** វៀន អាហ្នឹងគឺបំពាក់បំប៉នខាងគោលជំហរដឹកនាំប្រជាពលរដ្ឋ ដឹកនាំធ្វើស្រែ ធ្វើចម្ការ ធ្វើគ្រប់បែបគ្រប់យ៉ាងណា គ្រប់គ្រងប្រជាជនឲ្យបានល្អ កុំឲ្យមានអត់បាយក្រហាយទឹក។ គាត់ចេះតែណែនាំរហូត ជួយ សំខាន់គឺជួយខាងសេដ្ឋកិច្ចនេះឯង។

[១៥:១៣:២២]

**ស៖** តើកងទ័ពចូលរួមពាក់ព័ន្ធក្នុងកិច្ចការនេះដែរទេ?

**ឆ៖** បាទ សួរ លើកសំណួរម្តងទៀត អត់យល់បញ្ហា។

**ស៖** ខ្ញុំសូមបន្តទៅមុខចុះលោក ដោយសារពេលវេលាខ្ញុំខ្លី។ តើ ប៉ុល ពត និងនួន ជា បានប្រាប់លោកអ្វីខ្លះដែរ អំពីវៀតណាម?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ អាហ្នឹងគាត់បានបញ្ជាក់មែន *(ឮមិនច្បាស់)*។ គេថា វៀតណាមមានទិសដៅឈ្លានពានទឹកដីកម្ពុជាយើងហើយ មានទិសដៅគ្រប់គ្រងកម្ពុជាយើង យកកម្ពុជាយើងហើយ អាហ្នឹងគេប្រាប់មែន។

**ស៖** តើពួកគាត់និយាយ<អំពីបញ្ហា>នេះនៅក្នុងអង្គប្រជុំ ដែលលោកបានចូលរួមប្រជុំរយៈពេលបីបួនខែ<> ក្រោយពី ឡាំង ស្លាប់ទៅ<ឬ?> <>លោកថា<លោកបានទៅចូលរួមអង្គប្រជុំមួយហើយ>នៅក្នុងអង្គប្រជុំហ្នឹង ខៀវ សំផន ក៏មានវត្តមានដែរ។ តើពួកគាត់<ពិភាក្សាអំពីគោលបំណងរបស់វៀតណាម ក្នុង>ការឈ្លានពាន<ទេ ក្នុងកិច្ចប្រជុំនោះ>?

**ឆ៖** បាទ បានប្រាប់មែន។ ឮសួរតាម -- គាត់ប្រាប់ផង ភ្នែក ត្រចៀកយើងឮ<> ភ្នែកក៏ឃើញផង វាឈ្លានពានតាមព្រំដែន វ៉ៃជាបន្តបន្ទាប់ហ្នឹង។

**ស៖** តើពួកគាត់បានពិភាក្សាជាមួយលោកដែរទេ <នៅ>ក្នុងអង្គប្រជុំ<ដែល>មានវត្តមានប៉ុល ពត, <នួន ជា,> ខៀវ សំផន, សុន សេន ថា<ខ្មែរក្រហមបានឈ្លានពានចូល>វៀតណាម <គឺខ្មែរក្រហម>ប្រហារទៅលើវៀតណាម<>?

[១៥:១៥:៣០]

**ឆ៖** បាទ ប្រាប់មែន។ យើងប្រាប់ហើយ គឺយើងទៅឲ្យរៀបចំ<>វ៉ៃតទល់។

**ស៖** តើ<>ពួកគាត់មានបានប្រាប់ថា កងទ័ព<ខ្មែរក្រហម>ហ្នឹងបានចូលទៅប្រព្រឹត្តអំពើសម្លាប់រង្គាលនៅក្នុងប្រទេសវៀតណាម<ប្រឆាំងនឹងជនស៊ីវិល>ដែរទេ?

**ឆ៖** បញ្ហាហ្នឹង ខ្ញុំអត់យល់ទេ។ ខ្ញុំនៅ អត់ៗយល់ទេ រឿងថា មានកងទ័ពចូលទៅទប់ទល់នឹង

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រទេសវៀតណាមអី ខ្ញុំអត់យល់។

**ស៖** ខ្ញុំសូមអានសម្រង់ចេញពីសៀវភៅមួយដែលសរសេរឡើងដោយលោក ខៀវ សំផន E3/18, ERN ខ្មែរ 001038849 *(ស៊ីក)*, បារាំង 00595446, អង់គ្លេស គឺនៅត្រង់ទំព័រ៧៣។ ខៀវ សំផន បានសរសេរដូចតទៅ៖ "នេះគឺអ្វីដែលខ្ញុំបានរៀនសូត្រអំពីការវាយប្រហារ<របស់កម្ពុជា ទៅលើភូមិទិញបៀន>ខេត្ត<អានយ៉ាង> នៅចុងខែមេសា ៧៧។ វៀតណាម<បានឆ្លើយតបការវាយប្រហារនេះ ដោយប្រើប្រាស់>យន្តហោះ<អា-៣៧>ដែលរឹបអូសបានក្រោយសង្គ្រាម<អាមេរិក>។ <ការវាយប្រហារគ្នាទៅវិញទៅមកនេះ កើតមានឡើងក្រោយពីមានការឈ្លានពានយ៉ាង>បង្ហូរឈាម<ពី>កម្ពុជា<នៅចុងខែកញ្ញា ទៅលើជនជាតិវៀតណាមនៅក្នុងខេត្តតាយនីង និង>ខេត្តហាទៀង។ <>ភាគីទាំងពីរបានប្រព្រឹត្តអំពើសាហាវព្រៃផ្សៃ ហើយដែលត្រូវតែផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរ។"

ព្រឹត្តិការណ៍នេះ គឺច្បាស់ហើយថា កងទ័ពខ្មែរក្រហមបានចូលទៅតាមភូមិវៀតណាម នៅតាមព្រំដែន ដោយប្រព្រឹត្តអំពើកាប់សម្លាប់ទៅលើជនស៊ីវិលវៀតណាម។ ត្រង់នេះលោក ខៀវ សំផន និយាយអំពីការវាយប្រហារក្នុងខែមេសា <និង> កញ្ញា ឆ្នាំ៧៧។ ហើយលោកក៏ត្រូវបានកោះហៅឲ្យមកភ្នំពេញ ក្រោយពី ឡាំង ស្លាប់ទៅនៅ<ចុង>ឆ្នាំ១៩៧៧។ តើពួកគាត់ (ប៉ុល ពត, នួន ជា) មាននិយាយប្រាប់លោកអំពីការវាយប្រហារនេះទេ? <តើលោកចាំអ្វីខ្លះអំពីរឿងនោះ?>

[១៥:១៨:២៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះការតាំងសំណួរនេះ ដោយសារដែលលោក ខៀវ សំផន លើកឡើងអំពីពាក្យសម្តីរបស់ ណាយ៉ាន់ ចាន់ដា មិនមែនពីឯកសារសម័យកាលកម្ពុជាប្រជាធិបតេយ្យនាពេលនោះទេ។ សំណួរនេះស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះនេះហើយ។ ហើយមួយទៀត សំខាន់បំផុតគឺឈ្មោះខេត្តហាទៀងនេះ គឺថា ណាយ៉ាន់ ចាន់ដា បាននិយាយ ហើយខេត្តនេះនៅឆ្ងាយពីមណ្ឌលគិរី <និងរតនគិរី>ណាស់។ ហើយសាក្សីរូបនេះ គាត់មានចំណេះដឹង<> មានកម្រិតនៅ<ទាក់ទងទៅនឹងកត្តាភូមិសាស្ត្រ ហើយខេត្តដែល>ណាយ៉ាន់ ចាន់ដា<បានពិភាក្សានេះ>

<គឺជា>ខេត្ត<>ឆ្ងាយពីខេត្តមណ្ឌលគិរី<និងរតនគិរី>ណាស់។

**លោក នីកូឡាស គូមជែន៖**

<ជាថ្មីម្តងទៀត នេះគឺជាសៀវភៅដែលសរសេរដោយខៀវ សំផន។>

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់! កំពុងមានមកណេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបន្ថែមទៅនឹងការជំទាស់របស់មេធាវី កូប៉េ។ មិនមែនដោយសារតែមានសៀវភៅដែលសរសេរដោយ ខៀវ សំផន យើងត្រូវដកបរិបទចេញនោះទេ។ ដូចដែលយើងធ្វើនៅក្នុងសវនាការស្តីអំពីការឯកសារអ៊ីចឹង យើងត្រូវដឹងថាតើក្នុងលក្ខខណ្ឌបែបណាដែលមានបញ្ជាក់នៅក្នុងឃ្លាណាមួយនោះ ព្រោះថាលោក ខៀវ សំផន គាត់បាននិយាយអំពីហេតុការណ៍ដែលគាត់ទទួលបានការពន្យល់ពីអ្នកណាម្នាក់<នៅពេលក្រោយមក>។ អ៊ីចឹងយើងមិនត្រូវយកព័ត៌មានហ្នឹង មកថាជាព័ត៌មានដែលកើតមាននៅសម័យកម្ពុជាប្រជាធិបតេយ្យទេ។

**លោក នីកូឡាស គូមជែន៖**

នេះជាសៀវភៅរបស់លោក ខៀវ សំផន ដែលជាប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យដែលគាត់មានស្វាមីភក្តិចំពោះខ្មែរក្រហមច្រើនឆ្នាំក្រោយមកទៀត ហើយគាត់រៀបរាប់អំពីហេតុការណ៍ដែលបានកើតឡើងនៅពេលនោះ។ ហើយកាលនោះ <តាម>សាក្សី<នេះ>និយាយ <គាត់ក៏មានវត្តមានក្នុង>កិច្ចប្រជុំនិយាយអំពី<ជនជាតិ>វៀតណាម <និង>អំពីស្ថានការណ៍<នោះ។ ដូច្នេះហើយឃើញថា> វាមានភាពពាក់ព័ន្ធ<ច្បាស់ណាស់>។ ហើយខ្ញុំ<យល់ពីមូលហេតុដែល>មេធាវីបានជំទាស់ <ពីព្រោះលោក> ខៀវ សំផន <នៅទីនេះបាន>និយាយថា <មិនអាចបដិសេធបានដែលថា ខ្មែរក្រហមបានប្រព្រឹត្តិអំពើព្រៃផ្សៃប្រឆាំងនឹងជនស៊ីវិល>។ ប៉ុន្តែ<ភាពពាក់ព័ន្ធនោះគឺគោលនយោបាយរបស់ពួកគេចំពោះ>ជនជាតិវៀតណាម <និងជនជាតិវៀតណាមដែលគេបានរកឃើញ>នៅក្នុងព្រំដែនរបស់កម្ពុជា<>។

[១៥:២១:០៦]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមបញ្ជាក់ម្តងទៀត។ សំណួរគឺថា <>មិន<មែនជាអ្វីដែល>លោក ខៀវ

សំផន <បាននិយាយ នៅពេលដែល>គាត់<>សរសេរសៀវភៅ<របស់គាត់នោះ>ទេ។ <សំណួរ>គឺថាតើគាត់<ចង់និយាយអ្វី នៅពេលដែលព្រឹត្តិការណ៍នេះកើតឡើង>។ <សាក្សីបានចង្អុលបញ្ជាក់ថា> គាត់មិនដឹងអំពីការលុកលុយរបស់កម្ពុជាចូលទៅវៀតណាមទេ។ ហើយកាលដែលលើកឡើងថា លោក ខៀវ សំផន បានសរសេរសៀវភៅពាក់ព័ន្ធនឹងហេតុការណ៍នៅឆ្នាំនេះ ឆ្នាំនោះ <ក្រោយពីអង្គហេតុនោះ គឺមិនឆ្លើយតបទៅនឹងតថភាពនៅចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩>ទេ។ អ៊ីចឹងការបង្ហាញ<ព្រឹត្តិការណ៍នេះ> ថាជាចម្លើយរបស់លោក ខៀវ សំផន ជាប្រមុខរដ្ឋហ្នឹង វាមិន<ស្របទៅនឹងការពិតជាក់ស្ដែង>ទេ។ <នេះគឺយើងកំពុងនិយាយអំពី ខៀវ សំផន> គឺថា<ច្រើនឆ្នាំ>ក្រោយ<ព្រឹត្តិការណ៍នោះ គាត់បាន> បានធ្វើការស្រាវជ្រាវ <និយាយអំពីព្រឹត្តិការណ៍ជាក់លាក់មួយចំនួន គឺ>មិនមែននៅពេលកើតហេតុការណ៍នោះទេ ដែលលោកខៀវ សំផន គាត់សរសេរនោះ។ ដូច្នេះកាលដែលលើកយកឃ្លាហ្នឹងមកឲ្យសាក្សីស្ដាប់ គឺធ្វើឲ្យគាត់មានការភ័ន្តច្រឡំ ធ្វើឲ្យសាក្សីគាត់គិតថា គឺការសរសេរហ្នឹង សរសេរដោយលោក ខៀវ សំផន នៅសម័យកើតហេតុនោះតែម្ដង។ <សំណួរគឺមិនមែនសួរថាតើ> ខៀវ សំផន ជាអ្នកសរសេរឬក៏អត់ទេ។ <សំណួរ>គឺ<នៅពេលដែល>គាត់<ធ្វើសេចក្ដីថ្លែងការណ៍នោះ និងផ្អែកទៅលើ>ព័ត៌មាន<ដែល>គាត់ទទួលបាន<នៅពេលក្រោយមក>។

[១៥:២២:៣៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៥:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីសម្រេច ចេញដីកាសម្រេចលើសេចក្ដីជំទាស់តវ៉ារបស់សហមេធាវីការពារក្ដី ចំពោះសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះសាក្សី សៅ សារុន។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះចង់ឲ្យសហព្រះរាជអាជ្ញារៀបចំសំណួររបស់ខ្លួនឡើងវិញ ដោយសារតែសៀវភៅរបស់លោក ខៀវ សំផន ត្រូវបានសរសេរប៉ុន្មានឆ្នាំក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះយើងមិនអាចទាញសេចក្ដីសន្និដ្ឋានចេញពីសៀវភៅនោះបានថា លោក ខៀវ សំផន បានដឹងឮអំពីការលុកលុយរបស់កម្ពុជាប្រជាធិបតេយ្យ ទៅក្នុងប្រទេសវៀតណាមនោះទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដូច្នេះសហព្រះរាជអាជ្ញា សូមរៀបចំសំណួរឡើងវិញ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី សំណួររបស់ខ្ញុំហ្នឹង គឺ<ខ្ញុំអានចេញ>ពីសៀវភៅនេះ ដែល ខៀវ សំផន និយាយអំពីការវាយប្រហារទៅក្នុងភូមិនានារបស់វៀតណាម នៅក្នុងខែមេសា <និងខែកញ្ញា> ឆ្នាំ ១៩៧៧។ ថាតើលោកចងចាំពីការពិភាក្សាអ្វីទាក់ទងទៅនឹងការវាយចូលទៅដល់ក្នុងប្រទេសវៀតណាម ក្នុងឆ្នាំ១៩៧៧ដែរឬទេ?

[១៥:២៧:៣០]

**ប្រធានអង្គជំនុំ៖**

សួស្តី លោកសាក្សី តើលោកស្តាប់សំណួរបានដែរទេ លោក សៅ សារុន?

**លោក សៅ សារុន៖**

មិនបានទេ។ ខ្ញុំសំណូមពរឲ្យលើកសំណួរខ្លីៗបន្តិច។

<>

**ប្រធានអង្គជំនុំ៖**

លោក សៅ សារុន ចាំស្តាប់សំណួរ សហព្រះរាជអាជ្ញាអន្តរជាតិតាំងសំណួរសាជាថ្មីម្តងទៀត។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ខ្ញុំនឹងសួរសំណួរមួយទៀត។ តើ ប៉ុល ពត ធ្លាប់និយាយអំពីការស្អប់ជនជាតិវៀតណាម ដែរឬទេ?

**លោក សៅ សារុន៖**

**ឆ៖** បាទ គាត់មិនមែននិយាយ គឺស្អប់ជនជាតិទេ គឺស្អប់វៀតណាម អ្នកឈ្លានពានទឹកដីកម្ពុជា។

[១៥:២៨:៤០]

**ស៖** លោកសាក្សី ខ្ញុំនឹងអានចេញពីសៀវភៅរបស់ ថេត សម្បត្តិ ហើយនិង ជីណា ចន E3/4202 ជាសេចក្តីដកស្រង់ជាភាសាខ្មែរ ERN 00858265, បារាំង 00849385, ភាសាអង់គ្លេស នៅទំព័រ៥១។ នៅខាងក្រោម និយាយ សូមដកស្រង់៖ "ខ្ញុំស្អប់<យុវជន>វៀតណាម តាំងពីពេលដែលខ្ញុំក្មេងម្ល៉េះ។<>(ប៉ុល ពត ប្រាប់ នួន ជា) អ៊ីចឹង ខ្ញុំមិនចូលចិត្តពួកគេទេ ពីព្រោះពួកវៀតណាម<ឈ្លើយ ហើយឆ្លាតជ្រុល មានល្បិចកល និងមិនសុចរិត ពេលលេងទាត់បាត់ជាមួយខ្ញុំ និងជាមួយ>ក្មេងៗ

កម្ពុជា។

តើលោកសាក្សី នៅចាំដែរឬទេ តើ ប៉ុល ពត និយាយថា វៀតណាម គឺមនុស្សមានឧបាយកល មានល្បិចកល ហើយគាត់ស្អប់វៀតណាម? តើលោកធ្លាប់ឮការពិភាក្សាបែបនេះទេ?

**ឆ៖** ទេ គឺខ្ញុំអត់ឮទេ ពីព្រោះបញ្ហា វាអត់ឮទេ ឮតែថា--

**ស៖** ម្យ៉ាងវិញទៀត លោកបាន<>ប្រាប់យើងថា លោកចូលចលនាខ្មែរក្រហម ក្នុងឆ្នាំ ១៩៦៨។ ចាប់ពីឆ្នាំ១៩៦៨ ដល់ដើម<ទសវត្សរ៍>១៩៧០ តើលោកធ្វើការជាមួយកងទ័ពវៀតណាម កុម្មុយនីស្តដែលមានទីតាំងនៅកម្ពុជានាកាលណោះដែរឬទេ? <តើពួកគេជាសម្ព័ន្ធមិត្តរបស់លោកឬ?>

**ឆ៖** អត់បានធ្វើទេខ្ញុំ ពីព្រោះខ្ញុំនៅខាងស្រុកនេះ អត់បានធ្វើជាមួយខាងតំបន់ទេ គេធ្វើតាំងពីមុនមក ខ្ញុំអត់បានធ្វើទេ។

**ស៖** សំណួររបស់ខ្ញុំ ៗសួរអំពីការវាយប្រយុទ្ធប្រឆាំងនឹងកងកម្លាំង លន់ នល់។ តើលោកចងសម្ព័ន្ធភាពជាមួយកងកម្លាំងកុម្មុយនីស្តវៀតណាមនៅក្នុងខេត្តមណ្ឌលគិរីដែរទេ កាលណោះ?

**ឆ៖** បាទ អាហ្នឹងបានរួមគ្នាមែន វ៉ៃអាមេរិកហ្នឹង គឺរួមគ្នាវ៉ៃទាំងវៀតណាម ទាំងកម្ពុជាយើង។

[១៥:៣១:២៤]

**ស៖** តើ នួន ជា ធ្លាប់ពិភាក្សា<ជាមួយលោក>អំពី<ពេលវេលាដែលគាត់>នៅក្នុងប្រទេសវៀតណាម<ទេ>?

**ឆ៖** អត់ដឹងទេរឿងនេះ អត់ដឹងគេពិភាក្សាយ៉ាងម៉េចទេ អត់ដឹង។

**ស៖** ឥឡូវនេះ ខ្ញុំនឹងបន្តទៅមុខទៀតសួរលោកសាក្សីអំពីខែកញ្ញា ឆ្នាំ១៩៧៨ ជាការប្រជុំមួយដែលលោកបានចូលរួមនៅទីក្រុងភ្នំពេញ។ លោកនិយាយថា៖ “នៅការប្រជុំនោះ ប៉ុល ពត <ស្នើឲ្យ> លោក<>អានចម្លើយសារភាពដែលឆ្លើយដាក់លោក, តាអ៊ុន ហើយនិង នាង ផងដែរ។” តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ ថាវាមានមែន។

**ស៖** តើ ប៉ុល ពត បានចង្អុលបង្ហាញថា <>បុគ្គលហ្នឹង<នៅកន្លែង>ណាទេ ពេលដែលគេឆ្លើយសារភាពហ្នឹង<>?

**ឆ៖** អត់បញ្ជាក់ទេ ប្រភពចម្លើយហ្នឹងដឹងមានមកពីប្រភពណា យើងអត់ដឹង ឃើញតែថាឃើញចម្លើយហ្នឹង គេសរសេរជាសៀវភៅមកជូនមកឲ្យយើងមើល។

**សៈ** តើសេចក្ដីសារភាពនោះពិតដែរឬទេ <ចំពោះ>អ្វីដែល<និយាយអំពី>លោក<នោះ>?

**ឆៈ** ដឹងពិតមិនពិតទេ ឃើញតែចម្លើយហ្នឹង ឆ្លើយទៅពាសវាលពាសកាលទៅ ជាប់ទាំងខ្ញុំទាំងអីហ្នឹង។ លោក ប៉ុល ពត គាត់យកសៀវភៅហ្នឹងមកឱ្យអាន មកពិនិត្យទៅវា អាដែលជាប់ឈ្មោះចម្លើយនេះ វាអត់ឃើញមានអី ចេះតែឆ្លើយមកដាក់ៗ។

[១៥:៣៣:៤៧]

**សៈ** នៅពេលដែលលោកនិយាយថា គេឆ្លើយដាក់លោក <តើលោកចង់និយាយថា>គេ<បានកំណត់ឈ្មោះ>លោកនៅក្នុងខ្សែ ឬក្នុងក្រុមមនុស្សមួយក្រុមដែលប្រឆាំង<នឹងបក្សឬ>?

**ឆៈ** តាមទិសដៅគេនេះ គេអ៊ីចឹងហើយ ពីព្រោះវា ចម្លើយគេហ្នឹង វាដាក់ឈ្មោះគេច្រើនណាស់ឱ្យតែថាកម្មាភិបាល គឺដាក់ឈ្មោះទាំងអស់ហ្នឹង។ បើយកមកពិនិត្យទៅ វាមានស្អី មកពិភាក្សាគ្នា តាមចម្លើយគេ វាអត់មានហេតុផលអីហ្នឹង យើងទៅក្បត់ជាតិហ្នឹង និងចូលដៃចូលជើងជាមួយយួនផងនោះ។ ចេះតែឆ្លើយទៅ មកតែផ្ដេសផ្ដាស។

**សៈ** តើមានអ្នកណាម្នាក់ព្យាយាមជ្រើសរើសលោកឱ្យ<ចូលរួមក្នុង>ផែនការផ្ដួលរំលំ<មេដឹកនាំ>បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆៈ** អត់ដែលឮ អត់ដែលឃើញគេរើយ អត់ឮទេ។

**សៈ** តើ ប៉ុល ពត មានប្រាប់លោកអំពីមូលហេតុ ថាហេតុអ្វីបានជាគាត់បង្ហាញ<>ចម្លើយសារភាពហ្នឹងទៅលោកទេ?

**ឆៈ** អត់ឃើញទេ មិនឮទេ។ ឃើញតែសៀវភៅ ឃើញតែភ្ជាប់តែចម្លើយ ឈ្មោះអីតែប៉ុណ្ណឹង។

**សៈ** តើនេះដោយសារ ប៉ុល ពត គិតថា ចម្លើយសារភាពនេះវាមិនពិត គាត់មិនជឿ អ៊ីចឹងឬក៏យ៉ាងណា?

**ឆៈ** តាមខ្ញុំពិនិត្យទៅ គាត់ក៏អត់ជឿដែរ ពីព្រោះឆ្លើយមក វាហួស គ្រប់តែគ្នា។ ឆ្លើយហ្នឹងដូចអត់ពិតណ៎ា បានគាត់ក៏អត់ជឿដែរ គាត់ជូនទៅសៀវភៅចម្លើយនេះ មកឱ្យយើងអានវិញដើម្បីឱ្យយើងពិនិត្យទៅ ទាំងអស់ហ្នឹង។

[១៥:៣៦:២២]

**សៈ** តើ ប៉ុល ពត មានបានប្រាប់ថា <គាត់ដឹងថា មនុស្សដែលកំពុងតែជាប់>ពាក់ព័ន្ធ<នឹងការចាប់ខ្លួន ការសម្លាប់ទាំងនោះជាជនគ្មានកំហុស ព្រោះពួកគេ>ពាក់ព័ន្ធនៅក្នុងចម្លើយសារភាពនេះ

ឬក៏យ៉ាងណា?

**ឆ៖** អត់ដឹងដែរ រឿងហ្នឹង អត់ដឹងទេ។

**ស៖** ខ្ញុំសូមអានសម្រង់មួយឲ្យលោកស្តាប់ ចេញពីមនុស្សម្នាក់និយាយអំពី ប៉ុល ពត ដែលនិយាយអំពីចម្លើយសារភាពនេះ គឺឯកសារ E3/4202 សៀវភៅ ចេត សម្បត្តិ <និង ជីណា ចន។> បារាំង00849450, ខ្មែរ 00858362, អង់គ្លេសត្រង់ទំព័រ១១៩។ សៀវភៅនេះសរសេរថា៖ "ម៉ម នឹម មេបញ្ជាការដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ សុន សេន និង ប៉ុល ពត បានឆ្លើយនៅក្នុងកិច្ចសម្ភាសន៍មួយថា នៅពេលដែលមេបញ្ជាការ<កងទ័ពខ្មែរក្រហម> ហេង សំរិន រត់គេចទៅវៀតណាម គឺថាគាត់បានបញ្ជាឲ្យសម្លាប់ទាហានជាង<៦៧០>នាក់ចេញពីកងពលរបស់ ហេង សំរិន។ ប៉ុន្តែគាត់មិនធ្វើតាមបញ្ជារបស់ កែ ពក <ដែលសួរថា ហេតុអ្វីត្រូវទុកពួកគេនោះទេ>? ក្រោយមក <ប៉ុល ពត> បាន<កោះហៅ>កម្មាភិបាលជាន់ខ្ពស់ និងមេបញ្ជាការមកជួបក្នុងកិច្ចប្រជុំ។ គាត់ថា ប្រជាជនមិនត្រូវបំបែកចេញពីគ្នារវាងអ្នកថ្មី អ្នកចាស់ គឺអ្នកដែលរស់នៅទីក្រុង និងទីជនបទនោះទេ ដែលទាំងអស់នេះធ្វើឲ្យ ម៉ម នឹម ហ្នឹងគឺថាមានការភ្ញាក់ផ្អើល។ ប៉ុល ពត <បានចោទប្រកាន់>ថា <មេដឹកនាំមួយចំនួនក្បត់>ចលនានេះ <ហើយបាន>សម្លាប់មនុស្សច្រើនពេក។ គាត់ស្តីបន្ទោសឲ្យ សុន សេន និង កែ ពក <ចំពោះអ្វីដែលបានកើតឡើង>ពាក់ព័ន្ធទៅនឹង<ការបង្ក្រាប>ភូមិភាគបូព៌ា។ សូមដក<ស្រង់>៖ "សមមិត្ត សុន សេន និង កែ ពក សម្លាប់មនុស្សច្រើនណាស់ ហើយបានកប់គេ<ដោយប្រើ>ឡានប៊ុលដូហ្សឺ។ ខ្ញុំទទួលព័ត៌មានពីតាមរយៈគិញរបស់ខ្ញុំ"។ ប៉ុល ពត និយាយអ៊ីចឹង។ "អ្នកឯងក្បត់<ប្រជាជន> ហើយធ្វើឲ្យ<ប្រជាជន>ទៅចូលរួមជាមួយវៀតណាម។ <អ្នកឯង>ត្រូវតែកែប្រែខ្លួនចាប់ពីពេលនេះទៅ<>"។ ប៉ុលពត និយាយបន្តទៀតថា "អ្នកខ្លះគេចោទប្រកាន់ថា ជាភ្នាក់ងារ សេ.អ៊ី.អា, កា.ហ្សេ.បេ គឺជាមនុស្ស គ្មានទោសទេ ហើយចម្លើយសារភាពនេះ ដោយសារតែធ្វើទារុណកម្មពួកគេ។ ពួកគេខ្លះឆ្លើយថា គេធ្វើសេ.អ៊ី.អា តាំងពីមុនគេកើតទៅទៀត។"

តើ ប៉ុល ពត មានបានប្រាប់លោកថា ចម្លើយសារភាពទាំងអស់ហ្នឹងមិនឲ្យជឿបានទេ ដោយសារតែអ្នកឆ្លើយសារភាពហ្នឹង ត្រូវបានគេធ្វើទារុណកម្មដើម្បីទទួលបានព័ត៌មានបែបនេះ? ប៉ុល ពត មានប្រាប់លោករឿងនេះទេ?

[១៥:៣៩:២៨]

**ឆ៖** អត់ដែលឃើញប្រាប់ទេ។ អត់ឮ។

**សះ** តើ ប៉ុល ពត ធ្លាប់ដែលទទួលស្គាល់អីទេ នៅចំពោះមុខរបស់លោក ថាមានគេសម្លាប់ប្រជាជនច្រើនពេក? មានដែលនិយាយអ៊ីចឹងចំពោះមុខលោកទេ?

**ផះ** អត់ដែលឮនិយាយទេ។

**សះ** លោកសាក្សីខ្ញុំសូមបន្តឲ្យលឿនបន្តិចទៅនិយាយពីមនុស្សម្នាក់ ឈ្មោះ សុទ។ <លោកបាន>និយាយអំពី<ការងារ អំពីសារៈសំខាន់ក្នុងការងាររបស់លោកជាអ្នករៀបចំការងារ>។ លោកស្គាល់មនុស្សម្នាក់ឈ្មោះ សុទ្ធ ដែលទទួលបន្ទុកខាងផ្នែករៀបចំការងារ និងលើកប្រឡាយជីកទំនប់ទេ?

**ផះ** ឈ្មោះអី? អត់ច្បាស់។

**សះ** ឈ្មោះ សុទ។ សុទ គឺជាប្អូនប្រុសរបស់ សុភា<>?

**ផះ** អ៎ស្គាល់! សុទៗ មិនមែន សុខ ទេ។

**សះ** សូមអរគុណ។ ៤ឆ្នាំមុន <ពេលលោកបានផ្តល់សក្ខីកម្ម យើងបានពិភាក្សាអំពី>សារទូរលេខមួយគឺ E3/156 នៅថ្ងៃទី ០១ មករា ចុះថ្ងៃទី០១ មករា សូមកែប្រែ ២៣ មេសា ៧៨។ លោកចាំទេ នៅក្នុងសារទូរលេខហ្នឹង លោកស្នើសុំមតិពី ប៉ុល ពត ថាត្រូវចាត់ការយ៉ាងម៉េចជាមួយឈ្មោះ សុទ ដែលជាប់ពាក់ព័ន្ធជាមួយឈ្មោះ ជួន។ លោកចាំទេ ថាលោកបានផ្ញើសារទូរលេខចុះថ្ងៃទី២៣ មេសា ៧៨ មកប៉ុល ពត<ទេ>?

[១៥:៤១:៤៤]

**ផះ** បាទ ចាំ។ ពីព្រោះ សុទ ហ្នឹងកាលសម័យ តាឡាំង នៅហ្នឹងគាត់ជាប់ឃុំឃាំងរឿងស្រី។ ចោទថាគាត់ហ្នឹងក្បត់ជាតិ ខ្ញុំពិនិត្យ សុទ មកធ្វើការទៅ ខ្ញុំជួប សុទ ទៅវាអត់មានរឿងអ៊ីចឹង បានខ្ញុំស្នើថា ទៅលោក ប៉ុល ពត រឿងហ្នឹងវាអត់ពិតទេ រឿងគេរករឿងទេ។ ខ្ញុំថាសុំលែង លើកលែងទោស គាត់ក៏ឯកភាពឲ្យខ្ញុំ។ ខ្ញុំក៏អប់រំ សុទ ទៅក៏លែង រឿងស្រី ព្រោះស្រី។ សុទ ហ្នឹងគាត់មានប្រពន្ធហើយ ទៅស្រឡាញ់ស្រីថ្មី វាអ៊ីចឹងទេរឿងហ្នឹង។ ហើយនេះលើកលែងគាត់។

**សះ** សាក្សីដែលបានឆ្លើយកាលពីម្សិលមិញនិងថ្ងៃនេះ គឺ ប៊ុន ឡឹងចូយ គាត់បានឆ្លើយថា៖ "<គាត់នៅភូមិជាមួយ សុទ្ធ ហើយគាត់ស្គាល់សុទ្ធច្បាស់ណាស់។ គាត់និយាយថា> ក្រោយ សុទ ត្រូវបានគេចោទថាប្រព្រឹត្តខុសសីលធម៌ជាមួយស្ត្រី <គាត់ត្រូវបានគេចាប់>ខ្លួន <ហើយ>មិនដែលឃើញម្តងទៀតទេ។" ត្រឹមត្រូវដែរទេលោក? តើលោកមានបានទទួលបញ្ជាអ្វីពី ប៉ុល ពត ឲ្យចាត់ការយ៉ាងណាៗ យ៉ាងណីចំពោះ សុទ នេះទេ?

**ឆ៖** អត់ទេ កាលហ្នឹងលែងហើយ ពីរឿងគេចោទថារឿងស្រី រឿងប្រុសហ្នឹង--

**ស៖** *(គ្មានការបកប្រែ)*

**ឆ៖** មន្ទីរឃុំឃាំងនេះ លែងអស់ហើយ ទើបក្រោយមកនេះខ្ញុំអត់ដឹងទេ។ លែងអស់ហើយតើ។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ខ្ញុំ<យល់ថា>ខាង<>ដើមបណ្ដឹងរដ្ឋប្បវេណី<ត្រូវការយៈពេល២០នាទី។ ខ្ញុំមិនដឹងថាតើអាចបន្តទៅមុខទៀតបានឬទេ។ ខ្ញុំនឹងប្រគល់វេទិកាជូនទៅភាគីដើមបណ្ដឹងរដ្ឋប្បវេណី>ចុះ។

**លោក ពេជ អង្គ៖**

បាទ សូម--

[១៥:៤៤:០៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤៤:៥៤]

**លោក នីកូឡាស គូមជែន៖**

សហមេធាវីនាំមុខបានជម្រាបមកខ្ញុំថា ខ្ញុំអាចប្រើប្រាស់ពេលវេលារបស់គាត់។ ដូច្នេះ ខ្ញុំប្រើប្រាស់ពេលវេលា១៥នាទីនេះទៀត។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី ខ្ញុំសូមសួរលោកអំពីសារទូរលេខដែលខ្ញុំទើបលើកឡើងអំមិញនេះ គឺនៅថ្ងៃទី<០៧> មិថុនា <២០១២ លោកត្រូវបានគេសួរទាក់ទងនឹង>ឯកសារE3/248 ចុះថ្ងៃទី០១ ខែមករា ៧៨ នៅប្រហែលជាម៉ោង១០:០៨ គេបានសួរ<>លោក<នូវសំណួរមួយចំនួន ហើយបានអាន>សារទូរលេខ<នោះឲ្យលោកស្ដាប់>។ សារទូរលេខនេះនិយាយថា៖ “យើងខ្ញុំសូមរាយការណ៍អំពីយួនប្រាំបួននាក់រត់ចេញពីប្រទេស។ យោងតាមការសួរចម្លើយ <ពួកគេបានឆ្លើយថា> យួនបានចាត់តាំងពួកគេឲ្យមកធ្វើជាគិញនៅក្នុងប្រទេសកម្ពុជា ហើយរស់នៅជាមួយប្រជាជនកម្ពុជា ដើម្បីក្ដោបក្ដាប់សភាព-ការណ៍កម្ពុជា។ ឥឡូវនេះយើងបានបោសសម្អាតពួកគេអស់ហើយ។”

លោកសាក្សី នៅពេលលោកសរសេរសារទូរលេខថា លោកបានបោសសម្អាតអស់ហើយ នេះមានន័យថា ពួកគេត្រូវបានសម្លាប់អស់ហើយ ត្រឹមត្រូវទេ?

**លោក សៅ សារុនៈ**

**ឆៈ** អត់ត្រឹមត្រូវទេ។ អាហ្នឹងខ្ញុំបានឆ្លើយម្ដងហើយ។ អត់ៗយល់ទេ កាលសម័យ តាឡាំង គាត់នៅហ្នឹង ខ្ញុំអត់ដឹងទេ។ បើសម័យខ្ញុំមកហ្នឹង អត់មានទេ។ ខ្ញុំមកកាន់កាប់នៅតំបន់ អត់មាន។ មិនដែលឃើញគេចាប់យួន ចាប់អី។

[១៥:៤៦:៣៥]

**សៈ** លោកសាក្សី ឈ្មោះរបស់លោកនៅលើសារទូរលេខនេះ ចុះថ្ងៃទី០១ ខែមករា ៧៨ ក្រោយ ឡាំង ស្លាប់ទៅ។ ឥឡូវខ្ញុំសួរសំណួរបែបនេះលោក ពាក្យថា "យើងបានបោសសម្អាតពួកគេអស់ហើយ" តើលោកយល់ថា ប្រជាជនទាំងនេះត្រូវ<>បានសម្លាប់អស់ហើយឬ?

**ឆៈ** អត់យល់ទេ រឿងត្រូវសម្លាប់ជនជាតិយួននេះ។ អត់យល់ទេខ្ញុំ អត់យល់ទេ ខ្ញុំមិនដែលមានមតិអី រឿងសម្លាប់យួន សម្លាប់អីទេ អត់ទេ។

**សៈ** ខ្ញុំសូមសួរសំណួរនេះឡើងវិញ។ ពាក្យថា "យើងបានបោសសម្អាតពួកគេអស់ហើយ" តើលោកយល់ថា អ្នកទាំងនោះត្រូវបានគេសម្លាប់ចោលអស់ហើយដែរឬទេ?

**ឆៈ** អត់យល់ទេ។

**សៈ** សារទូរលេខនេះ ចុះថ្ងៃទី០១ ខែមករា ៧៨ តើលោកមានទទួលប្រតិកម្មណាមួយ<ទេ? ទូរលេខនេះផ្ញើទៅ>មន្ទីរ៨៧០។ <តើលោកមានបានទទួលប្រតិកម្មណាមួយមកពីមន្ទីរ៨៧០> ទាក់ទងទៅនឹងសារទូរលេខរបស់លោកនេះទេ?

**ឆៈ** អត់ដឹងទេ។

**សៈ** លោកសាក្សី តើនេះពិតជាថា លោកមិនដឹងអំពីការសម្លាប់មនុស្សណាម្នាក់ទាល់តែសោះ មែនឬ? <តើលោកកំពុងតែប្រាប់តុលាការថា លោកមិនបានដឹងអ្វីទាំងអស់ទាក់ទងនឹងការសម្លាប់មនុស្ស> ក្រោយពី ឡាំង ស្លាប់ទៅ<រហូតដល់វៀតណាមចូលមកដល់>?

[១៥:៤៨:២៧]

**ប្រធានអង្គជំនុំៈ**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែសុំការបញ្ជាក់មួយ ទាក់ទងទៅនឹងឯកសារដែលលោកសហព្រះរាជអាជ្ញាបានលើកឡើងហ្នឹង នៅជាសំណៅជាភាសាបារាំងហ្នឹងខ្ញុំមើលឃើញវា បងម-៨៧០។ អ៊ីចឹងខ្ញុំដូចជាយល់ថា លោកសហព្រះរាជអាជ្ញា គាត់ប្រើការិយាល័យ៨៧០ -- អ៊ំមន្ទីរ! សូមទោស។ <ខ្ញុំចង់បានការបញ្ជាក់ ពាក់ព័ន្ធទៅនឹងឯកសារដែលសហព្រះរាជអាជ្ញាបានលើកឡើង។>ព្រោះ<>នៅក្នុងជាភាសាបារាំងនេះ ខ្ញុំឃើញគេដាក់ “បង” <ម-៨៧០> ជា “បង”?

**លោក នីកូឡាស គូមជែន៖**

ខ្ញុំអត់មានសារទូរលេខជាមួយខ្ញុំនោះ គឺខ្ញុំអានចេញពីប្រតិចារឹកចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ហើយខ្ញុំបានប្រើពាក្យថា “មន្ទីរ៨៧០”<នៅក្នុងសំណួររបស់ខ្ញុំ>។ ខ្ញុំសួរសាក្សី ថាតើលោកមានបានទទួលប្រតិកម្មណាមួយ ទៅនឹងសារទូរលេខរបស់លោក ពីមន្ទីរ៨៧០ដែរទេ ដោយសារថាបានមានសរសេរថា៖ “ជូនបង មន្ទីរ៨៧០”<ហើយចុះហត្ថលេខាដោយ សារុន>។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី តើមន្ទីរ៨៧០ បានឆ្លើយតបទៅនឹងសារទូរលេខរបស់លោកនេះទេ?

**លោក សៅ សារុន៖**

**ឆ៖** អត់ទេ។ អត់ដែលសួរគាត់រឿង ៨០០ -- អ៊ូ! ៨៧០ អីទេ។

[១៥:៥០:០០]

**ស៖** លោកបានរាយការណ៍ជាប្រចាំ ជាទៀងទាត់ទៅមន្ទីរ៨៧០<មែនទេ? រាល់បញ្ហាសំខាន់ៗដែលកើតឡើងនៅតំបន់ ដែលជាការងាររបស់លោក លោក>ត្រូវរាយការណ៍<ប្រាប់ពួកគេនូវអ្វីដែលកំពុងតែកើតឡើង> ត្រឹមត្រូវដែរទេលោក?

**ឆ៖** អើ! អាហ្នឹងត្រឹមត្រូវ។ ពីព្រោះគេប្រធាន គេរាយការណ៍ប្រចាំខែ ប្រចាំថ្ងៃ រាយការណ៍អារឿងរាយការណ៍ទៅ៨៧០មែនហើយ។

**ស៖** តើមន្ទីរ៨៧០ បានបញ្ជូនសារទូរលេខ<>ទៅឲ្យលោក<>ញឹកញាប់ប៉ុនណាដែរ?

**ឆ៖** អត់ដឹងប៉ុន្មានដងទេ។ មានការគេណែនាំអី គេរាយការណ៍ជូន បើអត់មានទៅ ក៏អត់។ ជួនកាលមួយខែអី ម្តងអីអ៊ីចឹង ពេលណាមានសភាពការណ៍អីវាប្រែប្រួល ទៅណែនាំរឿងជីវភាពប្រជាជនអី ប៉ុណ្ណឹង។

**សៈ** ដូច្នេះជាមធ្យម តើលោកទទួលសារទូរលេខ<>មួយដងក្នុងមួយសប្តាហ៍<ឬ? តើញឹកញាប់ប៉ុនណា ដែលលោកទទួលបានសារទូរលេខជាមធ្យមនោះ>?

**ផះ** ជួនកាលមួយខែពីរដងក៏មាន បីដងក៏មាន វាអត់ទៀតទាត់ទេ។ តែមាន ៗសភាពការណ៍អីគាត់ណែនាំមក គាត់មានសារមក ពេលខ្លះអត់ក៏អត់ទៅ។ ជួនកាលមានមួយខែពីរដង ជួនបីដងក៏មានដែរ។

[១៥:៥២:០១]

**សៈ** តើលោកធ្លាប់បានទទួលសារទូរលេខណាមួយរិះគន់លោក<ក្នុងការចាប់ខ្លួននរណាម្នាក់ ឬក៏>ទិតៀន<តំបន់ក្នុងការ>ចាប់ប្រជាជន<ឬក៏>សម្លាប់ចោលអីដែរទេ?

**ផះ** អត់ទេ។ ពីព្រោះខ្ញុំវាមិនបានប្រព្រឹត្តអារឿងចាប់ប្រជាជនទៅសម្លាប់ចោលទេ ខ្ញុំមកទទួលការងារហ្នឹងនៅក្នុងតំបន់តែពីរខែទេ អត់ដែលទេ។ អត់! មិនដែលថាទិតៀនខ្ញុំរឿងហ្នឹងដែរ។ ខ្ញុំក៏មិនដែលប្រព្រឹត្តរឿងហ្នឹងដែរ។

**សៈ** តើអ្នកណាដែលជួយធ្វើការលោកនៅមន្ទីរតំបន់ គឺកម្មាភិបាលដែលជួយធ្វើការលោកនៅមន្ទីរតំបន់ជាអ្នកណាខ្លះដែរ?

**ផះ** ឃើញពីអ្នកណា មានតែៗអីជំនាន់ខ្ញុំហ្នឹង ឃើញមានពីណាទេ មានតែយុទ្ធជនធម្មតាអីប៉ុណ្ណឹង។ ខ្ញុំពិនិត្យ ខ្ញុំទៅធ្វើតែខ្ញុំទៅ អត់ពីណាជួយទេ។

**សៈ** តើលោកចាំទេថា ធិន ជំនួស តាឡយ <ជាប្រធាន>មន្ទីរក-១៧<ទេ>?

**ផះ** តាអី តាធិន? ដូចអត់ច្បាស់ត្រង់ហ្នឹង សូម--

**សៈ** បាទ តាធិនៗ។

**ផះ** និយាយម្តងទៀត។

**សៈ** លោកនៅចាំឈ្មោះ តាឡយ ទេដែលជំនួសឈ្មោះ ធិន?

**ផះ** ចំណាំ តាឡយ។ តាធិន ហ្នឹងប្រធាន។ តាឡយ ហ្នឹងជាសមាជិករបស់គេនៅក្នុងប្រធានមន្ទីរក-១៧នោះ អាហ្នឹងស្គាល់។

**សៈ** គាត់ឈ្មោះ វីន ឡយ អ៊ីចឹងទេលោក ត្រឹមត្រូវទេ?

**ផះ** បាទ ត្រឹមត្រូវ។

[១៥:៥៤:២៧]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** តើមានអ្វីកើតឡើងទៅលើឈ្មោះ វីន ឡូយ នេះ?

**ឆៈ** កាលហ្នឹង ដឹងកើតឡើងអីទេ ខ្ញុំអត់ស្គាល់ដែរ មិនដឹងជារឿងអីរបស់គេ។

**សៈ** តើគាត់បន្តធ្វើការជាមួយលោករហូតដល់ពេលវៀតណាមចូលមក ឬក៏យ៉ាងណា?

**ឆៈ** ម៉េច? សូមនិយាយម្តងទៀតអត់ច្បាស់។

**សៈ** តើ តាឡូយ បន្តធ្វើការនៅមន្ទីរក-១៧ រហូតដល់ពេលវៀតណាមចូលមក ឬក៏យ៉ាងណា?

**ឆៈ** អើ! គាត់ធ្វើការរហូតតើ! តាំងពីសម័យ តាឡាំង នៅគាត់ធ្វើការរហូតជាមួយ តាធិន ហ្នឹង។ តាធិន ប្រធាន, គាត់ហ្នឹងជាសមាជិកនៅក្នុងគណៈមន្ទីរគេហ្នឹង គណៈមន្ទីរក-១៧។

**សៈ** ខ្ញុំសូមអានហើយរំឭកការចងចាំរបស់លោក។ លោកសាក្សី យើងមានបញ្ជីឈ្មោះអ្នកទោសនៅស-២១ ឯកសារ E3/2251, E3/1651 ឯកសារទាំងពីរបង្ហាញថា វីន ឡូយ ដែលជាប្រធានមន្ទីរ<តំបន់១០៥> បានចូលមក ស-២១ នៅ<ថ្ងៃទី២០> ខែតុលា ឆ្នាំ៧៨។ អ៊ីចឹងបញ្ជាក់ថា គាត់មិនអាចបន្តធ្វើការជាមួយលោករហូតដល់ពេលវៀតណាមចូលមកដល់នោះទេ។ តើហេតុអ្វីបានជាលោកមិនប្រាប់តុលាការថា ឡូយ បាត់ខ្លួន? ម៉េចទៅបានលោកមិនហ៊ានឆ្លើយថា ឡូយ បាត់ខ្លួន?

**ឆៈ** បាត់មែនហ្នឹងណ៎ា គេធ្វើការហ្នឹង ហើយខ្ញុំ តា០៦ –តាសាន– នេះកងពលនេះ គេ មិនដឹងគេចាប់ មិនដឹងគេអី បញ្ជូនទៅណា ខ្ញុំអត់ដឹងដែរ ពីព្រោះខ្ញុំដឹងតែមកប្រចាំនៅតំបន់ ខ្ញុំនៅស្រុក មកយូរៗម្តង។ មិនដឹងគេបញ្ជូនទៅ អាហ្នឹងតុលាការអី ខ្ញុំអត់ដឹងដែរ។

[១៥:៥៧:០៥]

**សៈ** លោកសាក្សី<មានកំណត់ហេតុ>បញ្ជាក់ច្បាស់ថា មនុស្សជាច្រើនមកពី<មន្ទីរពាណិជ្ជ-កម្ម>តំបន់១០៥ មកពីកងពល៩២០ <និងផ្នែកខ្លះនៃ>តំបន់១០៥ <ត្រូវបាន>បញ្ជូនមក ស-២១ <នៅឆ្នាំ១៩៧៨>។ លោកដឹងទេថា គេមាននីតិវិធី គេមានច្បាប់ទម្លាប់បែបណាដែលត្រូវបញ្ជូនមនុស្សចេញពីតំបន់១០៥ មក<ភ្នំពេញ> នេះ?

**ឆៈ** អត់ដឹងទេ ខាងកងពល ខ្ញុំអត់ដឹងទេ មិនដឹងជាគេជ្រើសវិធីយ៉ាងម៉េចៗ ខ្ញុំអត់ដឹង។ មិនដឹងគេបញ្ជូនយ៉ាងម៉េច ដឹងវាអី អត់ដឹង។

**សៈ** ចុះលោកដឹងថា គេយកមនុស្សមក ស-២១ ហ្នឹងដោយមធ្យោបាយអីទេ ដឹកជញ្ជូនដោយរបៀបណាទេ?

**ឆៈ** ដឹងដែរ ដឹកជញ្ជូនតាមឡាន ជញ្ជូនតាមក្រចេះ មកដល់ក្រចេះអីហ្នឹង គេជិះកាណូត ជិះអី

អាហ្នឹងយល់ ឮគេនិយាយ ប៉ុន្តែភ្នែកខ្ញុំអត់ឃើញទេ។ ខ្ញុំនៅការនៅស្រុកឯណោះ អត់ដឹង។

**ស៖** ខ្ញុំសូមត្រឡប់ទៅនិយាយពេលដែល ប៉ុល ពត ឲ្យលោកឡើងជំនួស ឡាំង នេះ។ ៤ឆ្នាំមុននេះ លោកឆ្លើយថា លោកទៅមន្ទីរហ្នឹង<ប្រហែល>ពីរដង<>ក្នុងមួយអាទិត្យ។ តើ<នោះ>គឺដោយសារតែនៅក្នុងមន្ទីរតំបន់ហ្នឹង<ត្រូវបានប្រើជាកន្លែង>ផ្ទុកអ្នកទោស<>ឬក៏យ៉ាងម៉េច?

[១៥:៥៩:00]

**ឆ៖** ខ្ញុំទៅ កាលនោះខ្ញុំនៅមិនទាន់ទទួលខុសត្រូវទេ ខ្ញុំគ្រាន់តែមកជួយ មួយអាទិត្យពីរដង ម្តងមួយថ្ងៃ ឬក៏ពីរថ្ងៃអី។ អ្នកទោសហ្នឹងក៏មិនសូវមានច្រើនដែរ ប្រហែលជាបីបួននាក់ ដឹងគេទោសរឿងអី។ ខ្ញុំអត់ដឹងដែរ រឿងគេចាប់គេចងអី តាឡាំង ទេ។ រឿងដែលឃើញ*(ឮមិនច្បាស់)*មកហ្នឹង គេឃើញមនុស្សទោសហ្នឹង ក៏បានសាកសួរទៅដោះលែងគេខ្លះ ដោះលែងគេ វាអត់មានរឿង។ ខ្ញុំទៅឃើញមានច្រើនដែរអ្នកទោសហ្នឹង ប្រហែលជាបីបួននាក់ទេ។ តាមខ្ញុំឃើញ អាហ្នឹងខ្ញុំមិនមែននិយាយភូតភរទេ តាមឃើញ អ្នកទោស តាឡាំង គាត់យកមកដាក់--

**ស៖** លោកសាក្សី ពីរនាក់<ដែលត្រូវបានគេឃុំឃាំង>នៅមន្ទីរហ្នឹង<>និយាយថាមានមនុស្សប្រហែលជា៨០នាក់ រួមទាំងកូនក្មេងផង។ តើក្នុងចំណោមអ្នកទោសដែលគេឃុំនៅមន្ទីរតំបន់១០៥ហ្នឹង លោកមានឃើញគេឃុំទាំងក្មេងៗផងដែរទេ?

**ឆ៖** អត់ឃើញទេ។ តាមខ្ញុំឃើញនេះ ខ្ញុំទៅជំនួស តាឡាំង ហ្នឹង មិនឃើញមានក្មេងមានអីទេ មានតែមនុស្សប្រុសបីបួននាក់ នៅជាប់ទោសនៅហ្នឹង។

**ស៖** លោកសាក្សី <> មន្ទីរក-១៧ ត្រូវបានប្រើប្រាស់<ដើម្បី>ឃុំឃាំងមនុស្ស ដោយសារថា <កន្លែងឃុំឃាំងអ្នកទោសនៅ>ភ្នំក្រោល <ក-១១>ពេញពេក ឬក៏យ៉ាងម៉េច<>?

**ឆ៖** អត់ដឹងទេ ខ្ញុំអត់ដឹងទេ។ បែប តាមខ្ញុំធ្លាប់ទៅធ្វើការ តាឡាំង ធ្លាប់ហៅហ្នឹង មិនឃើញមានមនុស្សនៅឃុំឃាំងនៅក-១៧ហ្នឹង អត់ឃើញទេ។ មានតែចាកន្លែងគុកហ្នឹងបីបួននាក់ ដូចខ្ញុំថាហ្នឹងថាមកឃុំឃាំងនៅមន្ទីរហ្នឹង ខ្ញុំអត់ឃើញទេ។ ធ្លាប់ តាឡាំង ហៅទៅធ្វើការ*(ឮមិនច្បាស់)*--

[១៦:០១:២០]

**ស៖** ខ្ញុំសូមសង្ខេបនូវអ្វីដែលលោកបានឆ្លើយនៅរសៀលនេះ។ ប៉ុល ពត បានសួរទៅលោកដោយផ្ទាល់ខ្លួន ឲ្យលោកទទួលតួនាទីក្រោយពី ឡាំង ស្លាប់ទៅ។ លោកបានអនុវត្តគោលនយោបាយ <ប៉ុល ពត> ដោយស្មោះត្រង់ ក៏ដូចជាអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដោយស្មោះត្រង់

ហើយលោកមិនដែលទទួលការរិះគន់ ឬក៏ការទិតៀនណាមួយពី<ពួកគេ>ទេ <ចំពោះការធ្វើការរបស់លោក>។ ត្រឹមត្រូវដែរទេលោក?

**ឆ៖** បាទ ត្រឹមត្រូវ។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ហើយសវនាការថ្ងៃនេះ ដល់ពេលត្រូវឈប់សម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី៣០ ខែមីនា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី សៅ សារុន តាមប្រព័ន្ធសោតទស្សន៍បញ្ចប់ ហើយនិងផ្តើមសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1016 ពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់មន្ទីរសន្តិសុខភ្នំក្រោល សូមភាគីជ្រាប និងអញ្ជើញចូលរួម តាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក សៅ សារុន ដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកឱ្យមកបន្តផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីទីនោះមក អ.វ.ត.ក នៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

[១៦:០២:៥៨]

ហើយអង្គជំនុំជម្រះក៏សូមអរគុណលោក មឿន សុវណ្ណ មេធាវីប្រឹក្សាសាក្សី នាពេលនោះលោកអាចសម្រាកបានហើយ។ ហើយក៏អញ្ជើញលោកមកចូលរួមប្រឹក្សាសាក្សី សៅ សារុន តាមប្រព័ន្ធសោតទស្សន៍នៅទីនោះ នៅថ្ងៃស្អែកទៀតដែរ នឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយអរគុណផងដែរ លោក ញ៉ែម សំណាង បុគ្គលិកអង្គការ ធី.ភី.អូ ដែលបានជួយសម្របសម្រួលក្នុងការធ្វើសវនាការតាមប្រព័ន្ធសោតទស្សន៍ រវាងសាក្សីជាមួយនឹងអង្គជំនុំជម្រះ ហើយថ្ងៃនេះលោកអាចសម្រាកបានហើយ។ ហើយជួបគ្នានៅថ្ងៃស្អែកវេលា ម៉ោងប្រាំបួនព្រឹកណ៎ា។

**លោក ញ៉ែម សំណាង៖**

បាទ លោកប្រធាន។

01239309


**លោក សៅ សារុន៖**

បាទ។

**ប្រធានអង្គជំនុំ៖**

បង្គាប់អនុរក្សមន្ទីរឃុំឃាំងនាំខ្លួន លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*